**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព ខណ្ឌច្បារអំពៅ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក. ឆឹយ សុលីនណា**

**ក. សៀ គីមចេង**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព ខណ្ឌច្បារអំពៅ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. នីយ សុលីនណា**

**ក. សៀ គីមចេង**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ឆ្ឆ📖ឲឲ

យើងខ្ញុំទាំងពីររូបឈ្មោះ **ក.នីយ សុលីនណា** និង **ក.សៀ គីមចេង** ជានិស្សិតជំនាន់ទី២១ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំទាំងពីរ សូមលំឱនកាយគោរពធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងការយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាដោយផ្តល់ភាពកក់ក្តៅ សេចក្តីស្រលាញ់ មេត្តា ករុណា និងអប់រំទូន្មានប្រៀនប្រដៅកូនប្រកប ដោយព្រហ្មវិហារធម៌ ឱ្យកូនប្រព្រឹត្តិខ្លួនតាមគន្លងល្អៗ ដើម្បីរស់នៅក្នុងសង្គម ដោយភាពថ្លៃថ្នូរ ព្រមទាំងការទំនុកបំរុងខាងស្មារតី និងឧបត្ថម្ភជាថវិកា សំភារៈ ដល់ការសិក្សារៀនសូត្រតាំងពីមត្តេយ្យសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រ ។

**ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង** ថ្នាក់ដឹកនាំ បុគ្គលិក និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំគ្រប់គ្រង ជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីររូប រហូតទទួលបានជោគជ័យ និងបានឈានដល់ការចូលរួមសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនេះ ។

ហើយយើងខ្ញុំទាំងពីរ ក៏សូមធ្វើការថ្លែងអំណរគុណ ជាពិសេសចំពោះ លោកគ្រូសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សតក្កដា** គឺជាសាស្ត្រាចារ្យដែលប្រកបដោយព្រហ្មវិហារធម៌ ចំពោះនិស្សិត និងប្រកបដោយគតិបណ្ឌិត ដែលបានផ្តល់អនុសាសន៍សំខាន់ៗ បានចំណាយពេលយ៉ាងមានតម្លៃខិតខំពន្យល់ ណែនាំ ចែករំលែកបទពិសោធន៍ល្អៗ ជួយកែសម្រួលអក្ខរាវិរុទ្ធ និងការប្រើប្រាស់ពាក្យពេចន៍យ៉ាងច្រើននៅក្នុងអត្ថបទនេះ ដើម្បីជួយជម្រុញឱ្យសារណារបស់យើងខ្ញុំទាំងពីររូប សម្រេចជាលទ្ធផលយ៉ាងល្អមួយនេះ។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីររូប សូមសំដែងនូវការដឹងគុណអស់ពីដួងចិត្ត និងសូមឱ្យ **លោកអ្នកមានគុណទាំងពីរ** និង**លោកគ្រូសាស្ត្រាចារ្យណែនាំ បណ្ឌិត អ៊ុន សតក្កដា** ប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

អស់រយៈពេលបួនឆ្នាំ ដែលយើងខ្ញុំទាំងពីរនាក់បានចូលមកសិក្សានៅក្នុង**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ។ នៅក្នុងសាកលវិទ្យាល័យនេះ គឺពិតជាសាកលវិទ្យាល័យមួយដែលគួរចាប់អារម្មណ៍ ព្រោះសំបូរទៅដោយសាស្ត្រាចារ្យល្បីៗ ដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន និងណែនាំនិស្សិតឱ្យយល់ច្បាស់ពីជំនាញ ដែលនិស្សិតបានជ្រើសរើសយកមកសិក្សា ក្នុងនោះដែរ ចំពោះជំនាញដែលយើងខ្ញុំទាំងពីរ បានជ្រើសរើសយកមកសិក្សានោះ គឺជំនាញផ្នែកនីតិសាស្ត្រ ។

ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរពិតជាមានក្តីសោមនស្សរីករាយជាខ្លាំង ដោយយើងខ្ញុំទាំងពីរនាក់ទទួលបានចំណេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ដោយចំណេះដឹងដែលទទួលបាននេះហើយ ក៏បានជម្រុញឱ្យយើងខ្ញុំទាំងពីររូប ធ្វើការសម្រេចចិត្តជ្រើសរើសការសរសេរសារណាបញ្ចប់ការសិក្សានេះឡើងដោយជ្រើសរើសប្រធានបទ **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌច្បារអំពៅ** នេះមកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវ ដើម្បីជាជំនួយស្មារតី ក៏ដូចជាឯកសារសិក្សាបន្ថែមសម្រាប់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកដែលចង់ស្វែងយល់ពីការរៀបចំសណ្តាប់ធ្នាប់ និងការសោភ័ណភាពរបស់ខណ្ឌច្បារអំពៅផងដែរ ។

យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ គឺនៅពេលមានចំណុចខ្វះចន្លោះ ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យដូចនេះ សូមលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំផង ហើយក្រុមយើងខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ក្នុងការទទួលនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចែករំលែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះឱ្យមានភាពល្អប្រសើរ។

*សូមអរគុណ!*

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** .......... ១

**ជំពូកទី១**

**ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅ**

**១.១.ទិដ្ឋភាពទូទៅរបស់ខណ្ឌច្បារអំពៅ** .......... ៤

**១.១.១.មូលហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់** .......... ៥

១.១.១.១.កំណើនប្រជាជន .......... ៦

១.១.១.២.ភាពក្រីក្រ .......... ៧

១.១.១.៣.ចរាចរណ៍ .......... ៨

១.១.២.៤.សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ .......... ៨

**១.១.២.រចនាសម្ព័ន្ធរបស់ខណ្ឌច្បារអំពៅ** .......... ៩

១.២.១.១.ក្រុមប្រឹក្សាខណ្ឌ .......... ១០

១.១.២.២.គណៈអភិបាល .......... ១២

**១.២.បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់** .......... ១៤

**១.២.១.បច្ចុប្បន្នភាពនៃការរៀបចំសណ្តាប់ធ្នាប់** .......... ១៤

១.២.១.១.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ .......... ១៤

១.២.១.២.ការអភិវឌ្ឍសំណង់លំនៅដ្ឋាន .......... ១៧

១.២.១.៣.ការរៀបចំរបៀបរៀបរយ .......... ១៩

**១.២.២.ទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់** .......... ២០

១.២.២.១.ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន .......... ២០

១.២.២.២.ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ .......... ២២

១.២.២.៣.ការអភិវឌ្ឍលើវិស័យដីធ្លី .......... ២២

១.២.២.៤.ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ .......... ២២

## ជំពូកទី២

## ការរៀបចំសោភ័ណភាពខណ្ឌច្បារអំពៅ

**២.១.ការរៀបចំសោភ័ណភាពពេលថ្ងៃ និងពេលយប់**......................................................២៤

**២.១.១.ការរៀបចំសោភ័ណភាពពេលថ្ងៃ**........................................................................២៤

២.១.១.១.ការដាំដើមឈើដងផ្លូវ......................................................................................២៥

២.១.១.២.ការបង្កើតប្រព័ន្ធសុវត្ថិភាពចរាចរណ៍តាមដងផ្លូវ..........................................................២៥

២.១.១.៣.ការរៀបចំសំណង់អគារតូចធំ តាមផ្លូវ.......................................................................២៩

**២.១.២.ការរៀបចំសោភ័ណភាពពេលយប់**........................................................................៣០

២.២.២.១.ការបំពាក់ភ្លើងតាមដងផ្លូវ...................................................................................៣០

២.២.២.២.ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងកន្លែងសាធារណៈ..........................................៣១

**២.២.ការបំពុលបរិស្ថាន និងដំណោះស្រាយ**.......................................................................៣១

**២.២.១.ការបំពុលទឹក និងដំណោះស្រាយ**.........................................................................៣២

**២.២.២.ការបំពុលដី និងដំណោះស្រាយ**...........................................................................៣៥

**២.២.៣.ការបំពុលខ្យល់ និងដំណោះស្រាយ**.......................................................................៣៦

**២.២.៤.ការបំពុលដោយសំណល់រឹង រាវ និងដំណោះស្រាយ**...................................................៣៦

**២.២.៥.ការបំពុលដោយសំឡេង និងដំណោះស្រាយ**...........................................................៣៩

**សេចក្តីសន្និដ្ឋាន**............................................................................................................៤៤

**អនុសាសន៍**..................................................................................................................៤៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់ជាច្រើនទសវត្សមកនេះ ព្រះរាជាណាចក្រកម្ពុជាក៏កំពុងតែធ្វើដំណើរយ៉ាងខិតខំប្រឹងប្រែងនៅក្នុងការរៀបចំសណ្តាប់ធ្នាប់ និងធ្វើការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ដើម្បីប្រទេសជាតិរបស់ខ្លួនមានភាពជឿនលឿនទៅមុខ ឱ្យដូចប្រទេសដទៃទៀត ដែលកំពុងអភិវឌ្ឍន៍នៅក្នុងសកលលោកយើងនេះផងដែរ។ នៅក្នុងការអភិវឌ្ឍនេះផងដែរ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់កន្លែង មានដូចជា ទីក្រុង ស្រុក ខណ្ឌនានា ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់នីមួយៗ។

ប្រទេសកម្ពុជារបស់យើងសព្វថ្ងៃ ត្រូវធ្វើការរៀបចំ និងអភិវឌ្ឍប្រទេសឱ្យស្របទៅតាមការកំណត់នៃប្លង់គោល ដែលបានរៀបចំដោយគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ ឬអនុគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្តនីមួយៗ ត្រូវគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍ រាជធានី ខេត្ត ក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងកំណត់ដោយអនុក្រឹត្យ។ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព គឺជាកត្តាដ៏សំខាន់មួយ ដើម្បីកែលម្អ ឱ្យមានភាពល្អប្រសើរឡើងជាងមុន ដោយស្របទៅតាមប្លង់គោល និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឱ្យរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អជឿនលឿនទៅមុខជាបន្តបន្ទាប់។ សណ្តាប់ធ្នាប់ គឺការសម្តៅដល់ធាតុ៣ សន្តិសុខ ភាពស្ងប់ស្ងៀម និងអនាម័យ។ សោភ័ណភាពគឺល្អ ហ្មត់ហ្មង។ ដោយឡែកខណ្ឌនីមួយៗនៃព្រះរាជាណាចក្រកម្ពុជាក៏នៅមានភាពខ្វះចន្លោះ និងបញ្ហាប្រឈមផងដែរ ដោយបច្ចុប្បន្នគណៈអភិបាលខណ្ឌនីមួយៗកំពុងតែខិតខំប្រឹងប្រែង ដោះស្រាយចំពោះបញ្ហាប្រឈមដែលកំពុងកើតឡើង និងខិតខំកសាងអភិវឌ្ឍន៍ខណ្ឌជាបន្តបន្ទាប់។ ហេតុនេះក្រុមយើងខ្ញុំមានការជ្រើសរើស ប្រធានបទ“**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌច្បារអំពៅ**” នេះឡើងដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យមានភាពស៊ីជម្រៅ និងទទួលបាននូវចំណេះដឹងថ្មីបន្ថែមទៀត។

ដោយមើលឃើញពីបញ្ហាប្រឈមនានាដែលបានកើតឡើង រាជរដ្ឋាភិបាល ព្រមទាំងគណៈអភិបាលខណ្ឌច្បារអំពៅបានធ្វើការស្តារ និងជួសជុលទៅលើប្រព័ន្ធបង្ហូរទឹក ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ រៀបចំបន្ថែមទៅលើសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្នុងខណ្ឌ ដែលកត្តាទាំងនេះជាមូលហេតុនាំឱ្យមានការអភិវឌ្ឍនៅក្នុងខណ្ឌច្បារអំពៅ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងខណ្ឌច្បារអំពៅ គឺមានគណៈអភិបាលខណ្ឌ និងអភិបាលរងខណ្ឌ ព្រមជាមួយមន្ត្រីទាំងអស់ដែលមានតួនាទីក្នុងការអភិវឌ្ឍ និងរៀបចំក្នុងខណ្ឌនេះឱ្យបានល្អ។

ទោះជាយ៉ាងនេះក្តី ដើម្បីឱ្យនិស្សិតក្តី មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណៈជនទាំងអស់បានយល់កាន់ច្បាស់អំពីខណ្ឌច្បារអំពៅ គឺចោទជាសំណួរថា **តើខណ្ឌច្បារអំពៅមានវិធានការណ៍អ្វីខ្លះក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពឱ្យបានល្អ?** **តើខណ្ឌច្បារអំពៅមានទិសដៅអភិវឌ្ឍន៍អ្វីខ្លះនាពេលអនាគត?** **តើខណ្ឌច្បារអំពៅមានដំណោះស្រាយអ្វីខ្លះចំពោះការការពារបរិស្ថានឱ្យមានភាពល្អប្រសើរ?**

ដូចនេះនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណៈជន ប្រាកដជាយល់ដឹងអំពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌច្បារអំពៅ ថែមទាំងនាំមកនៅយកស្នាដៃស្រាវជ្រាវនេះធ្វើជាឯកសារពិគ្រោះ និងជំនួយស្មារតីបានទៀតផង។

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការស្រាវជ្រាវទាំងអស់ គឺតែងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ដោយឡែកក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធាននេះ គឺចង់ឱ្យនិស្សិត សាធារណជន បានយល់ដឹងពីការអភិវឌ្ឍ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៃខណ្ឌនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសចង់ឱ្យនិស្សិតជំនាន់ក្រោយបានយល់ដឹង និងជ្រួតជ្រាបច្បាស់ពីការអភិវឌ្ឍ ព្រមទាំងអាចយកជាឯកសារនេះសម្រាប់ជាជំនួយស្មារតីបន្ថែមលើការស្រាវជ្រាវរបស់ខ្លួន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទាំងអស់ តែងតែមានដែនកំណត់របស់ខ្លួន។ ដូច្នេះអ្វីដែលទាក់ទងទៅនឹងប្រធានបទ "ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌច្បារអំពៅ" គឺយើងនឹងធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើអ្វីដែលពាក់ព័ន្ធ នឹងសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌច្បារអំពៅ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ គឺពិតជាមានសារៈសំខាន់ដល់និស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ សាធារណជនទាំងអស់ អាចជួយសម្រួលដល់ការអភិវឌ្ឍ ឬរៀបចំសណ្តាប់ និងសោភ័ណភាពក្នុងខណ្ឌច្បារអំពៅដើម្បីយកទៅអភិវឌ្ឍន៍ក្នុងខណ្ឌដទៃទៀត ឬក្នុងស្រុកណាមួយបានថែមទៀត។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ គឺធ្វើបកស្រាយ និងបំភ្លឺទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាមានបញ្ហាប្រឈម និងដំណោះស្រាយរបស់ខណ្ឌព្រមទាំងឯកសារ ដែលទទួលបានពីសាលាខណ្ឌច្បារអំពៅ និងបណ្តាលផ្សព្វផ្សាយ ដែលបានសិក្សាស្រាវជ្រាវជាមួយទិដ្ឋភាពទូទៅផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធាននេះដែរ គឺបានធ្វើការបែងចែកជា២ជំពូក ក្នុងនោះមាន ៖

**១.ជំពូកទី១** ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅ ដែលជំពូកទី១បែងចែកពីរផ្នែក ដោយផ្នែកទី១ បកស្រាយអំពីទិដ្ឋភាពទូទៅ រីឯផ្នែកទី២បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់។

**២.ជំពូកទី២** ការរៀបចំសោភ័ណភាពខណ្ឌច្បារអំពៅ ហើយជំពូកទី១បែងចែកពីរផ្នែក ដោយផ្នែកទី១ ការរៀបចំសោភ័ណភាពពេលពេលថ្ងៃ រីឯផ្នែកទី២ ការបំពុលបរិស្ថាន និង ដំណោះស្រាយ។

# ជំពូកទី១

# ការរៀបចំសណ្ដាប់ធ្នាប់

# ក្នុងខណ្ឌច្បារអំពៅ

# ជំពូកទី១

# ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅ

យោងតាមការវិភាគពីស្ថានភាព ក៏ដូចជាបញ្ហាសណ្តាប់ធ្នាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះផ្សារភ្ជាប់ជាមួយបញ្ហាប្រឈមជាមួយជម្ងឺរីករាលដាលកូវីដ-១៩ ដែលកើតឡើងនាពេលបច្ចុប្បន្ននេះ។ យើងសរបញ្ជាក់ឱ្យឃើញថា ការរៀបចំសណ្តាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅ នៅតាមទីសាធារណៈ ត្រូវបានសាលាខណ្ឌធ្វើការយកចិត្តដាក់យ៉ាងខ្លាំង ដោយសារសាលាខណ្ឌបានធ្វើការរក្សាសន្តិសុខសុវត្ថិភាព ព្រមទាំងការរៀបចំសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋក្នុងការរស់នៅប្រកបដោយភាពត្រឹមត្រូវផងដែរ។ ប៉ុន្តែបញ្ហាសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅ ក៏នៅចោទជាបញ្ហាសម្រាប់សាលាខណ្ឌនៅឡើយ និងប្រជាពលរដ្ឋមួយចំនួនបានបំពានច្បាប់ ដែលជាហេតុធ្វើឱ្យសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅមិនទាន់មានភាពល្អប្រសើរ។ បញ្ហាទាំងអស់នេះហើយ គឺជាបញ្ហាដ៏សំខាន់មួយដែលអាជ្ញាធរខណ្ឌ គួរគប្បីដោះស្រាយបញ្ហាឱ្យទាន់សភាពការណ៍ និងត្រូវព្យាយាមផ្សព្វផ្សាយច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធនឹងការរៀបចំសណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋឱ្យបានយល់បង្ហាញដោយភាពទន់ភ្លន់ ដើម្បីជាភាពងាយស្រួលឱ្យពួកគាត់បានយល់ពីច្បាប់ និងគោលដៅដែលសាលាខណ្ឌមានផែនការយុទ្ធសាស្ត្រនាពេលអនាគត។ ម្យ៉ាងវិញទៀត មុននឹងឈានដល់ការរៀបចំ ឬការអភិវឌ្ឍត្រូវពិនិត្យមើលទៅតាមប្លង់គោល ដែលបានកំណត់ជាមុនសិន ក្នុងការរៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយ។ ប្លង់គោលជាឯកសារ ឬជាគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍ រាជធានីភ្នំពេញ។ ប្លង់គោលជាប្លង់គ្រឹះ និងជាប្លង់តម្រង់ទិសក្នុងការបែងចែក កំណត់ផ្ទៃដី សម្រាប់កំណត់តំបន់សាងសង់ តំបន់ចាក់សំរាមតំបន់សាលារៀន តំបន់ដែលត្រូវរក្សាការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍។[1] ក្នុងនោះក៏បានកំណត់ក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលបានចែងក្នុងមាត្រា៧ បានចែងថាដីអាចសាងសង់បាន ឬសាងសង់មិនបានមានដូចតទៅ ៖

- តំបន់សម្រាប់ការពារជាតិ
- តំបន់សម្រាប់ពាណិជ្ជកម្ម
- តំបន់កសិកម្ម ឧស្សាហកម្ម
- តំបន់សិប្បកម្ម
- តំបន់ទេសចរណ៍
- តំបន់វប្បធម៌ សាសនា
- តំបន់សម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ។[2]

[1] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩-២០២០ ទំព័រទី១៤៤

[2] មាត្រា៧ នៃច្បាប់ស្តីពី "ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤

## ១.១. ទិដ្ឋភាពទូទៅរបស់ខណ្ឌច្បារអំពៅ

ដោយយោងតាមអនុក្រឹត្យលេខ៥៧៩ អនក្រ.បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ខណ្ឌច្បារអំពៅ ជាខណ្ឌមួយទើបតែបង្កើតថ្មីដែលបានបំបែកចេញពីខណ្ឌមានជ័យ ខណ្ឌមានជ័យនៅក្នុងសម័យអាណានិគមនិយមបារាំងរហូតដល់សម័យសង្គមរាស្ត្រនិយមត្រូវបែងចែកជាពីរគឺ ៖

ទី១ ៖ ខាងកើតទន្លេបាសាក់ មានឈ្មោះថា ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

ទី២ ៖ ខាងលិចទន្លេបាសាក់ មានឈ្មោះថា ឃុំចាក់អង្រែ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

នៅក្នុងរបបសាធារណៈរដ្ឋខ្មែរ(សម័យលន់ នុល) ស្រុកច្បារអំពៅត្រូវបានប្តូរជាខណ្ឌច្បារអំពៅ ក្រុងភ្នំពេញ។ ក្រោយពីរំដោះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខណ្ឌច្បារអំពៅត្រូវប្តូរមកជាសង្កាត់ច្បារអំពៅវិញ ដែលមានភូមិចំណុះចំនួន៨រួមមាន៖ ភូមិច្បារអំពៅ១ ភូមិច្បារអំពៅ២ ភូមិព្រះពន្លា ភូមិព្រែកប្រា ភូមិបឹងឈូក ភូមិតាងៅ ភូមិឬស្សីស្រស់ និងភូមិកោះនរា។ ចំណែកត្រើយខាងលិចទន្លេក៏ត្រូវបានបង្កើតទៅជាសង្កាត់ចាក់អង្រែ សង្កាត់បឹងទំពន់ និងសង្កាត់ស្ទឹងមានជ័យ ។

រហូតដល់ឆ្នាំ១៩៨៦ ទីតាំងទាំងពីរខាងលើត្រូវបានបង្កើតទៅជាស្រុកមានជ័យ មានឃុំចំណុះចំនួន៨ ៖ ឃុំនិរោធ ឃុំច្បារអំពៅ១ ឃុំច្បារអំពៅ២ ឃុំព្រែកប្រា ឃុំចាក់អង្រែលើ ឃុំចាក់អង្រែក្រោម ឃុំបឹងទំពន់ (ត្រូវបានបង្កើតឡើងពីផ្នែកមួយនៃភូមិរបស់សង្កាត់ផ្សារដើមថ្កូវ) និងឃុំស្ទឹងមានជ័យនៅឆ្នាំ១៩៩៥ ស្រុកមានជ័យត្រូវបានរដ្ឋាភិបាលប្តូរទៅជាខណ្ឌមានជ័យវិញ ចំណែកឃុំចំណុះទាំង៨ ក៏ត្រូវបានប្តូរឈ្មោះមកជាសង្កាត់មកដល់បច្ចុប្បន្ន។

នៅឆ្នាំ២០១០រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញដោយកាត់យក សង្កាត់ចំនួន០៨ពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញ គឺសង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់ព្រែកប្រា សង្កាត់និរោធ សង្កាត់ព្រែកថ្មី សង្កាត់ក្បាលកោះ សង្កាត់ព្រែកឯង សង្កាត់វាលស្បូវ។[3] ហើយត្រូវបានផ្ទេរទីតាំងសាលាខណ្ឌមានជ័យ ដែលស្ថិតនៅក្នុងសង្កាត់ច្បារអំពៅទី១ ទៅឱ្យសាលាខណ្ឌច្បារអំពៅ។ សាលាខណ្ឌច្បារអំពៅត្រូវបានសម្ពោធឡើងជាផ្លូវការនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤។

- **ស្ថានភាពភូមិសាស្ត្រ** ៖ ខណ្ឌច្បារអំពៅស្ថិតនៅភូមិគ្រឹះលេខ០៣ ផ្លូវលេខ៣៦១ ភូមិព្រែក សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ។ សព្វថ្ងៃខណ្ឌច្បារអំពៅមានផ្ទៃដីសរុប៨០.៩៥ហិចតា ០.៨៥១ម$^{២}$ ក្នុងនោះរួមមានៈ ផ្ទៃដីកសិកម្ម ៣៨៩ហិចតា៨៥៥១ម$^{២}$។ មានព្រំប្រទល់ខាងជើងទល់នឹង ទន្លេមេគង្គ ស្រុកល្វាឯម ខេត្តកណ្តាល ខាងត្បូងទល់នឹង ទន្លេបាសាក់ ក្រុងតាខ្មៅ និងស្រុកស្អាង ខេត្តកណ្តាល ខាងលិចទល់នឹងទន្លេបាសាក់ ខណ្ឌមានជ័យ និងក្រុងតាខ្មៅ ខេត្តកណ្តាល ខាងកើតទល់នឹង

[3] មាត្រា១ នៃអនុក្រឹត្យ លេខ ៥៧៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ

ស្រុកកៀនស្វាយ ខេត្តកណ្តាល។[4] ខណ្ឌច្បារអំពៅមានទន្លេ២ គឺទន្លេបាសាក់ និងទន្លេមេគង្គក្រោម ដែលក្នុងនោះផ្ទៃទឹកមានព្រែកចំនួន ៥១ហិចតា ៧២ម$^{២}$។

- **ស្ថានភាពប្រជារាស្ត្រ** ៖ ប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌច្បារអំពៅមានចំនួន ៣០,៦៨៧គ្រួសារ ស្មើនឹងប្រជាពលរដ្ឋសរុបចំនួន១៥២,៧៥៨នាក់ ដែលក្នុងនោះមានស្រីចំនួន៨០,៣០១នាក់។ ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងចំនួន១០៥,៧៩១នាក់ ស្រី៥៤,៥០៤នាក់ ចំនួនប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត៩២,១២៦នាក់ អត្រាកំណើត៣.៤៣% ស្មើ ៤,៣០៦នាក់ ស្រី ២,១០០នាក់ អត្រាមរណភាព ០.៣១% ស្មើ៣៨៩នាក់ ស្រី១៦៤នាក់ ដង់ស៊ីតេប្រជាពលរដ្ឋ ១,៥៥៤នាក់/គម$^{២}$ ។[5]
- **ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច** ៖ មុខរបរប្រជាពលរដ្ឋក្នុងខណ្ឌច្បារអំពៅមានដូចជា៖ ១០% ជាអ្នករាជការ ៤៧%ជាអ្នកលក់ដូរ ២៧%ជាកម្មកររោងចក្រ និងកសិករ១៦%។ ភោជនីយដ្ឋានមានចំនួន១៥ទីតាំង រោងចក្រចំនួន១២ទីតាំង សិប្បកម្មចំនួ១៩១ទីតាំង ផ្សារសរុបចំនួន០៦ ទីតាំង( ផ្សាររដ្ឋ០៥ ផ្សារឯកជន០១ )។ធនាគារ និងមីក្រូហិរញ្ញវត្ថុ ១៦ (ធនាគារ១០, មីក្រូហិរញ្ញវត្ថុ ០៦ )ក្លឹបកម្សាន្តចំនួន០៩(ខារ៉ាអូខេ០៦,ឌីស្កូតែក០៣)។ សណ្ឋាគារ ផ្ទះសំណាក់ ចំនួន១៤ទីតាំង (សណ្ឋាគារ០៣, ផ្ទះសំណាក់១១)។ អាជាតមិនចំនួន០២ទីតាំង ទឹកស្អាតចំនួន០១ទីតាំង។ ការប្រមូលសម្រាមមានក្រុមហ៊ុនស៊ីវុទ្រីតនៅសង្កាត់និរោធ ច្បារអំពៅទី១ ច្បារអំពៅទី២ និងព្រែកប្រា និងរមណីយដ្ឋាន ចំនួន០១ទីតាំង(កៃថ្មៃ)។[6]
- **វិស័យអប់រំ** ៖ គ្រឹះស្ថានអប់រំរដ្ឋ វិទ្យាល័យ០៣, អនុវិទ្យាល័យ០៤, សាលាបឋមសិក្សា២០, សាលាមត្តេយ្យសិក្សា០៥ និងគ្រឹះស្ថានអប់រំឯកជន១៣។[7]
- **វិស័យសុខាភិបាល** ៖ មន្ទីរពេទ្យបង្អែក០២, មណ្ឌលសុខភាព០៤, គ្លីនិកឯកជន០២, ទីតាំងឱសថស្ថាន ឱសថស្ថានរង៣២ទីតាំង និងបន្ទប់ពិគ្រោះព្យាបាល និងមាត់ធ្មេញ៦១ទីតាំង ។[8]

---

[4] របាយការណ៍ស្រាវជ្រាវ សាលាខណ្ឌមានជ័យ ការបង្កើតខណ្ឌថ្មី ឆ្នាំ២០១៣

[5] សៀវភៅ "កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២០-២០២២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០"បានទទួលការអនុម័តពីក្រុមប្រឹក្សាខណ្ឌ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី៥

[6] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[7] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[8] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

- **វិស័យធម្មការ និងសាសនា** ៖ មានវត្តព្រះពុទ្ធសាសនាហិនយាន២៨វត្ត, វត្តធម្មយុត្តនិកាយ០១, វត្តវិហារព្រះពុទ្ធសាសនា មហាយាន១៥ទីតាំង, វិហារសាសនាឥស្លាម០១ទីតាំង, វិហារគ្រីស្តសាសនា ១៨ទីតាំង។[9]
- **អង្គការ សមាគមន៍** មានចំនួន២៤ទីតាំង ក្នុងនោះ អង្គការ១៩ទីតាំង, សមាគមន៍០៥ទីតាំង។[10]

### ១.១.១. មូលហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់

កត្តាដែលនាំឱ្យមានការរៀបចំក្រុងមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសន្និទានកម្ម ពោលគឺមានការគិតគូហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ។[11] ទន្ទឹមនឹងនេះ មុននឹងឈានដល់ការរៀបចំ ឬអភិវឌ្ឍន៍អ្វីមួយ គឺវាបណ្តាល មកពីភាពខ្វះចន្លោះ ដែលជាហេតុនាំកើតមានឡើងនូវបញ្ហាផ្សេងៗផងដែរ។ យ៉ាងណាមិញយើងក្រឡេកមើលទៅតាមបណ្តាតំបន់នានាដូចជា៖ ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ក្នុងប្រទេសនានា ក៏ដូចជាប្រទេសកម្ពុជារបស់យើង តែងតែមានការរៀបចំនូវគម្រោង ឬដាក់ផែនការសកម្មភាពអភិវឌ្ឍន៍នៅតាមតំបន់នានា ដែលកំពុងជួបនូវបញ្ហាខ្វះខាត ដែលនឹងត្រូវមានការរៀបចំឱ្យកាន់តែប្រសើរឡើងជាងមុន។ ជារួមការរៀបចំក្រុងដើម្បីឱ្យមានសណ្តាប់ធ្នាប់ សំដៅដល់ការរៀបចំរាជធានីដែលជាកន្លែងមួយមិនមានសកម្មភាពឱ្យមានភាពល្អ សន្តិសុខ ភាពស្ងប់ស្ងៀម និងអនាម័យ។ ដូច្នេះក្រុងកើតឡើងពុំមែនដោយសារកត្តាចៃដន្យនោះទេ គឺកើតឡើងដោយសារមូលហេតុជម្រុញពីក្រោយជាច្រើនដូចជា ៖

#### ១.១.១.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗ ៖ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារចំណាកស្រុកពីជនបទ និងកំណើនដោយសារ ការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ គឺពីឆ្នាំទៅមួយឆ្នាំមនុស្សចេះតែកើនឡើងដូច្នេះអត្រាកើតប្រជាពលរដ្ឋថ្មីនេះហើយក៏ជាចំនួនកំណើនប្រជាជននៅក្នុងទីក្រុង ស្ថិតទៅតាមកាលៈទេសៈពេលវេលាចេះតែទៅមុខ អត្រាមរណភាពភាគតិច ហើយអត្រាកើតក៏ច្រើនផងដែរ។ កំណើនដោយសារចំណាកស្រុកពីជនបទ គឺដោយសាររាជធានីភ្នំពេញជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្មផ្សេងៗ។ ដែលប្រមូលផ្តុំដោយរោងចក្រ សហគ្រាស ហេតុនេះទីក្រុង គឺជាទីផ្សារការងារដ៏ សម្បើមដែលធ្វើឱ្យប្រជាពលរដ្ឋនៅក្នុងស្រុកជនបទ ដែលមានការខ្វះខាតនៅការងារ ធ្វើជាហេតុនាំឱ្យពួកគេបានសម្រេចចិត្តចាកចេញពីទីលំនៅដ្ឋានរបស់ពួកគេ រៀងៗខ្លួនមកកាន់ទីក្រុង ដើម្បីស្វែងរកការងារ ធ្វើដើម្បីផ្គត់ផ្គង់ជីវភាពផងដែរ។ កំណើនដោយសារ

[9] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[10] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[11] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩-២០២០ ទំព័រទី៥

ការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទគឺកើតឡើងដោយសារសណ្ឋាន ដីទីក្រុងថ្មីដែលពីមុនគឺជាខេត្ត ឬជនបទ ។

- **កំណើនប្រជាជននៅថ្ងៃអនាគត៖** ចំនួនប្រជាជនពិភពលោក បានកើនឡើងដល់ចំនួន៦,១ពាន់លាននាក់ ក្នុងពាក់កណ្ដាលឆ្នាំ២០០០ទៅហើយ ដោយឡែកបច្ចុប្បន្នកំពុងកើនជាមធ្យមចំនួន៧,៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ខាងមុខ ចំនួនប្រជាជនពិភពលោក នឹងមានការកើនឡើងខ្លាំងនៅចន្លោះពីចំនួន៧,៩ ទៅ១០,៩លានពាន់នាក់។ បើទោះបីជាមានប្រទេសមួយចំនួនមានលេចចេញនូវអត្រាភាពនៃអត្រាមរណៈភាព ខ្ពស់ដោយសារតែ ជំងឺអេដស៍ក៏ដោយ ក៏កំណើនប្រជាជននៅតែខ្ពស់ដដែល។ យ៉ាងណាមិញ ចំនួនប្រជាជននៅ ក្នុងប្រទេសអភិវឌ្ឍនាពេលបច្ចុប្បន្ននេះ គឺមិនត្រូវបានគេរំពឹងថានឹងកើតឡើងក្នុងរយៈពេល៥០ឆ្នាំ ខាងមុខឡើយ ដោយសារតែកម្រិតនៃការមានកូនត្រូវបានគេដាក់ស្ថិតក្រោមកម្រិតកំណត់។ផ្ទុយទៅវិញចំនួនប្រជាជនក្នុងប្រទេស កំពុងអភិវឌ្ឍន៍ ត្រូវបានព្យាករណ៍ថានឹងកើនឡើងពី៤,៩ ពាន់លាននាក់នៅក្នុងឆ្នាំ២០០០ និងកើនឡើងដល់៨,២ ពាន់លាននាក់ក្នុងឆ្នាំ២០៥០។ កំណើនយ៉ាងឆាប់រហ័សនេះត្រូវបានគេរំពឹងថានឹង កើតឡើងក្នុងចំណោមក្រុម ប្រទេសអភិវឌ្ឍន៍ចំនួន៤៨ប្រទេស ដែលចំនួនប្រជាជនរបស់ពួកគេត្រូវបានរំពឹងថានឹងកើនឡើងជិតបីដងក្នុង៥០ ឆ្នាំខាងមុខ។ ចំណែកឯអន្តោប្រវេសន៍ អន្តរជាតិត្រូវបានព្យាករណ៍ថា នឹងមានកំណើន ដង់ស៊ីតេ ប្រជាជនខ្ពស់នៅ ក្នុងសតវត្សទី២១នេះ។[12]

### ១.១.១.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់ តែជាទូទៅភាពក្រីក្រសំដៅ ដល់ការដែលជាតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រ តាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការ រូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារធនធានទឹក អគ្គីសនី អនាម័យសុខភាពសង្គម មានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាព ផ្នែកស្មារតីនិយាយរួម សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។ការ សម្គាល់ពីភាពក្រីក្រត្រូវ បានសង្កត់ធ្ងន់លើចំណូលទាប របស់បុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា៖ ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់ តាមរយៈប្រាក់ចំណូលនេះឡើងដែលជាធម្មតា អ្នកដែលទទួលប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត ថាជនក្រីក្រ។ យ៉ាងហោចណាស់ជាង២០%នៃចំនួនប្រជាជនពិភពលោក រស់នៅក្នុងបន្ទាត់នៃក្រីក្រ៩០%ក្នុង ចំនួននេះកំពុងស្ថិតក្នុងប្រទេសអភិវឌ្ឍន៍។[13]

---

[12] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩-២០២០ ទំព័រទី៥

[13] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩-២០២០ ទំព័រទី៦

- **ភាពក្រីក្រនៅជនបទ**

ស្ថិតនៅបរិការណ៍នៃបច្ចុប្បន្នភាព ស្ថានភាពក្រីក្រនៃប្រទេសកំពុងអភិវឌ្ឍន៍ មានការកើនឡើងជាលំដាប់កំណើននេះអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជារាស្ត្រ ភូមិសាស្ត្រនយោបាយ គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅជនបទនាំឱ្យមានចំណាកស្រុកទៅទីក្រុងហើយចរន្តការនេះ នឹងកើនឡើងនៅពេលដែលស្ថានភាព នៅតំបន់កាន់តែលំបាក។ ដូច្នេះការបង្កើនសកម្មភាព សេដ្ឋកិច្ចនៅជនបទ ជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធិភាពជាទីបំផុត ដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកនេះ។

- **ភាពក្រីក្រនៅទីក្រុង**

កាលណាមានភាពក្រីក្រនៅក្នុងទីក្រុង គឺពិតជាមានបង្កផលពិបាកយ៉ាងខ្លាំង។ ជាទូទៅយើងពុំមាននូវលក្ខណៈសមភាពទេ កាលណាប្រសិនជាយើងធ្វើការប្រៀបធៀបពីភាពក្រីក្រ ដោយការដាក់បន្ទាត់មួយក្រិតឱ្យស្មើគ្នានោះ។ ឧទាហរណ៍ ការប្រើប្រាស់ថវិកា ៣លានដុល្លារសហរដ្ឋអាមេរិក ដូចគ្នា តែបុគ្គលម្នាក់នោះនៅជនបទចំណែកបុគ្គលម្នាក់ទៀតនៅទីក្រុងមិនអាចស្មើគ្នាទេនៅក្នុងការចំណាយលុយ។ មូលហេតុគឺដោយសារនៅក្នុងទីក្រុងមានការចំណាយខ្ពស់ជាងជនបទដាច់ឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះ អ្នករស់នៅតាមជនបទអាចមានឱកាសស្វែងរកការចិញ្ចឹមជីវិត តាមរយៈការទទួលអំណោយ ភោគផល ពីធម្មជាតិច្រើនជាងអ្នកនៅក្នុងទីក្រុង។[14] ជារួមប្រសិនបើមានភាពក្រីក្រនៅក្នុងទីក្រុងហើយ អាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវតែបង្កើតឱ្យមានសេវាកម្មគ្រប់វិស័យ ដើម្បីទាក់ទាញឱ្យអ្នកវិនិយោគនានា បង្កើតគ្រឹះស្ថាន រោងចក្រ សហគ្រាស ឬសេវាកម្មផ្សេងៗនៅក្នុងទីក្រុងដើម្បីឱ្យប្រជាពលរដ្ឋ នៅក្នុងទីក្រុងមានការងារធ្វើ ហើយក៏បានជួយដល់ប្រជាជនដែលរស់នៅទីជនបទកំពុងជួបនូវភាពក្រីក្រខ្វះខាតនូវការងារធ្វើ បានទទួលនូវការងារធ្វើផងដែរ។ ដូច្នេះភាពក្រីក្រនេះក៏ជាមូលហេតុមួយដែលនាំឱ្យមានការរៀបចំក្រុង។

### ១.១.១.៣. ចរាចរណ៍

បញ្ហាចរាចរណ៍ គឺជាកត្តាមួយដែលនាំឱ្យមានការរៀបចំក្រុង និងនាំឱ្យប្រទេសជាតិមានការអភិវឌ្ឍជឿនលឿនទៅមុខជាលំដាប់ផងដែរ។ កាលណាប្រទេសមួយមានបញ្ហាកកស្ទះចរាចរណ៍នៅក្នុងទីក្រុងហើយពិតណាស់វានាំឱ្យមានគុណវិបត្តិសម្រាប់ប្រជាពលរដ្ឋ ដូចជាខាតបង់សេដ្ឋកិច្ច ប៉ះពាល់សុខភាពមិនគោរពច្បាប់ចរាចរណ៍ ថែមទាំងមានផលប៉ះពាល់ទៅដល់បរិស្ថាន តាមរយៈផ្សែងបំពង់ស៊ីម៉ាំងម៉ូតូ រថយន្ត រថយន្តក្រុង រថយន្តដឹកទំនិញផ្សេងៗ។ មិនតែប៉ុណ្ណោះនៅពេលដែលមានការកកស្ទះចរាចរណ៍នោះម៉ូតូ និង

[14] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩-២០២០ ទំព័រទី៧

រថយន្ត គឺម៉ាស៊ីនមានការបញ្ចោះរហូតដោយមិនអាចពន្លត់បាន។ ជាក់ស្តែងបញ្ហាកកស្ទះចរាចរណ៍ នៅក្នុងទីក្រុងកើតចេញមកពីកត្តាបីយ៉ាង ៖

- **កត្តាមនុស្ស** ៖ មនុស្សកើនឡើងច្រើន, មនុស្សប្រើប្រាស់មធ្យោបាយធ្វើដំណើរតាមដងផ្លូវរៀងៗខ្លួនដែលបណ្តាលឱ្យមានការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍។ ហើយគ្រោះថ្នាក់ចរាចរណ៍របស់មនុស្សទៀតសោត កើតចេញពីការមិនគោរពច្បាប់ មិនគោរពភ្លើងសញ្ញា ស្លាកសញ្ញា បើកបរមិនយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកជាដើម។
- **កត្តាយានយន្ត** ៖ នៅក្នុងប្រទេសកម្ពុជាសំបូរទៅដោយយានយន្តមួយទឹកៗ មកពីក្រៅប្រទេសលក់សម្រាប់ប្រជាពលរដ្ឋ ប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរ នេះក៏ជាហេតុនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងខ្លាំងផងដែរ។
- **កត្តាផ្លូវ** ៖ មិនទាន់ឆ្លើយតបទៅតាមតម្រូវការ (ទីរួមខេត្ត និងក្រុង) ផ្លូវពុំមានស្តង់ដារ (មានលក្ខណៈតូច ផ្លូវជួសជុលច្រើនដង មិនមានផ្លូវអាកាស មិនមានស្ពានសម្រាប់អ្នកថ្មើរជើង)។

ជាក់ស្តែងនៅក្នុងឆ្នាំ២០១៧ មានរថយន្តគ្រប់ប្រភេទសរុបចំនួន ៤៤២.៩៧១គ្រឿង និងទោចក្រយានយន្តគ្រប់ប្រភេទមានចំនួន ១.៦០១.៤៥១គ្រឿង។ ប្រជាពលរដ្ឋមានរហូតដល់ចំនួន ១,៧លានាក់។ ក្រៅពីបញ្ហាការកើនឡើងនៃយានយន្ត ហេដ្ឋារចនាសម្ព័ន្ធផ្លូវក៏មានបញ្ហាចោទដែលនាំឱ្យមានការកកស្ទះចរាចរណ៍ផងដែរ ដោយសារផ្លូវក្នុងក្រុងមានភាពទ្រុឌទ្រោម និងតូចចង្អៀតពិបាកធ្វើដំណើរ មានការប្រេះស្រាំ ខ្វះការថែទាំ រថយន្តដឹកទំនិញលើសទម្ងន់ យកផ្លូវថ្នល់ជាចំណត ប្រជាពលរដ្ឋខ្វះការយល់ដឹងពីការអនុវត្តច្បាប់ចរាចរណ៍ និងមានខ្វះខាតនូវភ្លើងបំភ្លឺគ្រប់ផ្លូវ និងច្រកផ្លូវជាច្រើន។ ដូច្នេះហើយកត្តាទាំងអស់នេះជាហេតុនាំឱ្យមានការរៀបចំក្រុងដើម្បីជាភាពងាយស្រួលដល់ប្រជាពលរដ្ឋ ជាពិសេសភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិផងដែល។

#### ១.១.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីធានាដល់ការរស់នៅមានការការពារសុវត្ថិភាព ដល់ប្រជាពលរដ្ឋអាជ្ញាធរគ្រប់ជាន់ថ្នាក់នៅក្នុងខេត្ត-ក្រុងត្រូវយកចិត្តដាក់ជាខ្លាំង នូវការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ ដែលអនុវត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផែនការណែនាំស្តីពី ការចាប់តាំងអនុវត្តគោលនយោបាយ “ ភូមិ-ឃុំ ” មានសុវត្ថិភាព ក្នុងនោះមានគណៈបញ្ជាការឯកភាពរដ្ឋបាលទាំងថ្នាក់ខណ្ឌសង្កាត់ ដែលនឹងកំពុងអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពធានានូវមានលក្ខណៈ សម្បត្តិ៥យ៉ាង។ នៅក្នុងឆ្នាំ២០២១នាពេលបច្ចុប្បន្នរាជរដ្ឋាភិបាល បានរៀបចំកែលម្អលក្ខណៈសម្បត្តិគោលនយោបាយ“ ភូមិ-ឃុំ-សង្កាត់ ” មានសុវត្ថិភាព បន្ថែមរហូតដល់៧ចំណុចដូចជា ៖

- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- ផ្តល់សេវាសាធារណៈជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី កុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
- មានសណ្តាប់ធ្នាប់ល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
- ដោះស្រាយវិធានការនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធិភាព
- មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ
- ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងជំងឺឆ្លងរាលត្បាតកាចសាហាវប្រកបដោយប្រសិទ្ធិភាព។[15]

ចំពោះការអនុវត្តនូវគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់" ក្នុងគោលបំណងបន្តកសាង និងពង្រឹងការពារនូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ទាំងផ្លូវកាយ ផ្លូវចិត្ត លើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងគ្រប់គ្រង ទប់ស្កាត់ កាត់បន្ថយគ្រោះមហន្តរាយ និងជម្ងឺរាលត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅតុលាការ នៅក្នុងភូមិ-ឃុំ-សង្កាត់។ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើតល្បឿននៃកាត់បន្ថយភាពក្រីក្រ។

បន្ថែមពីនេះទៅទៀតនោះ កសាងកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់" មានសុវត្ថិភាព ឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋទូទាំងប្រទេស។

**១.១.២.រចនាសម្ព័ន្ធខណ្ឌច្បារអំពៅ**

អនុលោមតាមប្រកាសលេខ ៣៤៨ ប្រ.ក ចុះនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ភារកិច្ច របៀបការងារ និងរចនាសម្ព័ន្ធនៃសាលាស្រុក ខណ្ឌ បានចែងថា ស្រុក ខណ្ឌនីមួយៗ ត្រូវដឹកនាំដោយ អភិបាល ស្រុក ខណ្ឌ ០១រូប អមដោយអភិបាលរងស្រុក ខណ្ឌ០៣រូប ជាជំនួយការ ប៉ុន្តែដោយសារតែរាជធានីភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងមហាផ្ទៃបានបន្ថែមអភិបាលរងខណ្ឌ ០១រូបទៀត ឱ្យទៅបំពេញការងារតាមខណ្ឌទាំងអស់០៧ របស់រាជធានីភ្នំពេញ។

[15] គេហទំព័រ https://www.interior.gov.kh/news/detail/2225 ដកស្រង់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១

ដោយឡែកនៅក្នុងខណ្ឌច្បារអំពៅ គឺមាននូវអភិបាលខណ្ឌ០១រូប អមដោយអភិបាលរងចំនួន០៤រូប។[16] អភិបាលខណ្ឌទទួលខុសត្រូវរួមលើកិច្ចរដ្ឋបាលដែនដី និងទទួលបន្ទុកផ្ទាល់លើកិច្ចការសន្តិសុខនិង សណ្ដាប់ធ្នាប់សាធារណៈក្នុងខណ្ឌរបស់ខ្លួន។ ចំណែកអភិបាលរងខណ្ឌ០១រូប ទទួលបន្ទុកការងាររដ្ឋបាលទូទៅ ០១រូប ទទួលបន្ទុកការងារសង្គមកិច្ច និង០១រូបទៀត ទទួលបន្ទុកការងារសេដ្ឋកិច្ចគ្រប់គ្រងដោយប្រធាន០១រូបហៅថា ប្រធានមន្ទីរខណ្ឌ អមដោយ អនុប្រធាន០១រូបជាជំនួយការ។ ប្រធានមន្ទីរខណ្ឌត្រូវបានបំពេញការងារ ក្រោមការដឹកនាំអភិបាលរងខណ្ឌក្នុងការដឹកនាំសម្របសម្រួលការងារនានាចំណុះសាលាខណ្ឌ។ អនុប្រធានមន្ទីរមានភារកិច្ច ជំនួយការឱ្យប្រធានមន្ទីរខណ្ឌ អនុវត្តការងារតាមការប្រគល់ភារកិច្ចរបស់ប្រធានមន្ទីរខណ្ឌ និង ជំនួយមន្ទីរខណ្ឌពេលអវត្តមាន។

### ១.១.២.១. ក្រុមប្រឹក្សាខណ្ឌ




❖ **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- គ្រប់គ្រង និងថែរក្សារដ្ឋបាលខណ្ឌតាមការកំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន

[16] ប្រកាសលេខ៣៤៨ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ស្ដីពី តួនាទីភារកិច្ច របៀបរបបការងារ របស់ក្រសួងមហាផ្ទៃ

- ការងារ បុគ្គលិក ក្រមខណ្ឌ ប្រវត្តិរូប និងកម្រៃផ្សេងៗរបស់មន្ត្រីបុគ្គលិកសាលាខណ្ឌ
- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងារមន្ត្រី បុគ្គលិកសាលាខណ្ឌ
- ការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិសាលាខណ្ឌ
- សិក្សាលើកយោបល់លើការបង្កើត កែសម្រួល និងការរំសាយ ការិយាល័យចំណុះសាលាខណ្ឌ
- ការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីបុគ្គលិកសាលាខណ្ឌ
- រៀបចំសេចក្តីព្រាង របៀបវារៈ ខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាសាលាខណ្ឌ
- រៀបចំ និងបែងចែកលិខិតប្រជុំ ការរៀបចំទីកន្លែងប្រជុំ កំណត់គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌ
- ទទួល និងការបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវទៅដល់សមាជិកក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌ អភិបាលរងខណ្ឌ និងរដ្ឋបាលខណ្ឌព្រមទាំងក្រសួងស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារលិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាល និងរដ្ឋបាលខណ្ឌ
- រៀបចំ និងបិទផ្សាយពត៌មានលើក្តារព័ត៌មាន ស្វះស្វែងរកមធ្យោបាយ ស្វែងមធ្យោបាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងខណ្ឌ
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ នៅតាមសង្កាត់នានាក្នុងខណ្ឌ
- ជម្រុញ និងអនុវត្តកិច្ចការពាក់ព័ន្ធ ការបញ្ច្រៀបយេនឌ័រ និងបង្កើនសិទ្ធិអំណាចស្ត្រី
- អនុវត្តនូវកិច្ចការផ្សេងៗទៀតតាមការប្រគល់របស់នាយករដ្ឋបាលរបស់សាលាខណ្ឌ និងតាមការកែតម្រូវរបស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[17]

❖ **ការិយាល័យផែនការ និងអភិវឌ្ឍន៍**

- រៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគដើម្បីបញ្ចូលនៅក្នុងផែនការអភិវឌ្ឍរយៈពេល**០៥(ប្រាំ) ឆ្នាំ** កម្មវិធីវិនិយោគរយៈពេល**០៣(បី)ឆ្នាំ** រំកិលប្រចាំឆ្នាំរបស់រាជធានីភ្នំពេញ
- អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍនានារបស់សាលាខណ្ឌ សិក្សាវាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាសង្កាត់

[17] សៀវភៅ ការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦៤

- តម្រូវការគាំទ្រ ដើម្បីដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់នីមួយៗក្នុងខណ្ឌ
- ការសម្របសម្រួល និងគាំទ្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងផ្តល់សេវា ក្នុងចំណោមសង្កាត់នីមួយៗក្នុងខណ្ឌ
- កិច្ចការផ្សេងៗដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាននានាដែលតម្រូវដោយក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ។[18]

❖ **ការិយាល័យអន្តរវិស័យ**

- ការងារដីធ្លី និងសំណង់
- ការងារសេដ្ឋកិច្ច (ពាណិជ្ជកម្ម កសិកម្ម ទេសចរណ៍)
- ការងារសង្គមកិច្ច
- ការងារវប្បធម៌ សាសនា
- ការងារបរិស្ថាន កាកសំណល់ អនាម័យ សួនច្បារ
- ការងារសាធារណៈការ
- ការងារទទួលពាក្យបណ្តឹង
- ការងារសម្របសម្រួល
- ការងារព័ត៌មាន
- ការងារវប្បធម៌
- បញ្ជូនបន្ត
- ការងារលទ្ធកម្ម
- ការងារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗ
- ការងារផ្សព្វផ្សាយលទ្ធកម្មនៃការដេញថ្លៃ
- សេចក្តីព្រាងកិច្ចសន្យាទៅតាមអនុលោមបទដ្ឋាន និងគំរូកិច្ចសន្យា
- តាមដាន និងទូទាត់នៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ និងអ្នកទទួលការ ឬទីប្រឹក្សា
- តាមដានរបាយការណ៍ស្តីពីកិច្ចការលទ្ធកម្ម ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- កិច្ចការច្បាប់ និងសិទ្ធិមនុស្ស ការរំលោភច្បាប់ ការដោះស្រាយវិវាទនៅមូលដ្ឋាន។[19]

[18] សៀវភៅ ការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦៥
[19] សៀវភៅ ការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦៦

### ១.១.២.២. គណៈអភិបាលខណ្ឌ




សាលាខណ្ឌច្បារអំពៅ គឺត្រូវបានដឹកនាំដោយអភិបាលខណ្ឌចំនួន០១រូប និងអមអភិបាលរងចំនួន០៤រូប។ នៅក្នុងសាលាខណ្ឌច្បារអំពៅគណៈអភិបាល និងអភិបាលរងចំនួន០៤រូបត្រូវទទួលបន្ទុកដូចជា ៖

❖ **គណៈអភិបាលខណ្ឌច្បារអំពៅ**

- ដឹកនាំការងាររួម
- ដឹកនាំផ្ទាល់លើកិច្ចការទូទៅ
- ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ

ចំណែកឯអភិបាលរងខណ្ឌ ០៤រូបទៀតទទួលបន្ទុកការងារមួយយចំនួនមានដូចខាងក្រោម ៖

❖ **អភិបាលរងខណ្ឌ ០១រូប ទទួលបន្ទុកលើការងារការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

- កិច្ចការអប់រំយុវជន និងកីឡា
- កិច្ចការព័ត៌មាន
- កិច្ចការស្ថិតិ និងអគ្រានុកូលដ្ឋាន
- កិច្ចការនារី កុមារ និងសុខាភិបាល
- ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
- កិច្ចការវេទិកាសាធារណៈ ហិរញ្ញវត្ថុ
- កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កិច្ចការធនាគារ និងរតនាគារ រដ្ឋបាល ពន្ធដារ សាខាកាំកុងត្រូល

- កិច្ចការសាខាគយ រដ្ឋាករខណ្ឌ
- កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍
- កិច្ចការអង្គការក្រៅរដ្ឋាភិបាល

❖ **អភិបាលរងខណ្ឌ ០១រូប ទទួលបន្ទុកលើការងារការិយាល័យផែនការ និងអភិវឌ្ឍន៍**

- កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- កិច្ចការវិនិយោគ និងពាណិជ្ជកម្ម
- កិច្ចការអភិវឌ្ឍជនបទ និងអង្គភាពអគ្គិសនី
- កិច្ចការលទ្ធកម្ម
- កិច្ចការសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ សហគមន៍ សមាគមន៍
- កិច្ចការកម្មវិធី ផែនការអភិវឌ្ឍ ០៣ឆ្នាំរំកិលខណ្ឌ
- កិច្ចការគ្រប់គ្រងផ្សាររដ្ឋ និងផ្សារឯកជន
- កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ
- កិច្ចការរ៉ែ ថាមពល
- កិច្ចការបរិស្ថាន និងគ្រប់គ្រង សំណល់រឹង និងរាវ
- កិច្ចការសាធារណការ និងដឹកជញ្ជូន

❖ **អភិបាលរងខណ្ឌ ០១រូប ទទួលបន្ទុកលើការងារការិយាល័យអន្តរវិស័យ**

- កិច្ចការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាលខណ្ឌ
- កិច្ចការសហការអនុវត្តសេចក្តីសម្រេចរបស់តុលាការ
- កិច្ចការពាណិជ្ជកម្ម និងទទួលជួយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កិច្ចការគ្រោះមហន្តរាយ
- កិច្ចការការិយាល័យច្រកចេញចូលតែមួយ
- កិច្ចការការិយាល័យអនុសាខាកាកបាទក្រហម
- កិច្ចការធម្មការ និងសាសនា។

❖ **អភិបាលរងខណ្ឌ ០១រូប ទទួលបន្ទុកលើការងារការិយាល័យអន្តរវិស័យ**

- កិច្ចការទេសចរណ៍
- កិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ
- កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុទនីតិសម្បទា

- កិច្ចការឧស្សាហកម្ម និងសិប្បកម្ម
- កិច្ចការគ្រប់គ្រងទីតាំងយានយន្ត និងយានដ្ឋានជុសជុសរថយន្ត
- ការដោះស្រាយបាតុកម្ម កូដកម្ម និងការងារគ្រប់គ្រងផ្ទះជួល។[20]

## ១.២. បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់ខណ្ឌច្បារអំពៅ

### ១.២.១.បច្ចុប្បន្នភាពនៃការរៀបចំសណ្តាប់ធ្នាប់

ខណ្ឌច្បារអំពៅ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅក្បែរទីក្រុងភ្នំពេញផងនោះ ជាហេតុនាំឱ្យមានប្រជាពលរដ្ឋរស់នៅប្រកបរបរច្រើនប្រភេទ។ ជាងនេះទៅទៀតក្នុងខណ្ឌច្បារអំពៅ ក៏ឃើញថាបច្ចុប្បន្នសំបូរទៅដោយសំណង់អគារខ្ពស់ៗ បុរី លំនៅដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន សួនច្បារតាមដងផ្លូវ មណ្ឌលពាណិជ្ជកម្ម ផ្សារទំនើបសង់អមសងខាងផ្លូវដងវិថីតូចធំខ្វាត់ខ្វែងអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលមកទស្សនា និងទិញទំនិញគ្រប់ប្រភេទ។ ក្រៅពីនេះទៅទៀតខណ្ឌច្បារអំពៅ ហាក់បីដូចជាទីក្រុងមួយដែលសំបូរទៅដោយកន្លែងកំសាន្ត លំហែកាយ របស់ប្រជាពលរដ្ឋ ព្រមទាំងមានការតាំងលក់នូវទំនិញប្រើប្រាស់ទំនើបៗ និងភោជនីយដ្ឋានដ៏សំបូរបែបទៀតផង។ មិនតែប៉ុណ្ណោះនៅមានសំណង់អគារតូចធំ របស់ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជន អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលបោះទីតាំងនៅក្នុងសង្កាត់ទាំង០៨របស់ខណ្ឌច្បារអំពៅ និងបង្កឱ្យមានលក្ខណៈងាយស្រួយដល់ការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបនូវតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននិងសំណូមពររបស់ប្រជាពលរដ្ឋ។

#### ១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

បណ្តាហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌច្បារអំពៅមានដូចជា កសាងផ្លូវ ប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងកសាងស្ពាន។ ការកសាងផ្លូវ ប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និង ការកសាងស្ពាន ពិតជាមានសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងខណ្ឌនោះ មានភាពងាយស្រួលក្នុងការធ្វើដំណើរ និងងាយស្រួលប្រកបអាជីវកម្ម បន្ថែមពីនេះធ្វើឱ្យខណ្ឌច្បារអំពៅមានសណ្តាប់ធ្នាប់ និងជួយកាត់បន្ថយការកកស្ទះលូ និងកកស្ទះចរាចរណ៍នៅតាមដងផ្លូវបានមួយចំណែកធំ។

- **ការកសាងផ្លូវ**

ការអនុវត្តគម្រោងកសាងផ្លូវនាពេលបច្ចុប្បន្ននេះ បាននាំមកនៅការអភិវឌ្ឍជាច្រើនដោយបានការកាត់បន្ថយការរាំងស្ទះចរាចរណ៍ ដល់ប្រជាពលរដ្ឋបានមួយកម្រិតបន្ថែមទៀត ពីព្រោះនាពេលបច្ចុប្បន្ននៅក្នុងខណ្ឌមានការកើនឡើង កំណើនប្រជាជន និងកំណើនការសាងសង់លំនៅដ្ឋានជាច្រើន បន្ថែមពីនេះមានការកើនឡើងនូវមធ្យោបាយធ្វើដំណើរដូចជាយានយន្ត និងយានជំនិះផ្សេងៗនៅក្នុងខណ្ឌច្បារអំពៅនេះ។

[20] សៀវភៅ ការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦០

- ស្ថាបនាផ្លូវបេតុងរួមមាន៤ខ្សែ ក្នុងនោះសង្កាត់ព្រែកប្រា មាន២ខ្សែ ដោយខ្សែទី១ ក្នុងក្រុមទី១ និងក្រុមទី៦ ភូមិព្រះពន្លា និងក្រុមទី៧ ភូមិជ្រោយបាសាក់ មានប្រវែង៥៣ម៉ែត្រ ទំហំទទឹង៧ម៉ែត្រ ប្រវែង៦៧ម៉ែត្រ ទទឹង៥ម៉ែត្រ និងប្រវែង២៤៧ម៉ែត្រ ទទឹង៦ម៉ែត្រ និងខ្សែទី២ ផ្លូវក្នុង បុរីជ្រោយបាសាក់ ប្រវែង៦១ម៉ែត្រ និង ទទឹង៥ម៉ែត្រ ប្រវែង៨ម៉ែត្រ ។
- ស្ថាបនាផ្លូវបេតុង៦ខ្សែ មានប្រវែងសរុប៩៣៧ម៉ែត្រ នៅក្នុងភូមិតាងៅ ភូមិតាងៅក្រោម ភូមិឫស្សីស្រស់ ភូមិកោះនរា និង ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ។[21]
- ជួសជុលផ្លូវលេខ១១០ស្ថិតនៅក្នុងសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ។[22]
- ស្ថាបនាផ្លូវបេតុង ២ខ្សែ មានប្រវែងសរុប ៦២៩ម៉ែត្រ ក្នុងនោះខ្សែទី១ មានប្រវែង ៣៤៧ម៉ែត្រ ទទឹង៥ម៉ែត្រ ស្ថិតក្នុងភូមិព្រែកជាងព្រហ្ម និងខ្សែទី២ មានប្រវែង២៨២ម៉ែត្រ ទទឹង៤ម៉ែត្រ ស្ថិតក្នុងភូមិក្ដីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ។[23]
- ជួសជុលផ្លូវបេតុងគ្មានសរសៃដែកប្រវែង៣៧០ម៉ែត្រ ទទឹង៥ម៉ែត្រ ស្ថិតនៅក្នុងភូមិព្រែកតាពៅ និងភូមិព្រះពន្លារ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ ។[24]
- ស្ថាបនាផ្លូវបេតុង មួយខ្សែស្របតាមប្រាំងទន្លេខាងកើត ចាប់ពីស្ពានព្រះមុនីវង្សចាស់ ហូតដល់តំបន់អភិវឌ្ឍន៍កោះនរា។[25]

### ❖ ការកសាងប្រព័ន្ធលូបង្ហូរទឹក

ខណ្ឌច្បារអំពៅមានការស្ថាបនាប្រព័ន្ធបង្ហូរទឹក ដើម្បីកាត់បន្ថយនូវការជន់លិចដែលបណ្ដាល មកពីការស្ទះលូ មានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋផងដែរ ដូច្នេះខណ្ឌបានយកចិត្តទុកដាក់ ដោយធ្វើការស្ថាបនាប្រព័ន្ធថ្មីៗនៅតាមសង្កាត់នីមួយៗនៅក្នុងខណ្ឌ និងជួសជុលនូវលូចាស់ៗ ដើម្បីជាភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់មួយចំនួន ដោយគ្មានការបារម្ភភ័យខ្លាចនូវការកកស្ទះប្រព័ន្ធលូ និងជន់លិចទឹកបន្តទៀត ចំពោះការស្ថាបនាប្រព័ន្ធប្រឡាយទាំងនោះមានដូចខាងក្រោម ៖

- មានការកសាងប្រព័ន្ធលូបង្ហូរទឹកនៅក្នុងសង្កាត់ព្រែកថ្មី សង្កាត់ព្រែកប្រា សង្កាត់និរោធ ដែលមានទំហំ ១,៥ម៉ែត្រ។[26]

---

[21] គេហទំព័រ http://nokorwatnews.com/archives/455772?fbclid=IwAR ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

[22] គេហទំព័រ មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី បានចុះគ្រឿងចក្រជួសជុលផ្លូវលេខ១១០ ក្នុងខណ្ឌច្បារអំពៅ | សាលារាជធានីភ្នំពេញ (phnompenh.gov.kh) ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

[23] គេហទំព័រ https://www.cpp.org.kh/details/161552?fbclid=IwAR ដកស្រង់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១

[24] គេហទំព័រ http://nkdnews.com/archives/297182?fbclid=IwAR ដកស្រង់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១

[25] គេហទំព័រ https://cambodiapropertyreport.com/article/4132?fbclid=IwAR ដកស្រង់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

[26] គេហទំព័រ http://news.ctv8.com.kh/2018/77052/?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

- មានការសាងសង់ដាក់លូរំដោះទឹក៣ខ្សែ ប្រវែង២៣៥ម៉ែត្រ នៅក្នុងភូមិ តាងៅ ភូមិតាងៅក្រោម ភូមិឫស្សីស្រស់ ភូមិកោះនរា និង ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ ។[27]
- មានការសាងសង់ប្រព័ន្ធលូរំដោះទឹកប្រវែង៥៩៦ម៉ែត្រ មុខកាត់០,៨ម៉ែត្រ ស្ថិតនៅក្នុងភូមិព្រែកតាពៅ និងភូមិព្រះពន្លារ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ។[28]
- មានការសាងសង់ប្រព័ន្ធលូទំហំ មុខកាត់ទំហំ៦តឹក ស្ថិតនៅក្នុងសង្កាត់ច្បារអំពៅ២ ដើម្បីបង្ហូរទឹកទាន់ពេលភ្លៀងខ្លាំងម្តងៗ និងងាយស្រួលធ្វើដំណើរ។[29]

❖ **ការដាក់បង្គោលភ្លើងបំភ្លឺសាធារណៈ**

ក្នុងខណ្ឌច្បារអំពៅមានការរៀបចំដាក់បង្គោលភ្លើងបំភ្លឺ នៅតាមដងផ្លូវសាធារណៈនានា ដើម្បីជួយសម្រួលដល់ការបើកបររបស់ប្រជាពលរដ្ឋនានាពេលរាត្រី ប្រកបដោយសុវត្ថិភាពនៅលើដងផ្លូវមានដូចជា ៖

- មានការរៀបចំដាក់បង្គោលភ្លើង ចំនួន២២៨ដើម តាមដងផ្លូវជាតិលេខ១ចាប់ពីខណ្ឌច្បារអំពៅរហូតដល់ស្រុកកៀនស្វាយ ខេត្តកណ្តាល រាជធានីភ្នំពេញ និងអំពូលភ្លើងបំភ្លឺ ចំនួន២២០ដើម ចាប់ពីព្រំប្រទល់សង្កាត់វាលស្បូវ និងសង្កាត់និរោធ ទៅដល់ព្រំប្រទល់សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ។[30]
- មានការរៀបចំដាក់ភ្លើងស្តុបជំហ៊ានទី១ដាក់ចំនួន៥គោលដៅ ដោយចាប់ផ្តើមអនុវត្តគម្រោងចាប់ពីផ្លូវបំបែកជាបួនរវាងផ្លូវលេខ៣៦៣ កែងជាមួយផ្លូវជាតិលេខ១ គល់ស្ពានព្រះមុនីវង្សត្រើយខាងកើតរហូតទៅដល់ផ្លូវបំបែកជា៤ច្រកចូលបុរីប៉េងហួតផ្នែកខាងកើត ឆ្លងកាត់ទៅផ្លូវចូលដេប៉ូអេតចាយក្នុង ភូមិបឹងស្នោ សង្កាត់និរោធ។[31]
- មានការរៀបចំដាក់បង្គោលភ្លើងស្តុបផ្លូវជាតិលេខ១ នៅច្បារអំពៅ ដែលត្រូវបានរថយន្តបុកនោះ ពេលនេះត្រូវបានជួសជុល និងដាក់ឱ្យដំណើរការវិញហើយ ។[32]
- មានការរៀបចំដូរបង្គោលភ្លើងថ្មី នៅលើស្ពានមុនីវង្សចាស់ ។[33]
- មានការរៀបចំភ្លើងបំភ្លឺផ្លូវ៤ភូមិ ភូមិក្តីតាកុយ ភូមិវាលស្បូវ សង្កាត់វាលស្បូវ និងភូមិជ្រោយបាសាក់ ភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ ។[34]

---

[27] គេហទំព័រ http://nokorwatnews.com/archives/455772?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[28] គេហទំព័រ http://nkdnews.com/archives/297182?fbclid=IwAR3SMLNiFgCvcc9jnBk ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[29] គេហទំព័រ http://news.ctv8.com.kh/2019/102854/ ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[30] គេហទំព័រ http://nokorwatnews.com/archives/356964 ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[31] គេហទំព័រ http://nokorwatnews.com/archives/341058?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[32] គេហទំព័រ https://news.kohsantepheapdaily.com.kh/article/746796.html?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[33] គេហទំព័រ https://mpwt.gov.kh/kh/press/16268?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

[34] គេហទំព័រ http://nokorwatnews.com/archives/483731?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកកក្កដា ឆ្នាំ២០២១

❖ **ការកសាងស្ពាន**

ស្ពាន គឺជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ ព្រមទាំងជាមធ្យោបាយដ៏សំខាន់ក្នុងការដឹកជញ្ជូន ដែលបម្រើដល់វិស័យសេដ្ឋកិច្ចបានមួយផ្នែកធំ។ ក្នុងនោះផងដែរ ខណ្ឌច្បារអំពៅក៏មានស្ពានចំនួន២ ដែលភ្ជាប់ទៅខណ្ឌសព្វថ្ងៃមានដូចជា ស្ពានព្រះមុនីវង្សចាស់ ស្ពានព្រះមុនីវង្សថ្មី។

ក្នុងនោះផងដែរ ស្ពានដែលជាបន្ទុករបស់ខណ្ឌច្បារអំពៅគឺ ស្ពានព្រះមុនីវង្សចាស់មានឈ្មោះជាភាសាអង់គ្លេស GUSTAVE EIFFEL ដែលប្រជារាស្ត្រខ្មែរយើងសម័យមុន មានឈ្មោះស្ពានជ្រោយអោក បានកសាងពីឆ្នាំ១៩៨៥ លុះមកដល់ឆ្នាំ១៩៦៤ មានការទ្រុមទ្រោមយ៉ាងខ្លាំង។ ដោយស្ពាននេះបានសាងសង់ឡើងវិញរួមប្រារព្ធធ្វើសម្ពោធនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៦៦។ ស្ពានព្រះមុនីវង្ស គឺជាស្ពានមួយនៅភ្នំពេញដែលមានចរាចរណ៍មមាញឹក។ ស្ពាននេះមានប្រវែង២៦៩ម៉ែត្រ ទទឹង២គុណ១៤ម៉ែត្រ តភ្ជាប់ច្រាំងខាងលិច ដែលចុងបញ្ចប់នៃផ្លូវជាតិលេខ២ ឆ្លងកាត់ទន្លេបាសាក់ ទៅកាន់ច្រាំងខាងកើតដែលមាន ផ្លូវជាតិលេខ១ ជាច្រកឆ្ពោះទៅខេត្តចំនួននៃភាគខាងកើតប្រទេស ក៏ដូចជាទៅកាន់ប្រទេសវៀនណាម។

- ជួសជុលស្ពាន និងជួសជុលបង្កាន់ដៃស្ពាន និងផ្លូវថ្មើរជើង អ៊ុតកៅស៊ូ តួស្ពានព្រះមុនីវង្សចាស់សរុបប្រវែងទទឹង១១ម៉ែត្រ ។[35]
- ស្ថាបនាស្ពានឆ្លងពីកោះនរា ការបុកគ្រឹះសសរស្ពានបាន៤០ភាគរយ ចាក់ខ្សាច់ការពារកោះនរាបានប្រមាណ៦០ភាគរយ ការសាងសង់ស្ពានមានចំនួន២គឺស្ពានទី១ ចេញពីកោះនរា ឆ្ពោះទៅកោះពេជ្រមានទទឹង២៤.៥ម៉ែត្រ និងបណ្តោយ៦៤៦ម៉ែត្រ។
- ស្ថាបនាស្ពានទី២គឺតភ្ជាប់ពី ផ្លូវកោះនរា( ផ្លូវមុខអគ្គនាយកដ្ឋានវិទ្យុនិងទូរទស្សន៍បាយ័ន )ឆ្លងទន្លេតូចដែលមានប្រវែង៦០ម៉ែត្រ និងទទឹង២១ម៉ែត្រ ។[36]

**១.២.១.២. ការអភិវឌ្ឍសំណង់លំនៅដ្ឋាន**

នាពេលបច្ចុប្បន្ននេះនៅក្នុងខណ្ឌច្បារអំពៅ មានការអភិវឌ្ឍខ្លាំងទៅលើវិស័យសំណង់លំនៅដ្ឋានដែលនៅក្នុងនោះមានបុរី ខុនដូរ លំនៅដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ភោជនីយដ្ឋាន ផ្សារទំនើបៗ សួនច្បារ មជ្ឈមណ្ឌលពាណិជ្ជកម្ម មិនតែប៉ុណ្ណោះមានសំណង់ស្ថាប័នរដ្ឋជាច្រើន ដែលបានសាងសង់នៅក្នុងខណ្ឌ។ នៅក្នុងនោះដែលមានលំនៅដ្ឋានខ្លះកំពុងតែសាងសង់ដោយពុំមានលិខិតអនុញ្ញាតពីអាជ្ញាធរឱ្យបានត្រឹមត្រូវតាមច្បាប់ និងលំនៅដ្ឋានខ្លះទៀតសាងសង់ដោយមានការរំលោភបំពានទៅលើដីសាធារណៈរបស់រដ្ឋផងដែរ។

[35] គេហទំព័រ https://www.mpwt.gov.kh/kh/press/16133 ដកស្រង់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

[36] គេហទំព័រ https://www.kampucheathmey.com/businesseconomic/54510/ ដកស្រង់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

❖ **ការងារសំណង់ និងដីធ្លី**

- រុះរើផ្ទះបណ្តែតទឹកដែលមានការសាងសង់រំលោភលើដីចំណីទន្លេដែលជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិព្រែកប្រា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។[37]
- មន្ត្រីខណ្ឌបានចុះត្រួតពិនិត្យដីដុះ និងចុះវាស់វែង ដាក់បង្គោល បោះព្រំដី ដែលជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិជ្រោយអំពិល១ សង្កាត់ជ្រោយអំពិល ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។[38]
- មានសកម្មភាពចាក់ថ្មភ្នំចូលទន្លេត្រង់ម្តុំភូមិកោះនរា សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជាការស្ថាបនាច្រាំងទន្លេ មិនមែនជាការចាក់កម្ទេចថ្មចូលទន្លេ ដោយពុំមានលិខិតការអនុញ្ញាតពីរដ្ឋបាលខណ្ឌច្បារអំពៅ។[39]
- មានការដោះស្រាយវិវាទដីធ្លីសម្រុះសម្រួល ករណីវិវាទដីធ្លីរបស់ប្រជាពលរដ្ឋ ស្ថិតនៅភូមិព្រែកថ្មី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដឹកនាំដោយលោក ហ៊ត គឹមនី អភិបាលរងខណ្ឌច្បារអំពៅ ដោះស្រាយទទួលបានលទ្ធផល«ឈ្នះៈឈ្នះ ទាំងអស់គ្នា»។[40]
- មានការសម្របសម្រួលករណីវិវាទដីធ្លីរបស់បងប្អូនប្រជាពលរដ្ឋ ស្ថិតនៅភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដឹកនាំដោយលោក ហ៊ត គឹមនី អភិបាលរងខណ្ឌច្បារអំពៅ ដោះស្រាយទទួលបានលទ្ធផលឈ្នះ ឈ្នះ ទាំងអស់គ្នា។[41]
- មានការចុះពិនិត្យ និងសម្របសម្រួល ករណីសុំបែងចែកដីជូនបងប្អូនប្រជាពលរដ្ឋ នៅភូមិដើមចាន់១ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញដឹកនាំដោយលោក ហ៊ត គឹមនី អភិបាលរងខណ្ឌច្បារអំពៅ ស្រាយទទួលបានលទ្ធផលឈ្នះ ឈ្នះ ទាំងអស់គ្នា។[42]
- មានការដោះស្រាយទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ ចំនួន៣៦គ្រួសារ និងដីវត្តច្បារអំពៅ ដែលអូសបន្លាយជាង២០ឆ្នាំ ដឹកនាំដោយលោក ចេង មុនីរ៉ា អភិបាលនៃគណៈអភិបាលខណ្ឌ បានបញ្ចប់ដោយជោគជ័យ ក្រោមគោលនយោបាយ «ឈ្នះៈឈ្នះ ទាំងអស់គ្នា» ។ ទន្ទឹមនេះ ប្រជាពលរដ្ឋទាំង៣៦គ្រួសារ រស់នៅ ភូមិដើមស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ។[43]

---

[37] គេហទំព័រ https://www.construction-property.com/km/preaek-pra-canal-land-encroachers ដកស្រង់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

[38] គេហទំព័រ https://www.postkhmer.com/ ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

[39] គេហទំព័រ https://crosscheckwmc.com/post/1/53?fbclid=IwAR0R ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

[40] គេហទំព័រ http://nokorwatnews.com/archives/656638?fbclid=IwAR0K ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

[41] គេហទំព័រ http://rktnews.com/archives/150084?fbclid=IwAR36fOQuEGrf4_ ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

[42] គេហទំព័រ http://csndaily.com/index.php?a=article&id=13666&fbclid=IwAR3OOpog_f5m ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

[43] គេហទំព័រ https://www.cpc-news.com/archives/101067 ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

- មានការរៀបចំចុះបញ្ជីជាលក្ខណៈជាប្រព័ន្ធ បាន៥សង្កាត់ សង្កាត់ក្បាលកោះ សង្កាត់ព្រែកឯង សង្កាត់ព្រែកថ្មី សង្កាត់ព្រែកប្រា សង្កាត់និរោធ។
- មានការរៀបចំចុះចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋ និងមោឃៈនៃប័ណ្ណសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ស្ថិតនៅភូមិមិត្តភាព១ និងភូមិទួលតាចាន់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ។[44]
- មានការរៀបចំចុះចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋរស់នៅក្នុងបុរីស្វាយ២ ដែលបានបំបែកក្បាលដីរួច ចំនួន៤០ប័ណ្ណ ស្ថិតនៅភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ។
- មានការរៀបចំចុះចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋ និងមោឃៈនៃប័ណ្ណសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ស្ថិតនៅភូមិមិត្តភាព១ ស្ថិតនៅភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ។
- មានការរៀបចំចុះចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ និងមោឃៈនៃប័ណ្ណសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ស្ថិតនៅភូមិអូរអណ្តូង១ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ។
- មានការរៀបចំចុះចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋ ចំនួន២២៣ប័ណ្ណ និងមោឃៈនៃប័ណ្ណសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ស្ថិតនៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ។

❖ **ការអភិវឌ្ឍបុរីក្នុងខណ្ឌច្បារអំពៅ**

ជាការពិតណាស់ ការបង្កើតបុរីពិតជាបង្កនូវលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ព្រោះបុរីត្រូវបានសាងសង់ដោយមានលក្ខណៈស្តង់ដារនៃការសាងសង់ត្រឹមត្រូវ។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍបុរីអាចជួយសម្រួលដល់ការតាំងទីលំនៅផងដែរ កាលណាបុរីអភិវឌ្ឍន៍រួចម្ចាស់បុរីអាចផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋ តាមរយៈការបង់រំលោះបន្តិចម្តងៗ ក្នុងការទទួលបានសំណង់គេហដ្ឋាន សម្រាប់ស្នាក់នៅតាមលក្ខណៈស្តង់ដារ និងសមរម្យ។ ម៉្យាងវិញទៀត ការអភិវឌ្ឍបុរី អាចកាត់បន្ថយនូវបញ្ហា សំណង់អនាធិបតេយ្យ និងការកាន់កាប់ដីរដ្ឋខុសច្បាប់ គួរយ៉ាងការអភិវឌ្ឍបុរីនៅខណ្ឌច្បារអំពៅមានដូចជា ៖

- បុរី លីម ឈាងហាក់
- បុរី ប៉េង ហួត
- បុរី សម្បត្តិ មានហេង
- បុរី ភ្នំពេញថ្មី
- បុរី ហាច ធិច ឌីព្រីមៀម
- បុរី វាលស្បូវ

[44] គេហទំព័រ https://www.cycpp.news/2021/01/55309/?fbclid=IwAR3BbvHEP79I7-hs4-m ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

- បុរី ៩៩
- បុរី ភ្នំមាស
- បុរី ភ្នំពេញ ថោន
- បុរីវិមាន ស
- បុរី ហេង មានជ័យ
- បុរី THE WOOD ។

**១.២.១.៣. ការរៀបចំរបៀបរៀបរយ**

ការរៀបចំរបៀបរៀបរយ គឺជានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការរក្សាការពារ សន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ដល់ប្រជាពលរដ្ឋ។ ការរៀបចំរបៀបរៀបរយ គឺជាការរៀបចំទៅលើបញ្ហា ដែលអាជីវករ ឬប្រជាពលរដ្ឋណាមួយ បានធ្វើអាជីវកម្ម ឬការសាងសង់សំណង់ ដោយមានរំលោភយក ផ្លូវសាធារណៈ និងការរៀបចំផ្សាររដ្ឋ និងផ្សារឯកជន ឱ្យមានភាពត្រឹមត្រូវប្រកបទៅដោយរបៀបរៀបរយ។ ដោយ កន្លងមករដ្ឋបាលខណ្ឌច្បារអំពៅបានរៀបចំការងារ ដោះស្រាយបញ្ហាជាច្រើន។ មួយវិញទៀតដោយសារមាន ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ននេះផងដែល រដ្ឋបាលខណ្ឌត្រូវមានការរៀបចំគោលដៅបន្ថែម ទៀតទៅតាមសេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ នៅតាមសង្កាត់នីមួយៗនៅក្នុងខណ្ឌ ដើម្បីជាភាព ងាយស្រួល និងឱ្យមានភាពសមស្របទៅតាមស្ថានភាពនាបច្ចុប្បន្ននេះផងដែរ។

- មានការរៀបចំសណ្តាប់ធ្នាប់ និងសម្អាតបរិស្ថានកើបដី ខ្សាច់ចេញពី លើផ្លូវជាតិលេខ១ដែលខ្សាច់ទាំង នេះធ្លាក់ចេញពីរថយន្តដឹកខ្សាច់ចេញពីដេប៉ូលក់ខ្សាច់ និងបូមខ្សាច់នៅចំណុចភូមិបឹងស្នោ សង្កាត់និរោធ ក្នុងនោះក្រុមសន្តិសុខប្រចាំនៅសាលាខណ្ឌច្បារអំពៅបាននាំគ្នាបោសសម្អាតដីខ្សាច់ដែលធ្លាក់មក លើផ្លូវធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងចុះរៀបចំសណ្តាប់ធ្នាប់តាមបណ្តោយផ្លូវជាតិលេខ១ ជាពិសេស នៅតំបន់ស្មុគស្មាញ ដូចជាផ្សារព្រែកឯង និងផ្សារច្បារអំពៅ។
  ដីខ្សាច់ទាំងអស់នេះធ្លាក់ចេញពី ឡានដឹកខ្សាច់ និងឡានដឹកដី ព្រោះនៅក្នុងភូមិសាស្ត្រសង្កាត់និរោធ និងសង្កាត់វាលស្បូវ សំបូរទៅដោយដេប៉ូលក់ខ្សាច់ ។[45]
- ចុះកាត់ស្លាកយីហោ កាត់សំយាបផ្ទះ ចំពោះម្ចាស់លំនៅដ្ឋាន ម្ចាស់តូបលក់ដូរ ណាដែលសាងសង់របង សាងសង់តូប ដាក់ស្លាកយីហោនិងធ្វើយ៉ាបរំលោភយកផ្លូវសាធារណៈនៅក្នុងភូមិសាស្ត្រសង្កាត់វាលស្បូវ សង្កាត់ព្រែកឯង។[46]

[45] គេហទំព័រ http://nokorwatnews.com/archives/490278?fbclid=IwAR ដកស្រង់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

[46] គេហទំព័រ https://www.cpc-news.com/archives/52908 ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១

- ចុះពិនិត្យរៀបចំកន្លែងស្តង់លក់ដូរ គឺដើម្បីឱ្យបងប្អូនជាអាជីវករត្រូវមាន គម្លាតសុវត្ថិភាព សោភ័ណភាព និងអនាម័យ ក្នុងកំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញនឹងក្រុងតាខ្មៅ ក្នុងនោះក៏មានខណ្ឌច្បារអំពៅយើងដែល ហើយដើម្បីបង្ការទប់ស្កាត់ជម្ងឺកូវីដ១៩ ទីតាំងដែលកំពង់រៀបចំនោះ គឺស្ថិតនៅតាមផ្លូវព្រែកប្រាំង ក្រោយវត្តនិរោធ ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។[47]
- ចុះបាញ់ថ្នាំកំណត់ព្រំប្រទល់ អនុញ្ញាតឱ្យអ្នកលក់ដូរនៅតាមផ្លូវលេខ ៣៦៩ ពិសេសផ្សារជនជាតិ លក់ដូរនៅមូលដ្ឋានសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។[48]
- ចុះធ្វើការណែនាំដល់ប្រជាពលរដ្ឋ នៅតាមបណ្តាមហាវិថីតូចធំ និងផ្លូវតូចៗមួយចំនួនធំក្នុងខណ្ឌមិនឱ្យរំលោភលើចិញ្ចើមផ្លូវលើស១ភាគ៣នៃចិញ្ចើមផ្លូវឡើយ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ សោរភ័ណភាពទីក្រុង និងរក្សាទុកចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង ជនពិការភាពធ្វើដំណើរ។[49]

### ២.១.២. ទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់

ជាទូទៅ រាល់ការអភិវឌ្ឍតែងតែមានគោលដៅទុកជាមុន ដើម្បីត្រៀមក្នុងការអភិវឌ្ឍ ការរៀបចំផែនការ ឬគម្រោងទុកជាមុន ដើម្បីជាភាពងាយស្រួលឱ្យមានដំណើរការល្អ ហើយគម្រោងនេះត្រូវបានគេសរសេរទុកនៅក្នុងសៀវភៅផែនការអភិវឌ្ឍ ៥ឆ្នាំ នៃខណ្ឌច្បារអំពៅ។ ដោយឡែកទិសដៅនាពេលអនាគត គឺមានគោលបំណងអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ដើម្បីជាគោលដៅអភិវឌ្ឍន៍នៅក្នុងខណ្ឌ។

#### ២.១.២.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន

គម្រោងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធស្ពានឆ្នាំ២០២៣ខាងមុខ មានគោលដៅគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេបាសាក់ ចន្លោះពីស្ពានព្រះមុនីវង្ស និងស្ពានទន្លេបាសាក់ តាខ្មៅ (ស្ពានព្រែកសំរោង) គឺមានចន្លោះពីស្ពានព្រះមុនីវង្ស ទៅស្ពានទន្លេបាសាក់ (តាខ្មៅ) ចន្លោះប្រវែងប្រមាណជា ៧,៥៣៨ម៉ែត្រ មានបណ្តោយផ្លូវមេចំនួនពីរខ្សែស្របតាមបណ្តោលទន្លេបាសាក់រួចមានដូចជា៖

- ទី១ ផ្លូវលេខ៣៦៩ អមផ្នែកខាងកើតទន្លេ មានចន្លោះពី២០ម៉ែត្រ ទៅ៣០ម៉ែត្រ ។
- ទី២ ផ្លូវជាតិលេខ២ អមផ្នែកខាងលិចទន្លេ មានទទឹង ៣០ម៉ែត្រ ចាប់ពីស្ពានព្រះមុនីវង្ស ដល់រង្វង់មូលព្រះនរា មានប្រវែងប្រមាណ ៤,២៨៧ម៉ែត្រ បន្តឆ្លងកាត់ទីក្រុងតាខ្មៅ និងផ្លូវជាតិលេខ២១។

ក្នុងតំបន់នេះ ជាចរន្តដែលត្រូវធ្វើចរាចរណ៍ឆ្លងកាត់ ចូលមកផ្នែកកណ្តាលនៃរាជធានីភ្នំពេញ ដែលបណ្តាលឱ្យចរារណ៍កកស្ទះ ដោយសារកំណើនសេដ្ឋកិច្ចទីផ្សារ និងប្រជាពលរដ្ឋ ដូចនេះចាំបាច់ត្រូវធ្វើការ

---

[47] គេហទំព័រ https://csndaily.com/index.php?a=article&id=15733&fbclid=IwAR2BhnWNDG1U ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១

[48] គេហទំព័រ https://kohreport.com/news/9507/?fbclid=IwAR2ZuCl4T-MBgnCDoN_4RcQzztU9GGdjw ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១

អភិវឌ្ឍ ដោយសិក្សារកដំណោះស្រាយបញ្ហាកកស្ទះ តាមរយៈការសាងសង់ស្ពានឆ្លងកាត់ទន្លេបាសាក់ និង បណ្ដាញផ្លូវមេសំខាន់ៗមួយចំនួន។

គោលដៅគម្រោងស្ថាបនាខ្សែទី១ តភ្ជាប់ត្រង់ភូមិទួលរកា ភូមិព្រែកតាឡុង២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ និងភូមិអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ។ ស្ពាននេះ ចាប់បន្តពីមហាវិថីអ្នកឧញ៉ា មហាភក្តិសប្បុរសភោគបតី ហ៊ុន នាង ឆ្លងកាត់ផ្លូវជាតិលេខ២ ផ្លូវទទឹង៧ម៉ែត្រ ជាប់ខាងជើងវត្តចាក់អង្រែលើ ទន្លេបាសាក់ ផ្លូវលេខ៣៦៩ និងតភ្ជាប់ គម្រោងផ្លូវ៣០ម៉ែត្រ ទៅ៦០ម៉ែត្រ មានប្រវែងសរុបប្រមាណ៨៨៧ម៉ែត្រ។

គោលដៅគម្រោងស្ថាបនាខ្សែទី២ តភ្ជាប់ត្រង់ភូមិទួលរកា ភូមិព្រែកតាឡុង២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ និងភូមិអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ។ ស្ពានចាប់បន្តពីគម្រោងផ្លូវ ៥០ម៉ែត្រ-៦០ម៉ែត្រ (មហាឧបាសក ហ៊ុន នាង) ឆ្លងកាត់ផ្លូវជាតិលេខ២ ទន្លេបាសាក់ ផ្លូវលេខ៣៦៩ និងតភ្ជាប់ទៅគម្រោងផ្លូវ៥០ម៉ែត្រ ៦០ម៉ែត្រ មានប្រវែង៩០០ម៉ែត្រ។[50]

ទឹកដីក្បាលកោះដែលបច្ចុប្បន្ននេះជាតំបន់ដែលត្រូវគេដាក់ឈ្មោះថា «ទឹកដីត្រជាក់» ក្រោយគម្រោងរដ្ឋ ធំ៣ ត្រូវបានប្រកាសចាប់ផ្ដើមសាងសង់ក្នុងឆ្នាំ ២០២០រួចហើយ ដែលគម្រោងទាំង៣នោះ នឹងមានការបញ្ចប់ នៅឆ្នាំ២០២៣ រួមមាន៖

- **គម្រោងស្ពានភ្ជាប់ពី ភ្នំពេញ (ចំណុចកោះពេជ្យ) ទៅកោះនរា និងផ្លូវជាតិលេខ១៖** ជាក់ស្ដែងគម្រោង សាងសង់ស្ពានថ្មីនេះ ទើបប្រកាសក្រុងពាលី ចាប់ផ្ដើមសាងសង់កាលពីថ្ងៃទី ២៦ ខែតុលា ២០២០នេះ ហើយគ្រោងនឹងបញ្ចប់នាចុងឆ្នាំ ២០២៣ ។ គម្រោងស្ពានចំនួន ២ ខ្សែនេះ នឹងធ្វើឱ្យភ្នំពេញ នឹងតំបន់ នៅជុំវិញផ្លូវជាតិលេខ ១ កាន់តែជិតគិតស្មានមិនដល់។
- **គម្រោងព្រលានយន្តហោះថ្មី ក្នុងទឹកដីក្រុងតាខ្មៅ ខេត្តកណ្ដាល៖** ដោយសារតំបន់ក្បាលកោះជាប់នឹង ផ្លូវរដ្ឋ១១៤ (ផ្លូវរោងចក្រថៃហ៊្វ័រ) ដែលភ្ជាប់ទៅចំណុចប្រសព្វគ្នា រវាងក្រុងតាខ្មៅ និងខេត្តកណ្ដាល ពីគម្រោងយន្តហោះថ្មីក្នុងទឹកដីតាខ្មៅ។

អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី មានទីតាំងនៅក្នុងឃុំព្រែកស្ដែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មីនេះ ត្រូវបានសាងសង់ឡើងលើផ្ទៃដីទំហំប្រមាណ ២,៦០០ហិកតា ហើយ គ្រោងនឹងបញ្ចប់ការសាងសង់នៅក្នុងឆ្នាំ ២០២៣ ខាងមុខ។

- **គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-បាវិត៖** គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-បាវិត (PhnomPenh-Bavet Expressway) ជាខ្សែផ្លូវថ្មីទាំងស្រុង ដែលមានប្រវែងសរុបប្រហែល ១៣៥ គ.ម។ ផ្លូវនេះត្រូវសាងសង់ជា ៤គន្លង តួផ្លូវមានទទឹង ២៥,៥ ម៉ែត្រ។ ខ្សែផ្លូវនេះ នឹងចេញពីភ្នំពេញនៅចំណុចផ្លូវខ្សែក្រវ៉ាត់ក្រុងទី៣

[50] គេហទំព័រ https://cambodiapropertyreport.com/article/1557?fbclid=IwAR ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

កាត់តាមខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តស្វាយរៀង ឆ្ពោះទៅក្រុងបាវិត ព្រំដែនកម្ពុជា-វៀតណាម។ បច្ចុប្បន្នគម្រោងនេះត្រូវបានបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាព និងកំពុងស្ថិតក្នុង ដំណាក់កាលពិភាក្សាលើតម្លៃនៃគម្រោង និងប្រភពថវិកា។[51]

- គម្រោងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធស្ពានខ្សែកាបឆ្នាំ២០២៣ខាងមុខ តភ្ជាប់កោះនរា ខណ្ឌច្បារអំពៅ មកកាន់កោះពេជ្រខណ្ឌចំការមនផងដែរ។ ជាមួយគ្នានេះស្ពានខ្សែកាប តភ្ជាប់តំបន់អភិវឌ្ឍន៍កោះនរា មកកាន់កោះពេជ្រ មានប្រវែង៨២៤ម៉ែត្រក៏សម្រេចបានការងារបានប្រមាណ៣០% មកដែរ។[52]
- ចំពោះការអនុវត្តន៍គម្រោងជំហ៊ានទី២ ចាប់ពីច្រកចេញចូលក្រុមហ៊ុនផាន មិចទៅដល់ផ្លូវបំបែកចូលរោងចក្រស្រាបៀថៃហ្គ័រ។[53]
- ដាក់គម្រោងអភិវឌ្ឍសាងសង់ ស្ពានឆ្លងកាត់ទន្លេបាសាក់ ចន្លោះពីស្ពានព្រះមុនីវង្ស និងស្ពានព្រែកសំរោង។[54]

ការអភិវឌ្ឍគម្រោងនេះ ដើម្បីកាត់បន្ថយការកកស្ទះខ្លាំង ហើយជាភាពស្រួលក្នុងការប្រកបរបរអាជីវកម្មផ្សេងៗ ដោយធ្វើការលើកកម្ពស់ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាព និងពង្រឹងការផ្តល់សេវាយានយន្តឱ្យមានប្រសិទ្ធិភាព។ ចំណែកឯយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យនេះ គឺជាគន្លឹះដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធិភាពសេដ្ឋកិច្ច ជាតម្រូវការចាំបាច់ដល់ប្រជាពលរដ្ឋក្នុងជីវភាពរស់នៅ និងប្រកបមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ដូច្នេះវិស័យហេដ្ឋារចនាសម្ព័ន្ធ គឺជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានត្រូវពង្រឹងការស្ថាបនា និងជួសជុលផ្លូវ លូ ស្ពាន ឱ្យមានគុណភាព និងប្រសិទ្ធិភាពខ្ពស់។

**២.១.២.២. ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ**

ចំពោះការរំពឹងទុកនាឆ្នាំ២០២៣ខាងមុខនេះ ប្រជាពលរដ្ឋប្រមាណ៧០ភាគរយមានទឹកស្អាត ប្រើប្រាស់ដោយខណ្ឌបានរៀបចំបណ្តាយទឹកស្អាត សម្រាប់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍទៅលើវិស័យទឹកស្អាត និង អនាម័យនេះក្នុងគោលបំណងជម្រុញឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់ និងមានអនាម័យដល់ប្រជាពលរដ្ឋ។ មួយវិញទៀត ដើម្បីសម្រេចនូវគោលបំណងនេះក៏ត្រូវមាននូវយុទ្ធសាស្ត្រសម្រេចលើការអភិវឌ្ឍវិស័យនេះ ដោយជម្រុញឱ្យមានការតណ្តាញទឹកស្អាត ការសង់ និងជួសជុល និងការស្តារស្រះ ដើម្បីឱ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅគ្រប់មូលដ្ឋានទាំងអស់។

---

[51] គេហទំព័រ https://news.sabay.com.kh/article/1240235?fbclid=Iw ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

[52] គេហទំព័រ https://cambodiapropertyreport.com/article/4132?fbclid=IwAR2s5qJKYyTxs0bGJs0yXy ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

[53] គេហទំព័រ http://nokorwatnews.com/archives/341058?fbclid=IwAR ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

[54] គេហទំព័រ https://www.kampucheathmey.com/localnews/53160/?fbclid=IwAR2 ដកស្រង់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

**២.១.២.៣. ការអភិវឌ្ឍលើវិស័យដីធ្លី**

ចំពោះគោលដៅអភិវឌ្ឍន៍នៃវិស័យដីធ្លីក្នុងខណ្ឌច្បារអំពៅនាឆ្នាំ២០២៣ ប្រជាពលរដ្ឋ៦០ភាគរយទៅបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ដោយមានការចុះបញ្ជីដីធ្លីជាលក្ខណៈជាប្រព័ន្ធ ការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងផ្សព្វផ្សាយពីច្បាប់ភូមិបាល។ ក្នុងការអភិវឌ្ឍវិស័យដីធ្លី គឺមានយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍដោយធ្វើការផ្សព្វផ្សាយ ច្បាប់ភូមិបាលឱ្យបានទូលំទូលាយ និងមានសារៈសំខាន់ នៃការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដោះស្រាយវិវាទ និងសម្របសម្រួលទំនាស់ដីធ្លី។

**២.១.២.៤. ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ចំពោះគោលដៅអភិវឌ្ឍន៍វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈខណ្ឌច្បារអំពៅ ទៅថ្ងៃអនាគតដោយរំពឹងថា នឹងសម្រេចបានក្នុងឆ្នាំ២០២៣ខាងមុខ ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសុវត្ថិភាព ដោយខណ្ឌមានការអភិវឌ្ឍទៅលើ ៖

- ពង្រឹងសកម្មភាពរក្សាសន្តិសុខសណ្តាប់ធ្នាប់ ក្នុងមូលដ្ឋាន
- ទប់ស្កាត់ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- បង្ក្រាបអំពើចោរកម្ម និងលេងល្បែងស៊ីសងគ្រប់ប្រភេទ
- ពង្រឹងការប្រើប្រាស់នូវអាវុធខុសច្បាប់
- ប្រមូលក្រុមជនពាលដើម្បីអប់រំ
- សង់/ជួសជុលប៉ុស្តិ៍ប្រជាការពារ
- ពង្រឹងវិធានការណ៍ ការពារគ្រោះថ្នាក់ចរាចរណ៍
- ពង្រឹងសមត្ថភាព ការពារ ទប់ទល់គ្រោះអគ្គិភ័យ និងគ្រោះធម្មជាតិ
- ពង្រឹងការពារ និងទប់ស្កាត់ពីជំងឺវីរុសកូវីដ១៩ ។

ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងគោលបំណង បង្កើនការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋក្នុងខណ្ឌរស់នៅប្រកបដោយ សន្តិសុខ សុវត្ថិភាពបុគ្គល និងសុវត្ថិភាពសាធារណៈ គ្មានភ័យខ្លាច ស្ងៀមស្ងាត់ ជាពិសេសនោះគឺ ការរស់នៅប្រកបដោយសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត បន្ថែមពីនេះដើម្បីការពារអាយុជីវិតរបស់ប្រជាពលរដ្ឋជៀសផុតពីជំងឺកូវីដ ដែលជាជំងឺដល់កាចសាហាវ។ ដូច្នេះដើម្បីសម្រេចបាននូវគោលបំណងខាងលើ ខណ្ឌច្បារអំពៅ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ទៅលើវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានដូចខាងក្រោម ៖

- ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន

- អនុវត្តន៍គោលនយោបាយ ឃុំ សង្កាត់ មានសុវត្ថិភាព
- ផ្សព្វផ្សាយច្បាប់អនុវត្តន៍វិធានការការពារតាមការណែនាំរបស់ក្រសួងសុខាភិបាល ទប់ស្កាត់ការឆ្លងវីរុសកូវីដ-១៩ ដល់ប្រជាពលរដ្ឋគ្រប់ភូមិ និងសង្កាត់ទាំងអស់នៅក្នុងខណ្ឌច្បារអំពៅ។
- រៀបចំសណ្តាប់ធ្នាប់សាធារណៈ
- ជម្រុញការចុះធ្វើរដ្ឋបាល។

# ជំពូកទី២

# ការរៀបចំសោភ័ណភាព

# ខណ្ឌច្បារអំពៅ

# ជំពូកទី២
# ការរៀបចំសោភ័ណភាពខណ្ឌច្បារអំពៅ

កាលណាតំបន់មួយ ឬទីកន្លែងមួយមានភាពស្រស់ស្អាតនោះ វានឹងក្លាយទៅជាតំបន់មួយ ដែលពោរពេញទៅដោយភាពទាក់ទាញ ភាពល្អប្រសើរ និងភាពស្រស់បំព្រងដោយសារតែបរិស្ថាន និងអនាម័យនៅក្នុងតំបន់នោះ។ សោភ័ណភាព គឺជាអ្វីៗដែលធ្វើឱ្យកាន់តែប្រសើរឡើងជាងមុន ធ្វើឱ្យល្អហ្មត់ហ្មង និងជាអ្វីៗទាំងអស់ដែលអាចមើលឃើញនឹងភ្នែកបាន ហើយធ្វើឱ្យមានការចាប់អារម្មណ៍។

សព្វថ្ងៃនេះ បើយើងធ្វើការប្រៀបធៀបខណ្ឌច្បារអំពៅក្នុងរយៈពេល១០ឆ្នាំមុន និងពេលបច្ចុប្បន្ន យើងឃើញថាសន្ទុះនៃការអភិវឌ្ឍនៅក្នុងខណ្ឌមានការផ្លាស់ប្តូរដែលគួរឱ្យកត់សម្គាល់ ជាពិសេសគឺទៅលើបញ្ហាសោភ័ណភាពនេះឯង។ ក្នុងការរៀបចំនូវសោភ័ណភាពខណ្ឌ គឺអាស្រ័យទៅលើហេតុផលជាច្រើនដែលតម្រូវឱ្យអាជ្ញាធរខណ្ឌត្រូវយកចិត្តទុកដាក់ជាទីបំផុត ចំណែកឯផលដែលទទួលបានពីការរៀបចំនោះមានដូចជា ធ្វើឱ្យខណ្ឌមានភាពស្រស់ស្អាត មានផាសុខភាព ជាពិសេសមានការកែលម្អពីភាពអនាធិបតេយ្យប្រែក្លាយមកជាភាពស្រស់ស្អាត មានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយត្រឹមត្រូវតាមស្តង់ដារ ដែលធ្វើឱ្យប្រជាជននៅក្នុងខណ្ឌផ្ទាល់ មានការរស់នៅប្រកបដោយសុខដុមរមនា សុខសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត សន្តិសុខ សណ្តាប់ធ្នាប់ មានផាសុខភាព អនាម័យល្អ និងមានអារម្មណ៍ស្រស់ស្រាយជាមួយនឹងសោភ័ណភាពល្អប្រសើរ របស់ខណ្ឌ។ ហេតុដូចនេះហើយទើបរដ្ឋបាលខណ្ឌបានខិតខំ ស្វះស្វែង រិះរក គ្រប់មធ្យោបាយ កែកុន និងស្ថាបនាដើម្បីឱ្យខណ្ឌច្បារអំពៅ មានភាពរីកចម្រើនសុះសាយ និងមានភាពលេចធ្លោ ជាពិសេសដើម្បីប្រកួតប្រជែងខាងផ្នែកសោភ័ណភាពស្អាត ទីក្រុងស្អាត ជាមួយខណ្ឌដទៃៗទៀតនៅរាជធានីភ្នំពេញ។

## ២.១. ការរៀបចំសោភ័ណណភាពពេលថ្ងៃ និងពេលយប់

ជាទូទៅ រាល់ខណ្ឌនីមួយៗនៃទីក្រុងភ្នំពេញតែងតែមានភាពអភិវឌ្ឍន៍របស់ខ្លួន និងចង់ឱ្យខណ្ឌរបស់ខ្លួនក្លាយជាទីចាប់អារម្មណ៍ពីសំណាក់មហាជន និងមជ្ឈដ្ឋាននានា។ ការរៀបចំសោភ័ណភាពនៅក្នុងខណ្ឌភាគច្រើន គឺផ្តោតសំខាន់ទៅលើសោភណ័ភាពទាំងពេលថ្ងៃ និងទាំងសោភ័ណភាពពេលយប់។

### ២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ

ការរៀបចំសោភ័ណភាពពេលថ្ងៃ គឺសម្តៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពានប្រពន្ធ័លូ ចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី និងប្រពន្ធ័សុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ និងទាំងថ្មើរជើងផង ប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយថែម

ទៀត។[55] ក្នុងនោះដែរយើងសង្កេតឃើញថា នៅក្នុងខណ្ឌច្បារអំពៅមានភាពអភិវឌ្ឍន៍ខ្លាំង និងមានភាពលេចធ្លោទៅលើ ការដាំដើមឈើតាមដងផ្លូវ ដាំស្មៅលម្អតាមសួនច្បារ ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍តាមដងផ្លូវ ព្រមទាំងបានរៀបចំសំណង់អគារតូចធំតាមដងផ្លូវឱ្យមានសណ្តាប់ធ្នាប់ ប្រកបទៅតាមស្តង់ដាររបស់ខណ្ឌដែលបានកំណត់។

### ២.១.១.១. ការដាំដើមឈើតាមដងផ្លូវ

ជាក់ស្តែងនាពេលថ្មីៗនេះ រដ្ឋបាលខណ្ឌ បានដាំស្មៅ និងដើមឈើតូច ធំជាច្រើន ជាពិសេសដាំដើមផ្កាសាគូរ៉ាជាច្រើនដើមនៅចិញ្ចើមផ្លូវតាមបណ្តោយផ្លូវជាតិលេខ១ មុខវត្តនិរោធរង្សី ព្រមទាំងបានរៀបចំនូវប្រព័ន្ធស្រោចទឹកដោយស្វ័យប្រវត្តិនៅតាមសួនច្បារនៅមុខបងអនុវិទ្យាល័យ ច្បារអំពៅ។ បន្ថែមពីនេះទៀត រដ្ឋបាលខណ្ឌក៏បានជម្រុញដល់អាជ្ញាធរសង្កាត់ ត្រូវយកចិត្តទុកដាក់ ចូលរួមដាំដើមឈើគ្រប់ប្រភេទនៅតាមទីវត្តអារាម សាលារៀន ភូមិឋាន ប្រឡាយទឹក ដងផ្លូវ និងនៅតាមទីសាធារណៈនានា ក្នុងគោលបំណងជួយថែរក្សាបរិស្ថាន បង្កើនទេសភាព សោភ័ណភាព បង្កើតម្លប់ពណ៌បៃតង និងជាម្លប់ដ៏ត្រជាក់សម្រាប់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ ជាពិសេសជួយកែប្រែបរិយាកាសធម្មជាតិនៅតាមសាលារៀន វត្តអារាម និងទីសាធារណៈនានាឱ្យកាន់តែល្អប្រសើរថែមឡើង។[56]

### ២.១.១.២. ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ

ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ មានសារៈសំខាន់ណាស់សម្រាប់អ្នកធ្វើដំណើរគ្រប់រូប ដូចជាការបំពាក់កាំមេរ៉ាសុវត្ថិភាព ការរក្សាសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងស្លាកសញ្ញាចរាចរណ៍ជាដើម។ កាំមេរ៉ាសុវត្ថិភាពមានសារៈប្រយោជន៍ចាំបាច់ណាស់ដែលបានរួមចំណែកក្នុងការកាត់បន្ថយបទល្មើសនានា តាមដានស្ថានភាពចរាចរណ៍ ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងងាយស្រួលក្នុងការទទួលបាននូវព័ត៌មានជាក់ស្តែងពីបទល្មើសផ្សេងៗដែលកើតមានឡើងនៅក្នុងប្រទេស ជាពិសេសនៅរាជធានីភ្នំពេញតែម្តង។ បច្ចេកទេសកាំមេរ៉ាសុវត្ថិភាពត្រូវបានគេប្រើប្រាស់នៅតាមបណ្តាប្រទេសជាច្រើនលើកសាកលលោកដែលគេប្រើក្នុងគោលបំណងដើម្បីទប់ស្កាត់ បង្ក្រាប តាមចាប់បទល្មើស តាមទីសាធារណៈ ដែលបង្កើនទំនុកចិត្តដល់ភ្ញៀវទេសចរណ៍ និងអ្នកដំណើរគ្រប់រូបនៅតាមដងផ្លូវនេះ គឺជាឧទាហរណ៍ដែលល្អបំផុតសម្រាប់ប្រទេសកម្ពុជាយកមកអនុវត្តបាន។ កាំមេរ៉ាសុវត្ថិភាពសាធារណៈមានសារៈប្រយោជន៍សម្រាប់ថតយករូបភាពពីទីតាំងគោលដៅ និងពីពេលវេលាជាក់លាក់ដែលបទល្មើសមួយកើតឡើង។ មិនថែមទាំងប្រើសម្រាប់ថតរូបតែប៉ុណ្ណោះទេ គឺគេអាចយកទិន្នន័យ ដើម្បីមកប្រើប្រាស់ជាប្រយោជន៍ដែលអាចជាតម្រុយនៃបទល្មើស ឬអាចជា

[55] សៀវភៅ នីតិនគរូបនីយកម្មវិទ្យាបណ្ឌិត អ៊ុន សកក្តដា បោះពុម្ពឆ្នាំ២០១៩-២០២០ ទំព័រទី១

[56] គេហទំព័រ https://www.kampucheathmey.com/local-news/150519/ ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

ភស្តុតាងជាក់ស្តែងសម្រាប់បទល្មើសដែលកើតមាន។ ហេតុដូចនេះហើយទើបរដ្ឋបាលរាជធានីភ្នំពេញ បានស្នើឱ្យម្ចាស់ហ៊ុន និងខុនដូទាំងអស់នៅក្នុងរាជធានីភ្នំពេញ ផ្តល់ទិន្នន័យពីកាំមេរ៉ា សុវត្ថិភាពជូនសមត្ថកិច្ច ដើម្បីពង្រឹងកិច្ចសហការជាមួយគ្នា ឱ្យបានល្អក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់ ជូន ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ ហើយសមត្ថកិច្ចនឹងរក្សាជាការសម្ងាត់ ដោយមិនអនុញ្ញាតឱ្យយកទិន្នន័យចេញពីកាំមេរ៉ា សុវត្ថិភាពទាំងនោះទៅផ្សព្វផ្សាយ ដោយគ្មានការអនុញ្ញាតឡើយ។[57] ការបំពាក់កាំមេរ៉ានេះនឹងធ្វើឡើងនៅតាមច្រកសំខាន់ៗនៅក្នុងខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ក្នុងនោះដែរខណ្ឌច្បារអំពៅដែលជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ ដែលសម្បូរទៅដោយ ប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ ទាំងប្រជាជនចំណាកស្រុក ទាំងកម្មករ កម្មការនី ទាំងមន្ត្រីរាជការតូចធំ ជាពិសេសទាំងរថយន្តគ្រប់ធុន មិនថាបែបទេសចរណ៍ រថយន្តដឹកទំនិញ រថយន្តក្រុង និងជាពិសេស ប្រភេទរថយន្តកុងទីន័រធំដែលដឹកទំនិញចេញចូលទៅផែស្វយ័តទៅភ្នំពេញ ឥតឈប់ឈរ ដែលនេះជាហេតុធ្វើឱ្យសាលារាជធានីភ្នំពេញបានបំពាក់នូវ កាំមេរ៉ាសុវត្ថិភាពជាច្រើនគ្រឿង នៅតាមស្តុបសំខាន់ៗក្នុងខណ្ឌច្បារអំពៅ ដើម្បីការពារសន្តិសុខ សុវត្ថិភាពរបស់អ្នកធ្វើដំណើរ ជាពិសេសនៅពេលយប់ និងផ្តល់ជាភាពងាយស្រួលក្នុងការកំណត់ បាននូវមុខសញ្ញាច្បាស់លាស់ ទីតាំងភស្តុតាង ពេលវេលាដែលបទល្មើសកើតមាននៅក្នុងខណ្ឌ។

- **ចំពោះបញ្ហាចិញ្ចើមផ្លូវ**

ដោយសារតែស្ថានភាពចរាចរណ៍នៅលើផ្លូវជាតិលេខ១ ក្នុងតំបន់ខណ្ឌច្បារអំពៅ មានបញ្ហាកកស្ទះស្ទើរតែរៀងរាល់ថ្ងៃ ដែលបណ្តាលមកពីការដាក់តាំងលក់ទំនិញគ្រប់ប្រភេទ នៅលើចិញ្ចើមផ្លូវ ការឈប់ចតត្រីចក្រយានយន្តទោចក្រយានយន្តគ្រប់ប្រភេទនៅលើ ផ្លូវសាធារណៈ និងតាមចិញ្ចើមផ្លូវយ៉ាងអនាធិបតេយ្យ គ្មានសណ្តាប់ធ្នាប់ ទើបនេះជាកត្តា ដែលឃុំាងឱ្យរដ្ឋបាលខណ្ឌធ្វើការដោះស្រាយ និងរៀបចំចំពោះបញ្ហានេះឱ្យបានលឿនបំផុត។ សាលាខណ្ឌក៏បានចូលរួមក្នុងការអនុវត្តនូវសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ ដើម្បីធ្វើយ៉ាងណា ចូលរួមថែរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ កាត់បន្ថយ ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ផ្សេងៗ ជាពិសេសដើម្បីលើកកម្ពស់សោភ័ណភាពខណ្ឌ និងចូលរួមទប់ស្កាត់ការរីករាលដាលនៃការឆ្លងជំងឺកូវីដ១៩ ទប់ស្កាត់ការប្រមូលផ្តុំ មនុស្សច្រើនដែលមិនបានអនុវត្តវិធានការ ៣កុំ និង ៣ការពារ របស់ប្រមុខរាជរដ្ឋាភិបាល ព្រមទាំងការពារចិញ្ចើមផ្លូវពីការរំលោភបំពានពីសំណាក់ប្រជាពលរដ្ឋ ដោយចាត់វិធានការធ្វើការណែនាំ និងរៀបចំចិញ្ចើមផ្លូវតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងតំបន់ខណ្ឌច្បារអំពៅដូចជា ៖

- ហាមសាងសង់ រោងតូប និងស្តង់ ដាក់តាំងលក់ទំនិញគ្រប់ប្រភេទល្មើសសណ្តាប់ធ្នាប់នៅលើផ្លូវសាធារណៈ និងតាមបណ្តោយផ្លូវជាតិលេខ១ ចំណុចផ្សារព្រែកឯង តាមបណ្តោយផ្លូវ៣៦៩ និង ផ្លូវ៣៥៧ ក្នុងសង្កាត់ច្បារអំពៅទី២។

[57] គេហទំព័រ http://phnompenh.gov.kh/news-press-releases/post/news081020/ ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

- ហាមចតត្រីចក្រយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ យ៉ាងអនាធិបតេយ្យ និងគ្មានសណ្តាប់ធ្នាប់ នៅលើផ្លូវសាធារណៈ និងតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងសង្កាត់ព្រែកឯង និងសង្កាត់ច្បារអំពៅទី២។[58]

តាមសេចក្តីណែនាំស្តីពី "ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវ សាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ" បានចេញសេចក្តីណែនាំទៅដល់ខណ្ឌទាំង១៤ ក្នុងរាជធានីភ្នំពេញ ក្នុងការណែនាំដល់ប្រជាពលរដ្ឋនៅក្នុងខណ្ឌរបស់ខ្លួនចំពោះការប្រើប្រាស់ដីចំណីផ្លូវ ក៏ដូចជាចិញ្ចើមផ្លូវដោយស្រប តាមការកំណត់របស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងគោលដៅ ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ និងលើកកម្ពស់សោភ័ណភាពទីក្រុង-ខណ្ឌ និងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ចិញ្ចើមផ្លូវ ទាំងផ្នែកខាងលើ និងផ្នែកខាងក្រោមដីសម្រាប់បម្រើជាផលប្រយោជន៍ដល់សាធារណៈជនស្របតាមលក្ខណៈបច្ចេកទេស។ ក្នុងសេចក្តីណែនាំនោះ សាលារាជធានីភ្នំពេញបានកំណត់ឱ្យប្រើប្រាស់ចិញ្ចើមផ្លូវដូចខាងក្រោម ៖

- ចិញ្ចើមផ្លូវទុកបម្រើដល់ការធ្វើចរាចរណ៍ដោយថ្មើរជើង
- បម្រើកម្មភាព ដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៌ និងពិធីបុណ្យផ្សេងទៀត នៅលើដងផ្លូវ ប៉ុន្តែត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ទៅតាមកម្រិតនៃពិធី និងតាមភាពចាំបាច់
- បម្រើកម្មភាពដឹកនាំជីកកប់បណ្តាញក្រោមដី ដូចជា បណ្តាញទឹកស្អាត ប្រពន្ធ័លូ ខ្សែបញ្ជូនអគ្គិសនី បំពង់ទុយោ ខ្សែកាបអុបទិចគ្រប់ប្រភេទ និងបរិក្ខារក្រោមដីផ្សេងៗទៀត
- បម្រើកម្មភាពសាងសង់ ក្នុងគម្រោងចាំបាច់មួយចំនួនដូចជា បរិក្ខារបម្រើឱ្យវិស័យការពារជាតិ សន្តិភាពជាតិ បរិក្ខារបម្រើឱ្យការគ្រប់គ្រង ឬ ការសាងសង់ ផ្លូវ និងបរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀតតាមការចាំបាច់។
- សម្រាប់ប្រជាពលរដ្ឋដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ គ្រឹះស្ថានអប់រំ អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវចូលរួមប្រើចិញ្ចើមផ្លូវឱ្យស្របតាមការកំណត់របស់សាលារាជធានីភ្នំពេញដោយអាចប្រើប្រាស់ចិញ្ចើមផ្លូវត្រឹម ១/៣ សម្រាប់ការរៀបចំ សម្ភារៈទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ ជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្តាប់ធ្នាប់ និងចរាចរណ៍។ រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនត្រូវឱ្យលើសពី ១/៣ នៃចិញ្ចើមផ្លូវឡើយ។[59]

---

[58] សេចក្តីជូនដំណឹងស្តីពីលេខ ០៣២/២១ លេខ០៣៣/២១ និងលេខ០៣៤/២១ សជណ.ចអព.អណា៣ ចុះថ្ងៃទី១០ ខែឧសភា ២០២១ ស្តីពី "ការហាមលក់ដូរលើផ្លូវ៣៥៧ ផ្សារព្រែកឯង និងផ្លូវលេខ៣៦៩ ក្នុងខណ្ឌច្បារអំពៅ"

[59] សេចក្តីណែនាំរដ្ឋបាលរាជធានីភ្នំពេញ លេខ ០១៣/១៨ សជណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី "ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ"

ដោយឡែករដ្ឋបាលខណ្ឌក៏បានដាក់កំហិតទៅលើអ្នកដែលបានសង់រោង តូប ឬស្តង់ដាក់តាំងលក់ទំនិញគ្រប់ប្រភេទ ល្មើសសណ្តាប់ធ្នាប់ត្រូវរុះរើចេញវិញដោយខ្លួនឯង ក្នុងរយៈពេល០៣ថ្ងៃ គិតចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដែលបានចេញ សេចក្តីជូនដំណឹងនេះតទៅ។ ក្នុងករណី ចចេសរឹងរូស មិនអនុវត្តតាមការណែនាំខាងលើ រដ្ឋបាលនឹងចុះអនុវត្តវិធានការរដ្ឋបាលដោយមិនទទួលខុសត្រូវ ចំពោះការបាត់បង់ទ្រព្យសម្បត្តិ ឬខូចខាតសម្ភារៈអ្វីឡើយ។

❖ **ការបំពាក់ភ្លើងសញ្ញាចរាចរណ៍**

ចំពោះការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវត្រូវបានចែងក្នុងជំពូកទី២ មាត្រា៩ នៃច្បាប់ចរាចរណ៍ផ្លូវគោក ដែលចែងថា៖ “សញ្ញាចរាចរណ៍ផ្លូវគោករួមមាន ផ្លាកសញ្ញាចរាចរណ៍តាមផ្លូវភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត។ ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវត្រូវរៀបចំជាប្រពន្ធ័ទាក់ទងស៊ីចង្វាក់គ្នាជាហូរហែ នៅតាមកន្លែងមានសារៈប្រយោជន៍ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវ ងាយស្រួលមើលឃើញ។ សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយ សមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវ ដែលអាចធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយត្ន័ជាមុនបាន”។[60]

ចំណែកនៅក្នុងខណ្ឌច្បារអំពៅវិញ ការរៀបចំដំឡើងភ្លើងសញ្ញាចរាចរណ៍ ត្រូវបានស្ថាបនាដោយក្រុមការងារបច្ចេកទេសរបស់មន្ទីរសាធារណការរាជធានីភ្នំពេញ សហការជាមួយក្រុមការងារបច្ចេកទេសមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន ដែលហៅកាត់ថា JICA។ ក្នុងនោះផងដែរក្រុមការងារបានរៀបចំដាក់ភ្លើងសញ្ញាចរាចរណ៍ នៅតាមបណ្តោយផ្លូវជាតិលេខ១ក្នុងភូមិសាស្ត្រខណ្ឌច្បារអំពៅ ដោយដំឡើងភ្លើងស្តុបចំនួន ៩គោលដៅគឺ ៖

- គោលដៅទី១ ដាក់នៅផ្លូវបែកជាបួនចំណុចផ្លូវលេខ៣៦៣ កែងផ្លូវជាតិលេខ១ ក្នុងសង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ (ស្តុបផ្សារច្បារអំពៅ)
- គោលដៅទី២ ដាក់នៅចំណុចផ្លូវលេខ៣៦៧ មុខសាលាបឋមសិក្សាច្បារអំពៅ កែងផ្លូវជាតិលេខ១ មុខវត្តច្បារអំពៅ (ស្តុបវត្តច្បារអំពៅ)
- គោលដៅទី៣ ដាក់នៅផ្លូវបែកជាបួនចំណុចផ្លូបចូលវត្តប្រជុំវង្ស កែងផ្លូវជាតិលេខ១ ផ្លូវទៅកោះនរា (ស្តុបវត្តនិរោធ)
- គោលដៅទី៤ ដាក់នៅច្រកចេញ ចូលអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន កែងផ្លូវជាតិលេខ១ (ស្តុបបាយ័ន)

[60] មាត្រា៩ នៃច្បាប់ចរាចរណ៍ផ្លូវគោក ដែលអនុម័ត ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ និងវិសោធនកម្ម ឆ្នាំ២០១៧

- គោលដៅទី៥ ដាក់នៅច្រកចេញ ចូលប៊ុរីប៉េងហួត ទល់មុខអគ្គនាយកដ្ឋានអន្តោប្រវេសន៍(ស្តុបប៊ុរីប៉េងហួត)
- គោលដៅទី៦ ដាក់នៅចំណុចផ្លូវបំបែកជា៤រវាងច្រកចេញ ចូលប៊ុរីប៉េងហួតផ្នែកខាងកើត ទៅកាន់ច្រកចេញចូលដេប៉ូលក់ខ្សាច់ ខាងក្រោយដេប៉ូអេតចាយក្នុងសង្កាត់និរោធ ខណ្ឌច្បារអំពៅ (ស្តុបមន្ទីរពេទ្យជោរវ៉េ)
- គោលដៅទី៧ ដាក់នៅចំណុចច្រកចេញ ចូលដីឧកញ៉ាស៊ុយ សុផាន កែងផ្លូវជាតិលេខ១
- គោលដៅទី៨ និងទី៩ ដាក់នៅចំណុចផ្លូវបំបែកជា៤ រវាងផ្លូវចេញ ចូលទៅកំពង់ចម្លងតាព្រហ្ម មាត់ក្រសះ កែងផ្លូវជាតិលេខ១ និងផ្លូវបំបែកចូលរោងចក្រថៃហ្គ័រ (ស្តុបថៃហ្គ័រ)។[61]

ការដាក់ភ្លើងសញ្ញាចរាចរណ៍នៅក្នុងខណ្ឌច្បារអំពៅ ពិតជាមានសារៈសំខាន់ជាចំណែកមួយជួយសម្រួលដល់ការងាររបស់សមត្ថកិច្ចនៅក្នុងខណ្ឌផ្ទាល់ដូចជាជួយកាត់បន្ថយចំនួននគរបាលចរាចរដែលឈរនៅតាមគោលដៅដើម្បីសម្រួលចរាចរណ៍ជូនប្រជាពលរដ្ឋ មិនតែប៉ុណ្ណោះជួយសម្រួលដល់បញ្ហាចរាចរណ៍បានល្អប្រសើរទៀតផង។

❖ **ការដាក់គំនូសសញ្ញាចរាចរណ៍**

ការដាក់គំនូសសញ្ញាចរាចរណ៍មានសារៈសំខាន់សម្រាប់អ្នកធ្វើដំណើរលើដងផ្លូវ ដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកបើកបរ និងអ្នកថ្មើរជើងដែលបានធ្វើការបែងចែកសិទ្ធិអាទិភាពនៃការបើកបរលើដងផ្លូវដូចជាគំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ គំនូសសញ្ញាព្រួយលើទ្រូងផ្លូវ គំនូសសញ្ញាផ្សេងៗលើទ្រូងផ្លូវ។[62]

❖ **ការដាក់ស្លាកសញ្ញាចរាចរណ៍**

ចំពោះការដាក់នូវស្លាកសញ្ញាចរាចរណ៍សាលារាជធានីភ្នំពេញបានរៀបចំដាក់តាមបណ្តោយផ្លូវ នានានៅក្នុងខណ្ឌទាំង១៤ ដើម្បីផ្តល់ព័ត៌មានសម្រាប់អ្នកបើកបរក៏ដូចជាអ្នកដំណើរថ្មើរជើង ឱ្យមានការប្រុងប្រយត្ន័កាន់តែខ្ពស់ជាងមុន ព្រមទាំងជួយកាត់បន្ថយ ក៏ដូចជាបញ្ចៀសនូវបញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដែលបានកើតឡើងជាយថាហេតុ។ រដ្ឋបាលខណ្ឌក៏បានធ្វើការបំពាក់នូវស្លាកសញ្ញាចរាចរណ៍នៅតាមផ្លូវសំខាន់ៗដែលសម្បូរទៅដោយមនុស្សធ្វើដំណើរជាពិសេសគឺផ្លូវជាតិលេខ១តែម្តង ដែលការដាក់ផ្លាកសញ្ញាចរាចរណ៍នោះមានដូចជាស្លាកសញ្ញាបំរាម សញ្ញាបញ្ជាំង សញ្ញាសិទ្ធិអាទិភាព សញ្ញាគ្រោះថ្នាក់ សញ្ញាបណ្តោះអាសន្ន សញ្ញាបង្ហាញ

---

[61] គេហទំព័រ http://nokorwatnews.com/archives/341058 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

[62] គេហទំព័រ http://www.google.com ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

ទិសដៅសញ្ញាបង្ហាញប្រាប់ទីប្រជុំជន និងព្រំប្រទល់តំបន់ សញ្ញាបង្ហាញព័ត៌មាន សញ្ញាផ្ដល់ដំណឹង សញ្ញាដាក់បន្ថែមពីក្រោម សញ្ញាប្រាប់ឈ្មោះតំបន់ និងសញ្ញាប្រាប់ឈ្មោះផ្លូវ។[63]

### ២.១.១.៣. ការរៀបចំសំណង់អគារតូច ធំ តាមដងផ្លូវ

ប្រទេសកម្ពុជា ជាប្រទេសដែលស្ថិតនៅក្រោមដំបូលសន្តិភាព អរគុណសន្តិភាព និងស្ថិតក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ទើបធ្វើឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់វិស័យទាំងអស់។ ជាក់ស្ដែងដូចជាវិស័យស្ថាបត្យកម្ម និងសំណង់ មានការរីកចម្រើនគួរឱ្យ កត់សម្គាល់ ជាពិសេសសន្ទុះនៃការកើនឡើងនូវចំនួនសំណង់អគារ តូច ធំ ខ្ពស់ ទាប ច្រើនម៉ូត ច្រើនសណ្ឋាននៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួនទៀត។

ខណ្ឌច្បារអំពៅក៏ជាខណ្ឌមួយដែលកំពុងក្លាយទៅជាតំបន់មួយក្នុងចំណោមតំបន់រីកលូតលាស់លឿនបំផុតដោយសារតែភាពជឿនលឿននៃសេដ្ឋកិច្ចរបស់ទីក្រុងនៅក្នុងវិស័យបច្ចេកវិទ្យា ការអភិវឌ្ឍថ្មីៗនៃវិស័យពាណិជ្ជកម្ម រួមទាំងវិស័យលំនៅដ្ឋាន និងអចលនទ្រព្យមានកំណើនជាបន្តបន្ទាប់ ដូចជាមានគម្រោងបុរីល្បីៗជាច្រើនបានបោះជំហានទៅកាន់ខណ្ឌច្បារអំពៅ គម្រោងឧទ្យាន Park Community Mall ដែលក្នុងគម្រោងនោះសម្បូរទៅដោយ សាលារៀនល្បីៗ ហាងកាហ្វេល្បីៗ ភោជនីយដ្ឋាន និងហាងលក់ទំនិញ ជាច្រើនទៀត។ មិនថែមទាំងសម្បូរទៅដោយអគារពាណិជ្ជកម្មតូច ធំជាច្រើនប៉ុណ្ណោះទេ ក្នុងនោះដែរក៏មានមន្ទីរពេទ្យធំៗ ធនាគារ សណ្ឋាគារ សំណង់អគាររដ្ឋដូចជា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នាយកដ្ឋានលិខិតឆ្លងដែន និងសាលារៀនរដ្ឋជាច្រើនទៀតផងដែរ។[64] ដោយឡែកបើទោះបីជាមានការរីកស្គុះស្គាយនៃសំណង់ អគារតូច ធំជាច្រើននៅក្នុងខណ្ឌក្តី ក៏យើងឃើញថា សំណង់អគារមួយចំនួនតូចស្ថិតនៅក្នុងភាពអនាធិបតេយ្យ ខ្វះសណ្ដាប់ធ្នាប់ និងបង្កភាពអសន្តិសុខដែលអាចប៉ះពាល់ដល់សោភ័ណភាពខណ្ឌ។ ដូចនេះការរៀបចំសំណង់អគារឱ្យមានរបៀបរៀបរយជាមូលដ្ឋានដ៏សំខាន់សម្រាប់គ្រប់គ្រងភាពអសកម្ម ឬបាតុភាពសង្គមផ្សេងៗ ដែលនឹងរួមចំណែកពង្រឹងសុវត្ថិភាព សន្តិសុខសង្គម ជម្រុញការគ្រប់គ្រងផ្នែកនគរូបនីយកម្មឱ្យកាន់តែប្រសើរ និងជាផ្នែកមួយជួយបង្កើនសម្រស់ សោភ័ណភាពដល់ទីក្រុងទាំងមូលផងដែរ។

ការរៀបចំសណ្ដាប់ធ្នាប់ សោភ័ណភាពមិនត្រឹមតែសម្រាប់អ្នកដែលរស់នៅផ្លូវគោកប៉ុណ្ណោះទេ សូម្បីតែអ្នករស់នៅតាមទឹកក៏ត្រូវរៀបចំឱ្យមានរបៀបរៀបរយផងដែរ។ ដូចនេះហើយទើបរដ្ឋបាលខណ្ឌ រួមនឹងមន្ត្រីពាក់ពន្ធ័ទាំងអស់បានបន្តចុះបេសកកម្ម ដឹកនាំកម្លាំងចំរុះ ចុះតាមដងទន្លេក្នុងភូមិសាស្ត្រខណ្ឌ ណែនាំ ជម្រុញដល់ម្ចាស់

---

[63] គេហទំព័រ https://lorkremlaw.files.wordpress.com/2014/09/e19e9fe19e89e19f92e19e89e19eb6e19e85e19e9ae19eb6e19e85e19e9ae19e8ee19f8de19e95e19f92e19e9be19ebce19e9ce19e82e19f84e19e80.pdf ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

[64] គេហទំព័រ https://free.facebook.com/762625803936611/posts/1044884679044054/?_rdc=1&_rdr ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

ចិញ្ចឹមត្រី ផ្ទះបណ្តែតទឹក ផ្ទះទូកតូចៗ និងសំណង់មិនរៀបរយលើផ្ទៃទន្លេ ឱ្យរុះរើ និងចល័តចេញពី ផ្ទៃទន្លេឱ្យទាន់ពេលវេលា មុនពេលការអនុវត្តវិធានការណ៍របស់រដ្ឋបាលខណ្ឌ។[65]

ដើម្បីធ្វើឱ្យខណ្ឌកាន់តែមានភាពស្រស់បំព្រង ក្លាយជាតំបន់លេចធ្លោ មានសោភ័ណភាពគួរជាទីគាប់ប្រសើរ មានសណ្តាប់ធ្នាប់ និងសន្តិសុខ ព្រមទាំងផ្តល់ជាទីផាសុខភាពសម្រាប់ប្រជាជននៅក្នុងខណ្ឌទៀតនោះ រដ្ឋបាលខណ្ឌបានយកចិត្តទុកដាក់បន្ថែមទៅលើចំណុចជាច្រើនទៀតដូចជា បានចេញធ្វើអនាម័យបោសសំអាត និងលាងសម្អាតផ្លូវជាតិលេខ១ ចាប់ពីគល់ស្ពានព្រះមុនីវង្ស រហូតដល់ផ្លូវបំបែកលេខ១១៤ (ផ្លូវថៃហ្គ័រ) ដើម្បីលើកកម្ពស់សោភ័ណភាព និងអនាម័យក្នុងខណ្ឌ ព្រមទាំងបានបាញ់ថ្នាំសម្លាប់មូស ថ្នាំសម្លាប់បាក់តេរីផ្សេងៗនៅតាមវត្តអារាម សាលារៀន មន្ទីរពេទ្យ និងកន្លែងដែលបាក់តេរី មេរោគចូលចិត្តសំងំពួននៅដែលអាចបង្កឱ្យមានជំងឺផ្សេងៗ ជាពិសេស ជំងឺកូវីដ១៩។[66]

### ២.១.២. ការរៀបចំសោភ័ណភាពនាពេលយប់

សោភ័ណភាពពេលយប់ គឺសម្តៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងមហាវិថីនានាក្នុងទីក្រុងជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រី នៅតាមសួនច្បារសាធារណៈផងដែរ។[67] ការលម្អសោភ័ណភាពនាពេលយប់មិនត្រឹមតែជាគ្រឿងលម្អតុបតែងតែប៉ុណ្ណោះទេតែជាការរៀបចំ ដែលធ្វើឱ្យទិដ្ឋភាពនៅក្នុងខណ្ឌមានភាពប្លែក ជួយបង្កើនសម្រស់ ភាពទាក់ទាញដល់ភ្ញៀវ ទេសចរណ៍ឱ្យមកកំសាន្តបែបលក្ខណៈគ្រួសារ ឬបែបមិត្តភាពផ្សេងទៀត ជាពិសេសអាចជួយបំភ្លឺផ្លូវដល់អ្នកដំណើរ ដែលនេះក៏អាចជួយកាត់បន្ថយនូវគ្រោះថ្នាក់ បានមួយកម្រិតផងដែរ។ ការរៀបចំសោភ័ណភាពនាពេលយប់រួមមាន ៖ ការបំពាក់ភ្លើងតាមដងផ្លូវ និងការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ។

#### ២.១.២.១. ការបំពាក់ភ្លើងតាមដងផ្លូវ

ការបំពាក់ភ្លើងតាមដងផ្លូវនាពេលយប់ ជាកត្តាមួយដែលសំខាន់ក្នុងការជួយលើកកម្ពស់សោភ័ណភាពនៅក្នុងខណ្ឌជាពិសេសគឺការបំភ្លឺផ្លូវនាពេលរាត្រីសម្រាប់អ្នកដំណើរដែលធ្វើដំណើរទៅវិញទៅមកតាមដងផ្លូវ។ ដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការ ព្រមទាំងការរក្សានូវសុខសុវត្ថិភាពរបស់ប្រជាជននៅតាមសង្កាត់នានាក្នុងខណ្ឌច្បារអំពៅ រដ្ឋបាលខណ្ឌ បានរៀបចំដាក់ឱ្យដំណើរការនូវការដាក់បង្គោលភ្លើងបំភ្លឺផ្លូវ ដើម្បីសម្រួលដល់ការធ្វើចរាចររបស់ប្រជាពលរដ្ឋ ជាពិសេសទប់ស្កាត់មិនឱ្យកើតមានបទល្មើសនៅក្នុងខណ្ឌនាពេលយប់។ ដូច្នេះហើយទើបរដ្ឋបាលខណ្ឌបានសហការជាមួយ ក្រុមការងារបច្ចេកទេសរបស់មន្ទីរសាធារណការ រាជធានីភ្នំពេញ

---

[65] គេហទំព័រ https://facebook.com/សាលាខណ្ឌច្បារអំពៅ/posts/11-06-2021 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

[66] គេហទំព័រ https://facebook.com/សាលាខណ្ឌច្បារអំពៅ/posts/03-04-2021 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

[67] គេហទំព័រ http://nokorwatnews.com/archives/356964 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

ដើម្បីដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវចំនួន២២៨ដើម ដាក់នៅតាមបណ្ដោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់និរោធ រហូតដល់ព្រំប្រទល់រវាងសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ និងស្រុកកៀនស្វាយ ខេត្តកណ្ដាល។ ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវនេះផងដែរ ក្រុមការងារបានចែកចេញជា២ផ្នែកគឺ ៖

- ផ្នែកទី១ ចាប់ពីគល់ស្ពានព្រះមុនីវង្ស ត្រើយខាងកើតទៅដល់សង្កាត់វាលស្បូវ ដែលបង្គោលភ្លើងទាំងនោះត្រូវដាក់នៅតាមបណ្ដោយសួនច្បារពុះចែកគន្លងផ្លូវ និងដាក់តាមចិញ្ចើមផ្លូវទាំងសងខាង។
- ផ្នែកទី២ បង្គោលភ្លើងបំភ្លឺផ្លូវ ចាប់ពីសង្កាត់វាលស្បូវទៅដល់ព្រំប្រទល់ស្រុកកៀនស្វាយ ដាក់នៅតាមបណ្ដោយផ្លូវទាំងសង្ខាង។[68]

បន្ថែមពីការដាក់បង្គោលភ្លើងតាមដងផ្លូវ និងផ្លូវសាធារណៈមួយចំនួនដូចជាផ្លូវចូលទៅកាន់លំនៅដ្ឋានដែលមានប្រជាពលរដ្ឋរស់នៅតាមសង្កាត់នានា ជាពិសេសរដ្ឋបាលខណ្ឌក៏បានយកចិត្តទុកដាក់លើការដាក់រៀបចំ ជួសជុលស្ពានព្រះមុនីវង្សចាស់ ដោយធ្វើការជួសជុលកម្រាលថ្មើរជើង បង្កាន់ដៃស្ពាន និងផ្លាស់ប្តូរបង្គោលភ្លើងបំភ្លឺផ្លូវចាស់ចេញ ដោយដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវថ្មីជំនួសវិញ។[69]

### ២.១.២.២. ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ

ចំពោះការបំពាក់ភ្លើងនៅតាមសួនច្បារយើងសង្កេតឃើញថា ខណ្ឌក៏បានយកចិត្តទុកដាក់ផងដែរ ដើម្បីធ្វើយ៉ាងណាលើកកម្ពស់សោភ័ណភាពតាមដងផ្លូវឱ្យកាន់តែ មានភាពស្រស់ស្អាតមួយ កម្រិតទៀត ដោយរដ្ឋបាលខណ្ឌបានដាក់ភ្លើងចម្រុះជាច្រើនពណ៌នៅតាមបង្គោលភ្លើងបំភ្លឺផ្លូវ តាមបណ្តោយសួនច្បារភ្លោះ ចាប់ពីគល់ស្ពានខាងកើតរហូតដល់សួនច្បារភ្លោះសង្កាត់វាលស្បូវ។ មិនតែប៉ុណ្ណោះរដ្ឋបាលខណ្ឌក៏បានបង្កើនការលម្អនៅតាមអគារមួយចំនួនដូចជា អគារសាធារណៈ អគារឯកជនជាដើម។ យើងក៏បានដឹងមកហើយថា បច្ចុប្បន្ននេះខណ្ឌច្បារអំពៅគឺ ជាខណ្ឌមួយដែលមានសក្តានុពលខ្លាំង ដែលពោរពេញទៅដោយសំណង់អគារ លក្ខណៈបែបបុរី ខុនដូ ផ្ទះល្វែង ដែលមានការលម្អ និងរំលេចទៅដោយភ្លើងពណ៌ចម្រុះជាច្រើនដែលធ្វើឱ្យ សំណង់អគារទាំងនោះមានភាពស្រស់ស្អាតលេចធ្លោទៅតាមការច្នៃប្រឌិតរបស់ម្ចាស់អគារនីមួយៗ។ ការបំពាក់ភ្លើងចម្រុះនៅតាមអគារទាំងនោះ យើងសង្កេតឃើញថាមានភាពកាន់តែពិសេសទៅទៀត គឺនៅថ្ងៃបុណ្យជាតិផ្សេងៗ មានការតុបតែង យ៉ាងល្អវិចិត្រនៅតាមអគារនីមួយៗ មិនតែប៉ុណ្ណោះវាក៏ជាផ្នែកមួយដែលទាក់ទាញនូវសាធារណៈជនឱ្យមកទស្សនា លេងកំសាន្ត និងមានការចាប់អារម្មណ៍ទៅលើសោភ័ណភាពរបស់ខណ្ឌផងដែរ។

[68] គេហទំព័រ http://nokorwatnews.com/archives/356964 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

[69] សេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ លេខ: ០២៦/២១ សជណ ចុះថ្ងៃទី០៧ ខែមេសា ២០២១ ស្តីពី "ការពង្វាងចរាចរណ៍នៅលើស្ពានព្រះមុនីវង្សចាស់"

## ២.២. ការបំពុលបរិស្ថាន និងដំណោះស្រាយ

ទន្ទឹមទៅនឹងការអភិវឌ្ឍឥតឈប់ឈរ និងការរីកចម្រើនស្ទើរតែគ្រប់វិស័យទាំងអស់ ក្នុងនោះដែរយើងសង្កេតឃើញថាបញ្ហាផ្សេងៗជាច្រើនក៏បានកើតមាន ជាហេតុដែលធ្វើឱ្យមានការប៉ះពាល់ដល់ការអភិវឌ្ឍនិងប៉ះពាល់ដល់សោភ័ណភាពរបស់ប្រទេស ឬរដ្ឋ។ សព្វថ្ងៃនេះ បញ្ហាបរិស្ថាន គឺជាបញ្ហាចម្បងមួយដែលបង្កនូវគ្រោះថ្នាក់ខ្លាំងក្លាជាងគេក្នុងចំណោមបញ្ហាដទៃទៀតដែលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈទាំងអស់។ ជាក់ស្តែងថ្វីត្បិតតែប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងអភិវឌ្ឍន៍យ៉ាងណាក្តី ក៏យើងឃើញពីសន្ទុះនៃការអភិវឌ្ឍយ៉ាងគំហុក ជាពិសេសវិស័យសេដ្ឋកិច្ច និងឧស្សាហកម្មធំ តូចគ្រប់ប្រភេទ ប៉ុន្តែដោយសារកំណើនប្រជាជន និងការរីកចម្រើនផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស នេះហើយទើបធ្វើឱ្យ មានការបង្កផលប៉ះពាល់ជាពិសេសបង្កឱ្យមានការបំពុលយ៉ាងខ្លាំងទៅដល់បរិស្ថាន។

ការបំពុលបរិស្ថាន គឺជាការបង្កភាពកង្វក់ទៅលើសារធាតុ និងជីវចម្រុះគ្រប់ប្រភេទ លើភពផែនដីតាមរយៈការបញ្ចេញសារធាតុពុលគ្រប់ទម្រង់រួមមាន រឹង រាវ និងឧស្ម័ន ដូចនេះបញ្ហានៃការបំពុលបរិស្ថាន គឺជាការព្រួយបារម្ភចម្បងមួយដែលប្រជាជន និងរដ្ឋាភិបាលកំពុងតែប្រឈមមុខ។ ការបំពុលបរិស្ថានដែលយើងតែងតែជួបប្រទះរួមមាន ការបំពុលទឹក ដី ខ្យល់ សំណល់ និងសំឡេង។[70] បន្ថែមពីមូលហេតុដែលធ្វើឱ្យមានការបំពុលបរិស្ថាន រាជរដ្ឋាភិបាលកម្ពុជាក៏បានរិះរកមធ្យោបាយដើម្បីទប់ស្កាត់ បង្ការ ការពារ និងដាក់ចេញនូវវិធានការដោះស្រាយចំពោះបញ្ហាដែលកើតឡើងទៅលើបរិស្ថាន។

### ២.២.១. ហេតុបង្កនាំឱ្យមានការបំពុលទឹក និងដំណោះស្រាយ

ទឹកមានសារៈសំខាន់ណាស់សម្រាប់ជីវិតប្រចាំថ្ងៃ មិនថាសម្រាប់ជីវិតមនុស្ស សត្វ ជីវៈមានជីវិត និងនៅក្នុងបរិស្ថាន។ ទឹកក៏បានដើរតួនាទី ជាផ្នែកមួយដែលសំខាន់ក្នុងការជួយជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសឱ្យមានភាពរីកចម្រើនលូតលាស់ដូចជាក្នុងវិស័យឧស្សាហកម្ម កសិកម្ម គមនាគមន៍ ទេសចរណ៍ និងតំបន់ទីក្រុង។ តែបើប្រភពទឹកដ៏សំខាន់នោះទទួលរងនូវការបំពុល ឬបង្កនូវភាពល្អក់កករ ក៏វាជាបញ្ហាគំរាមដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិដែលអាស្រ័យផលនឹងទឹកនោះផងដែរ។

ការបំពុលទឹក គឺជាការធ្វើឱ្យកង្វក់ដល់ទឹក នៅពេលដែលសារធាតុបំពុលនានាបានហូរចូល ទៅក្នុងប្រភពទឹក។ ការបំពុលទឹក គឺជាបញ្ហាប្រឈមដ៏ធំមួយដែលធ្វើឱ្យប៉ះពាល់ ស្ទើរតែគ្រប់ប្រទេសទាំងអស់ទូទាំងពិភពលោក។ សោភ័ណភាពបរិស្ថានអាចទទួលរងការជះឥទ្ធិពល អាក្រក់ខ្លាំងប៉ុណ្ណាពីការបំពុលទឹកគឺអាស្រ័យទៅតាមសកម្មភាពនៃការបំពុលនោះដែលភាគច្រើន កើតចេញពីទីកន្លែងមួយចំនួនដូចជា ទីក្រុង

[70] គេហទំព័រ https://opendevelopmentcambodia.net/km/topic/pollution-and-waste/#ref-74643-2 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

ទីប្រជុំជនទីកន្លែងកម្សាន្ត រមណីយដ្ឋាន និងទីសាធារណៈជាដើម។[71] កត្តាដែលអាចបង្កឱ្យមានការបំពុលទឹកមានដូចជា ៖

- ការបំពុលដោយសកម្មភាពមនុស្សដូចជា៖ ការបោះសំរាមចូលក្នុងទឹក ការបង្ហូរកាកសំណល់ផ្ទះបាយចូលក្នុងទឹក ការបន្ទោរបង់ ការបង្ហូរទឹកកង្វក់ ការបូមខ្សាច់ខុសបច្ចេកទេស។ល។
- ការបំពុលដោយសមាសធាតុគីមីដែលបង្ហូរចេញពីរោងចក្រឧស្សាហកម្ម និងសិប្បកម្មមួយចំនួនដូចជា៖ បារត សំណ កាឌីមីញ៉ូមនិងអាសេនិច ជីគីមី ថ្នាំសម្លាប់សត្វល្អិត
- ការបំពុលដោយអាកាសធាតុ តាមរយៈទឹកភ្លៀង ឬភ្លៀងអាស៊ីត
- ប្លាស្ទិក សំបកដបជ័រ ចូលទៅក្នុងទឹក
- កាកសំណល់វិទ្យុសកម្ម
- ជាតិពុលចេញពីកប៉ាល់ ទូក ឬនាវា ៖ ការលេចធ្លាយប្រេង សាំង ការបង្ហូរប្រេងចូលក្នុងទឹក
- ការបង្ហូរកាកសំណល់ចេញពីរោងចក្រ ឧស្សាហកម្ម ចូលក្នុងទឹក ។[72]

សកម្មភាពនៃការបំពុលទឹកជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើបរិស្ថាន ហើយក៏ប៉ះពាល់ដោយផ្ទាល់ និងប្រយោលដល់ មនុស្ស សត្វ រុក្ខជាតិ ព្រមទាំងសោភ័ណភាពនៃទីក្រុង ឬតំបន់សាធារណៈផ្សេងៗផងដែរ។ តាមរយៈការប្រើប្រាស់ និងបរិភោគទឹកមិនស្អាត អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាពជាច្រើនដូចជាជម្ងឺគ្រុនពោះវៀន គ្រុនចាញ់ អាសន្នរោគ រលាកថ្លើម ឃ្លង់ គ្រុនលឿន រាគ និងជម្ងឺផ្សេងៗជាច្រើនទៀត។ មិនតែប៉ុណ្ណោះការបំពុលទឹកក៏ប៉ះពាល់ដល់វិស័យមួយចំនួនផងដូចជា វិស័យកសិកម្ម គឺនៅពេលដែលយើងយកទឹកដែលពោរពេញទៅដោយសារធាតុគីមីបង្កឡើងដោយកាកសំណល់រឹង ប្លាស្ទិកដែលកប់ក្នុងដី ឬត្រាំនៅក្នុងទឹក សារធាតុបារត សំណ កាឌីមីញ៉ូម អាសេនិច ជីគីមី ថ្នាំសម្លាប់សត្វល្អិត ភ្លៀងអាស៊ីតដែលបង្អុលចុះក្នុងប្រភពទឹក ហើយយើងក៏បានយកទឹក ដែលមានសារធាតុគីមីនោះមកប្រើប្រាស់ ស្រោចស្រពលើដំណាំ ផល្លានុផលផ្សេងៗ ដែលអាចបង្កឱ្យដំណាំ ឬផលទាំងនោះរលួយ ខូចគុណភាព និងអាចបង្កហេតុអាក្រក់ដល់មនុស្សសត្វទៀតផង។

- **វិធានការដោះស្រាយចំពោះបញ្ហាបំពុលទឹក**

ចំពោះបញ្ហាមួយៗដែលកើតឡើង តែងតែមានវិធានការក្នុងការបង្ការ ទប់ស្កាត់ និងដំណោះស្រាយជានិច្ច។ សម្រាប់បញ្ហាបំពុលទឹកក៏ដូចគ្នា ក៏មានវិធានការដោះស្រាយដូចជា ៖

[71] គេហទំព័រ https://healthcambodia.com/p6241/ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

[72] គេហទំព័រ https://km.warbletoncouncil.org/causas-consecuencias-contaminacion-agua-11450#menu-3 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

- កម្រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ
- ហាមឃាត់ជាដាច់ខាតរាល់ការចោល ឬការបង្ហូរចេញនូវសំណល់រាវពីប្រភពបំពុលដែលផ្ទុយពីកម្រិតស្តង់ដារដែលបានកំណត់
- ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រពន្ធ័លូសាធារណៈ
- ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅដ្ឋាន ឬអគារសាធារណៈចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រពន្ធ័លូសាធារណៈ ឬប្រពន្ធ័ចម្រោះសំអាតនានា។[73]
- អប់រំប្រជាជនឱ្យយល់ដឹងពីផលប៉ះពាល់ពីការចោលសំរាមទៅក្នុងទឹក និងផលប៉ះពាល់ដល់បញ្ហាសុខភាព។
- រៀបចំឱ្យមានអាងប្រព្រឹត្តកម្ម អាងចម្រោះសំអាត មុននឹងបង្ហូរទឹកកខ្វក់ ឬទឹកស្អុយចូលទៅក្នុងប្រភពទឹក។
- ចាត់វិធានការច្បាប់ឱ្យបានតឹងរឹងបំផុតដោយទទួលការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់កំណត់។

### ២.២.២. ហេតុបង្កនាំឱ្យមានការបំពុលដី និងដំណោះស្រាយ

ការបំពុលដី គឺជាដំណើរការនៃការរិចរិលគុណភាព នៃផ្ទៃផែនដីបណ្តាលមកពីសារធាតុគីមី និងដំណើរការផ្សេងទៀត នៃអន្តរាគមន៍របស់មនុស្ស។[74] ការបំពុលដីជាបញ្ហាប្រឈមមួយដែលគួរឱ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ន បើទោះបីជាវាមិនសូវជះឥទ្ធិពលដល់អ្នករស់នៅកណ្តាលទីក្រុងប៉ុន្មានក៏ដោយ។ ប៉ុន្តែការបំពុលដីនៅតែជាបញ្ហាប្រឈមមួយចំពោះអ្នកដែលរស់នៅប្រកបរបរកសិកម្មនៅតាមបណ្តាខេត្ត។ ការបំពុលដីធ្វើឱ្យប៉ះពាល់ជាច្រើនដល់វិស័យកសិកម្មដូចជា ការបំពុលធ្វើឱ្យដីបាត់បង់នូវជីវជាតិនាំឱ្យទិន្នផលកសិកម្មមានការធ្លាក់ចុះបាត់បង់ប្រពន្ធ័អេកូឡូស៊ី។ សោភ័ណភាពបរិស្ថានអាចទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ប្រសិនបើទីក្រុង ឬប្រទេសពោរពេញទៅដោយសំរាម ។ កត្តាធំចំបងមួយដែលបណ្តាលឱ្យដីទទួលរងការបំពុលខ្លាំងជាងគេ គឺការបំពុលដោយសំរាម ឬកាកសំណល់។ សំរាមកើតមានឡើងគ្រប់ទិសទី មិនប្រកាន់ថានៅទីណា នៅប្រទេសណាឡើយ។ ការទុកដាក់សំរាមមិនបានត្រឹមត្រូវ ឬចោលពាសវាលពាសកាលទៅលើដី គឺជាហេតុដែលបណ្តាលឱ្យមានការប៉ះពាល់ដល់ដី ជាពិសេសចំពោះប្រភេទនៃសំរាម ដែលមិនបានកែច្នៃឡើងវិញបាន ឬកាកសំណល់ផ្ទះបាយ។ ការគរសំរាមនៅទីកន្លែងណាមួយរយៈពេលយូរដូចជា ទីលានចាក់សំរាមជាដើម គឺអាចបណ្តាលឱ្យដីនៅកន្លែងនោះខូចគុណភាព ឬបាត់បង់ជីវជាតិ។ សំរាមមួយចំនួនដែលកប់ក្នុងដីត្រូវប្រើរយៈ

[73] មាត្រា៤ មត្រា៦មាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យ លេខ២៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ “ស្តីពីការត្រួតពិនិត្យការបំពុលទឹក”

[74] គេហទំព័រ https://km.warbletoncouncil.org/contaminaction-del-suelo-3188 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

ពេលយូរណាស់ទើបអាចរលាយអស់ទាំងស្រុង (ប្លាស្ទិក កំប៉ុង ឬដបជ័រ) ខណៈដែលសំរាមមួយចំនួនទៀតមានផ្ទុកសារធាតុពុលជាហេតុ បណ្តាលឱ្យដីទទួលរងនូវការខូចទ្រុងទ្រោយ គុណភាព មិនអាចយកមកប្រើប្រាស់បាន។

កត្តាផ្សេងៗទៀតដែលបណ្តាលឱ្យមានការបំពុលដី រួមមាន ៖

- ការប្រើប្រាស់ជីគីមី ថ្នាំពុល ថ្នាំសម្លាប់សត្វល្អិត
- ការបន្ទុះភ្នំភ្លើង កំអែលភ្នំភ្លើង ផេះពីកំអែលភ្នំភ្លើង រញ្ជួយដី
- កាកសំណល់ឧស្សាហកម្ម សហគ្រាស
- ការបំពុលដោយកសិកម្ម

ការបំពុលដី មិនត្រឹមតែអាចបង្កឡើងតាមកត្តាមួយចំនួនខាងលើប៉ុណ្ណោះទេ ការបំពុលអាចកើតតាមរូបភាពជាច្រើនទៀតដូចជា ប្រសិនបើសត្វពាហនៈ ដើររកចំណីនៅកន្លែងដែលគេចោលសំរាម ហើយមនុស្សបរិភោគ ឬចាប់សត្វទាំងនោះ ពួកយើងអាចនឹងមានជម្ងឺ ហើយនៅពេលដែលមានសំណល់អសរីរាង្គច្រើនត្រូវបានគេដុតនៅលើដី វាក៏អាចបង្កឱ្យមានការបំពុលដីផងដែរ។[75]

❖ **វិធានការដោះស្រាយចំពោះបញ្ហាបំពុលដី**

ចំណាត់ការ និងដំណោះស្រាយទៅលើបញ្ហានៃការបំពុលដីរួមមាន ៖

- សិក្សាពីរូបធាតុផ្សំ និង ផលប៉ះពាល់នៃជីគីមី
- ប្រើប្រាស់ជីគីមីក្នុងបរិមាណសមល្មម
- ប្រើប្រាស់ជីធម្មជាតិ (ជីកំប៉ុស)
- បញ្ឈប់នូវការប្រើជីគីមីដែលស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់
- បញ្ឈប់រាល់សកម្មភាពនៃការបង្ហូរទឹកកខ្វក់
- បញ្ឈប់រាល់សកម្មភាពនៃការចាក់ចោលសំរាម ឬសំណល់រឹងទៅលើដី
- រៀបចំឱ្យមានកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
- ជម្រុញឱ្យប្រើប្រាស់របស់ដែលអាចកែច្នៃឡើងវិញបាន
- កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ដប ឬកំប៉ុងជ័រ
- អប់រំដល់ប្រជាជនអំពីផលប៉ះពាល់នៃបរិស្ថាន ផលវិបត្តិនៃការបំពុលដី ដែលអាចប៉ះពាល់ដល់សុខភាពនិងជីវិតរបស់សត្វ រួមទាំងបរិស្ថានទាំងស្រុង។

[75] គេហទំព័រ http://livelearn.org/assets/media/docs/resources/GoodPeople_GoodEnv_flipchart_khm.pdf ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

- ចាត់វិធានការច្បាប់ឱ្យបានតឹងរឹងបំផុតចំពោះជនដែលល្មើសដោយទទួលការផាកពិន័យឬផ្តន្ទាទោសតាមច្បាប់កំណត់។

### ២.២.៣. ហេតុបង្កនាំឱ្យមានការបំពុលខ្យល់ និងដំណោះស្រាយ

ខ្យល់ត្រូវបានបំពុលនៅពេលវាប៉ះពាល់ទៅនឹងភាពកខ្វក់នៃឧស្ម័នពុលនិងភាគល្អិតតូចៗដែលបញ្ចេញដោយរោងចក្រឧស្សាហកម្ម មធ្យោបាយដឹកជញ្ជូនទៅក្នុងបរិយាកាសខាងក្រៅ។[76] ជាទូទៅការបំពុលខ្យល់មានសភាពធ្ងន់ធ្ងរនៅក្នុងទីក្រុង តំបន់ឧស្សាហកម្ម តំបន់ទំនាប ឬតំបន់ដែលឡោមពទ្ធ័ដោយភ្នំ និងកន្លែងមានខ្យល់បក់មិនល្អ មិនបរិសុទ្ធ និងការបំពុលខ្យល់អាចកើតចេញពីកត្តាជាច្រើនដូចជា ៖

- ការដុតឥន្ទនៈហ្វូស៊ីល (ប្រេង ធ្យូង ម៉ាស៊ូត សាំង)
- ផេះពីការផ្ទុះភ្នំភ្លើង
- ចំហេះចេញពីគ្រឿងចក្រចាស់ៗ រថយន្ត ម៉ូតូ រថភ្លើង ម៉ាស៊ីនត្រជាក់
- ផ្សែងពុលចេញពីរោងចក្រឧស្សាហកម្មធំៗ សហគ្រាស
- ឧស្ម័នផ្ទះកញ្ចក់
- ផ្សែងពុលចេញពីឈាបនដ្ឋាន
- ការបំពុលដោយធូលី
- ការបម្រែបម្រួលអាកាសធាតុ
- ភ្លៀងអាស៊ីត។

ការបំពុលខ្យល់មិនត្រឹមតែធ្វើការបំផ្លាញទៅលើអាកាសធាតុ បរិស្ថានទេ ជាពិសេសគឺបំផ្លាញយ៉ាងខ្លាំងដល់សុខភាពមនុស្ស សត្វពីព្រោះថាជីវិតមនុស្សត្រូវការខ្យល់ដើម្បីដកដង្ហើម និងបំលាស់ប្តូរឧស្ម័ននៅក្នុងខ្លួន តែបើយើងរស់នៅជាមួយបរិស្ថានដែលពោរពេញទៅដោយការបំពុលគ្រប់បែបយ៉ាង និងស្រូបដោយខ្យល់ពុលជាច្រើនជារៀងរាល់ថ្ងៃនោះវាអាចបណ្តាលឱ្យយើងប្រឈមនឹងជម្ងឺដូចជា ជម្ងឺមហារីក រលាកសួតធ្ងន់ធ្ងរ រ៉ាំរ៉ៃ ការគាំងបេះដូង ការដាច់សរសៃឈាមខួរក្បាល មហារីកសួត ជាពិសេសជម្ងឺទាក់ទងនឹងប្រពន្ធ័ផ្លូវដង្ហើមជាច្រើនទៀត។[77] ដូច្នេះហើយទើបយើងត្រូវមានចំណាត់ការទៅលើបញ្ហាបំពុលខ្យល់ឱ្យបានឆាប់រហ័សបំផុត។

---

[76] គេហទំព័រ https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health:ការបំពុលខ្យល់ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

[77] គេហទំព័រ https://km.eferrit.com/និយមន័យនៃការបំពុលខ្យល់/ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

❖ **វិធានការដោះស្រាយចំពោះបញ្ហាបំពុលខ្យល់**

ចំពោះបញ្ហាបំពុលខ្យល់នេះដែរ យើងក៏មានវិធានការដើម្បីកាត់បន្ថយ ទប់ស្កាត់ និងដោះស្រាយផងដែរ ដូចជា ៖

- កាត់បន្ថយការប្រើប្រាស់គ្រឿងចក្រចាស់ៗដោយរាជរដ្ឋាភិបាលត្រូវជម្រុញប្រជាជនឱ្យប្រើប្រាស់មធ្យោបាយសាធារណៈ ដូចជារថយន្តក្រុងថ្មីៗ ឬប្រើប្រាស់ឧបករណ៍ដើរដោយអាគុយឬ ថាមពលពន្លឺព្រះអាទិត្យ ។
- កាត់បន្ថយការនាំចូលយានយន្តចាស់ៗ និងបន្ថយពន្ធនាំចូលយានយន្តថ្មីៗ
- រឹតបន្តឹងច្បាប់ចំពោះការដ្ឋាន និងឡានដឹកដីខ្សាច់ដែលខុសទៅនឹងបំរាម
- បញ្ឈប់ឱ្យមានការបូជាសពនៅក្នុងទីក្រុង
- បង្កើតឱ្យមានប្រពន្ធ័បន្សុទ្ធខ្យល់
- កាត់បន្ថយការដុតសំណល់កសិកម្ម និងការដុតឈើ ដើម្បីកាត់បន្ថយកម្រិតផ្សែងនិងកាបូនឌីអុកស៊ីតនៅក្នុងខ្យល់
- ពន្យល់ប្រជាជនពីផលប៉ះពាល់នៃការបំពុលខ្យល់
- ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស
- ហាមឃាត់ដាច់ខាតនូវការនាំចូល និងផលិតនូវសារធាតុឆេះដែលមានជាតិស្អាន់ធ័រ
- ការបង្ហូរ ឬការធ្វើឱ្យលេចធ្លាយនូវសារធាតុឆេះ ប្រេងឥន្ធនៈ
- ហាមឃាត់ការបញ្ចេញវិទ្យុសកម្ម ឬសារធាតុគីមីទៅក្នុងបរិយាកាស។
- ចាត់វិធានការច្បាប់ឱ្យបានតឹងរឹងបំផុតចំពោះជនដែលល្មើសដោយទទួលការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់កំណត់។[78]

### ២.២.៤.ហេតុបង្កនាំឱ្យមានការបំពុលដោយសំណល់ និងដំណោះស្រាយ

ប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍដទៃទៀត បញ្ហាបរិស្ថានជាបញ្ហាចោទដ៏ធំមួយ ដែលពិបាកគេច ក្នុងនោះការចោល និងការគ្រប់គ្រងសំណល់ក៏ជាបញ្ហាចម្បងក្នុងចំណោម បញ្ហាដែលបំពុលដល់បរិស្ថាន។ ការបញ្ចេញកាកសំណល់ មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹង កំណើនប្រជាជនដែលនេះជាការព្រួយបារម្ភយ៉ាងខ្លាំងទៅលើបញ្ហាបរិស្ថាន សុខភាពមនុស្ស និងខូចសោភ័ណភាពថែមទៀតផង។ សំណល់ ឬសំរាមប្រភេទណាក៏ដោយក៏ជាប្រភព និងជម្រកនៃមេរោគដែរ សំណល់មិនថារឹង ឬរាវទេ សុទ្ធតែកើតចេញពីការរៀបចំទុកដាក់

[78] មាត្រា៨ ១០ មាត្រា១១ និងមាត្រា១២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពី "ការត្រួតពិនិត្យការបំពុលខ្យល់-និងការរំខានដោយសំលេង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

របស់មនុស្សទាំងអស់ តែបើខ្វះខាតការអនុវត្តការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវទេនោះ វានៅតែជាបញ្ហាចោទ និងជាសម្ពាធដ៏ធំសម្រាប់បរិស្ថានដដែល។[79]

❖ **ការបំពុលដោយសំណល់រឹង**

សំណល់រឹង គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់របរកំទិចកំទីដែលលែងត្រូវការ ឬប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។

ដើម្បីជាភាពងាយស្រួលក្នុងការប្រមូល ដឹកជញ្ជូន ចាត់ចែងនិងគ្រប់គ្រងសំណល់រឹងឱ្យបានល្អ គេបានធ្វើការបែងចែកប្រភេទនៃសំណល់រឹងទៅតាមប្រភពដែលបង្កើតវា ដោយចែកចេញជាច្រើនប្រភេទផ្សេងៗដូចជា៖ សំណល់លំនៅដ្ឋាន ឧស្សាហកម្ម មន្ទីរពេទ្យ ពាណិជ្ជកម្ម និងសំណល់កសិកម្ម។ មិនត្រឹមតែបែងចែកជាប្រភេទប៉ុណ្ណោះទេ គេថែមទាំងចែកចំណាត់ថ្នាក់ជា២ គឺ សំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់មិនគ្រោះថ្នាក់ ឬសំណល់ធម្មតា។ សំណល់ប្រកបដោយគ្រោះថ្នាក់គឺ សំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជម្ងឺមហារីក ចម្លងជម្ងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិតបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់ភាគច្រើនមានប្រភពចេញពីលំនៅដ្ឋាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មផ្សេងៗ។[80] សំណល់គ្រោះថ្នាក់ភាគច្រើនមានប្រភពចេញពីឧស្សាហកម្ម ដូចជារោងចក្រធ្វើអាគុយ រោងចក្រធ្វើសង្ក័សី រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត ឧស្សាហកម្មថ្នាំពេទ្យ ឧស្សាហកម្មថ្នាំលាប ឬឧស្សាហកម្ម សហគ្រាសដែលប្រើប្រាស់សារធាតុគីមីច្រើន និងសារធាតុប្រកបដោយគ្រោះថ្នាក់ខ្ពស់។

ចំណែកឯសំណល់នៅតាមលំនៅដ្ឋានក៏អាចមានសារធាតុប្រកបដោយគ្រោះថ្នាក់ដែរតែមានកម្រិតតិចតួច ចំណែកវិស័យកសិកម្មវិញ ដោយសារតែបច្ចេកទេសរបស់យើងនៅមានកម្រិតទាប កសិករភាគច្រើនប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានជាតិពុលខ្លាំង និងប្រើប្រាស់ជាតិគីមីច្រើនដើម្បីបង្កើនទិន្នផលដំណាំ ដូច្នេះសារធាតុប្រកបដោយគ្រោះថ្នាក់មួយចំនួនក៏ត្រូវបានកើតឡើងតាមរយៈវិស័យនេះផងដែរ។ សំណល់រឹងជាប្រភព និងទីជម្រកនៃពពួកមេរោគឆ្លង ព្រមទាំងសត្វល្អិតចង្រៃជាច្រើន។ តែយ៉ាងណា សំណល់រឹងមួយចំនួនដែលមិនបង្កគ្រោះថ្នាក់ដូចជា សំណល់ផ្ទះបាយ ក្រដាសកាតុង ក្រណាត់ កែវ ផ្លាស្ទិកជាដើម នៅពេលដែលមិនទទួលបានការទុកដាក់បានត្រឹមត្រូវ ឬត្រូវបានបោះចោលសំណល់រាយប៉ាយ គ្រាន់អាចបង្កឱ្យមានក្លិនស្អុយ ឬកកស្ទះប្រពន្ធ័លូ តាមរយៈការហូរនាំដោយទឹកភ្លៀង ដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាព និងសណ្តាប់ធ្នាប់

[79] គេហទំព័រ https://opendevelopmentcambodia.net/km/topics/pollution-and-waste/ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

[80] មាត្រា៣ នៃអនុក្រឹត្យ លេខ៣៦ អនក្រ.បក ស្តីពី "ការគ្រប់គ្រងសំណល់រឹង" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

សាធារណៈតែប៉ុណ្ណោះ។ ប៉ុន្តែចំពោះសំណល់រឹងប្រកបដោយគ្រោះថ្នាក់ ដែលមានផ្ទុកនូវសារធាតុពុលវិញ អាច ជះឥទ្ធិពលអាក្រក់ដល់សុខភាពប្រជាជនដូចជា មានបញ្ហាខាងផ្លូវដង្ហើម កើតមានជម្ងឺសើស្បែក និងបណ្តាលឱ្យ កើតមាន ជម្ងឺរ៉ាំរ៉ៃផ្សេងៗ។ មិនតែប៉ុណ្ណោះ ចំពោះអ្នករើសអេតចាយ ឬអ្នកដែលរស់នៅជុំវិញទីលានចាក់សំណល់ រឹងគឺងាយនឹងរងគ្រោះថ្នាក់ដោយការមុត ឬប៉ះពាល់សំណល់ដោយផ្ទាល់ ខណៈដែលការយល់ដឹងពីបញ្ហា អនាម័យ និងសុខភាពរបស់ពួកគាត់មានកម្រិតទាប។[81]

❖ **ការបំពុលដោយសំណល់រាវ**

សំណល់រាវ គឺសំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុ បំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[82] សំណល់រាវដែលបញ្ចេញពីគ្រប់ប្រភពដូចជា លំនៅដ្ឋាន ឧស្សាហកម្ម មន្ទីរពេទ្យ ឬអាចជាសំណល់សល់ពីការធ្វើពាណិជ្ជកម្ម គឺសុទ្ធតែជាហេតុបង្កឱ្យមានការ បំពុលដល់បរិស្ថាន។ សំណល់រាវអាចមានដូចជា សំណល់ពីការបន្ទោរបង់ ការបោកខោអាវ ការលាងបន្លែផ្លែឈើ ត្រីសាច់ សំណល់រាវចេញពីរោងចក្រ សំណល់ដែលសល់ពីឧស្សាហកម្មគីមីមាន ឧស្សាហកម្មប្រេង ឧស្សាហកម្មតម្បាញ ឧស្សាហកម្មលោហធាតុ និងសំណល់វេជ្ជសាស្ត្រដូចជា ឈាម ទឹករំអិលជាដើម។ ដូចនេះ ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានល្អទេនោះការបំពុល ក៏ដូចជាផលប៉ះពាល់ជាច្រើនអាចកើតមានឡើងចំពោះ សោភ័ណភាព បរិស្ថាន សុខភាពមនុស្ស សត្វ និងរុក្ខជាតិ។[83] សំណល់រាវដែលមានសារធាតុគីមី ធ្វើឱ្យប៉ះពាល់ ដល់សោភ័ណភាព បង្កឱ្យប្រភពទឹកសាធារណៈមានក្លិនមិនល្អ។ល។ សារធាតុគីមីពុលប្រកបគ្រោះថ្នាក់ដូច ជា ក្លយអរ ផូស្វរ ស៊ីលីស្យូម អាម៉ូញ៉ាក់ នីទ្រីត អាចធ្វើឱ្យដីនិងទឹកខូចគុណភាព ព្រមទាំងបង្កគ្រោះថ្នាក់ដល់ សុខភាពមនុស្ស សត្វនិងជីវៈចម្រុះ។[84] ចំពោះមនុស្សអាចបង្កភាពប៉ះពាល់ខ្លាំង ជាពិសេសទៅលើបញ្ហាសុខ ភាពដូចជាជម្ងឺគ្រុនពោះវៀន គ្រុនចាញ់ រាគរូស ជាដើម។ មនុស្សអាចឆ្លងជម្ងឺតាមរយៈការបរិភោគ ប្រើប្រាស់ទឹក ដែលមានសារធាតុពុល ឬអាចមកពីភ្នាក់ងារចម្លងដូចជា សត្វរុយ សត្វជ្រូក ឆ្មា និងសត្វពាហនៈដែលដើរលុក លុយក្នុងគំនរសំរាម។ ដូចនេះចំពោះបញ្ហាបំពុលដោយសំរាម ឬកាកសំណល់មិនថារឹង ឬរាវសុទ្ធតែបង្កភាព

[81] គេហទំព័រ http://mekonginfo.org/assets/midocs/0002192-environment-solid-waste-managementtraining-material.pdf ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

[82] មាត្រា៤ អនុក្រឹត្យ លេខ២៣៥ អនក្រ.បក "ស្តីពីការគ្រប់គ្រងប្រពន្ធ័លូ និងប្រពន្ធ័ប្រព្រឹត្តកម្មទឹកកខ្វក់" ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៧

[83] សារណាបញ្ចប់ការសិក្សា"ការរៀបចំសណ្តាប់ធ្នាប់និងសោភ័ណភាពខណ្ឌចំការមន" របស់និស្សិតឈ្មោះក.ហុង ដានេ និងក.លី សុជាតា សាស្ត្រាចារ្យណែនាំ បណ្ឌិត ហាប់ ផល្លី ឆ្នាំ២០១៨ ,ទំព័រទី២៧ ,ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

[84] ការវាយតម្លៃបឋមលេខយោង ០០០០១៤/system no.36 ប្រកាសស្តីពីការគ្រប់គ្រងសំណល់រាវដែលមានសារធាតុគីមីពុល កាលបរិច្ឆេទ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣

មហន្តរាយដល់ជីវិតមនុស្ស សត្វ រុក្ខជាតិ និងជីវៈចម្រុះ មិនតែប៉ុណ្ណោះធ្វើឱ្យបរិស្ថាន និងសោភ័ណភាពមិនមានភាពស្រស់បំព្រងទៀត។

❖ **ការគ្រប់គ្រងសំណល់រឹង-រាវ**

- ណែនាំដល់ប្រជាជនឱ្យមានការយល់ដឹងអំពីការបែងចែកសំណល់ទៅតាមប្រភេទដូចជា ត្រូវវេចខ្ចប់ ទុកដាក់សំរាម-សំណល់រឹង ដែលអាចបង្កគ្រោះថ្នាក់ដូចជា អំបែងកែវ អំបែងដប កញ្ចក់ ម្ជុល និងវត្ថុបង្កគ្រោះថ្នាក់ផ្សេងទៀតចូលទៅក្នុងថង់ពណ៌ក្រហម ឬធ្វើជាសញ្ញាសម្គាល់ដើម្បីបញ្ជាក់ប្រាប់ដល់កម្មករប្រមូលសំរាមឱ្យមានការប្រុងប្រយត្ន័។[85]
- ការញែកសំណល់មាន២គឺ ការញែកសំណល់នៅតាមលំនៅដ្ឋាន និងការញែកសំណល់នៅតាមទីសាធារណៈដូចជា រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម។ការញែកសំណល់នៅតាមលំនៅដ្ឋានរួមមាន៖ សំណល់ដែលប្រកបដោយគ្រោះថ្នាក់ (ថ្មពិល អាគុយ កំប៉ុងថ្នាំសម្លាប់សត្វ និងកំប៉ុងដែលមានសារធាតុគីមី។ល។) និងការញែកសំណល់សម្រាប់កែច្នៃ (ក្រដាស អំបែង ដប ឬកែវ និងសារធាតុប្លាស្ទិក)។ ចំពោះការញែកសំណល់នៅតាមទីសាធារណៈដូចជា រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្មមានលក្ខណៈស្មុគស្មាញជាងនៅតាមលំនៅដ្ឋាន ដូចនេះគេក៏បានប្រើប្រាស់ធុងទៅតាមប្រភេទ និងទៅតាមពណ៌ដើម្បីជាភាពងាយស្រួល ក្នុងការប្រមូល និងគ្រប់គ្រង។
- ការប្រើប្រាស់ធុងសំរាមទៅតាមពណ៌ និងប្រភេទនៅតាមទីសាធារណៈដូចជា ៖សំណល់ផ្ទះបាយ (តំណាងឱ្យធុងពណ៌បៃតង) សំណល់ប្លាស្ទិក (តំណាងឱ្យធុងពណ៌លឿង) និងសំណល់គ្រោះថ្នាក់(តំណាងឱ្យធុងពណ៌ក្រហម)។ ក្រៅពីដាក់ពណ៌ធុងហើយ ក្រសួងនៅបានបន្ថែម logo ឬរូបដើម្បីបង្កជាភាពងាយស្រួលដល់ប្រជាជនក្នុងការបោះសំរាម។
- ការប្រមូល និងដឹកជញ្ជូនសំរាមអាជ្ញាធរបានអនុវត្តនូវវិធីសាស្ត្រដូចជាការប្រមូលនៅតាមលំនៅដ្ឋាន ការប្រមូលតាមសហគមន៍ និងការប្រមូលតាមចិញ្ចើមផ្លូវ។ ជាក់ស្តែងរដ្ឋបាលខណ្ឌច្បារអំពៅបានដឹកនាំកម្លាំងសណ្តាប់ធ្នាប់ ធ្វើការកើបប្រមូលសំរាម ពីគល់ស្ពានច្បារអំពៅដល់ស្ពានព្រែកសំរោង ដើម្បីកាត់បន្ថយសំរាមដែលស្អុយរលួយ ធ្វើឱ្យប៉ះពាល់ដល់បរិស្ថានសោភ័ណភាពនៅក្នុងខណ្ឌ។[86]

---

[85] សេចក្តីណែនាំ លេខ០០៩/១៩ សណន.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

[86] គេហទំព័រ https://www.cpp.org.kh/details/238080 ដកស្រង់ថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០២១

❖ **វិធានការដោះស្រាយចំពោះបញ្ហាបំពុលដោយសំណល់រឹង និងសំណល់រាវ**

កាលណាមានហេតុបង្ក មានផលប៉ះពាល់នោះដំណោះស្រាយក៏ត្រូវកើតមានដែរ។ ដោយសារឃើញពីបញ្ហា និងផលប៉ះពាល់នៃការបំពុលដោយសំណល់ទាំងរឹង ទាំងរាវ ទើបធ្វើឱ្យរាជរដ្ឋាភិបាលបានស្វះស្វែងរកវិធានការដើម្បីទប់ស្កាត់ បង្ការ និងដោះស្រាយទៅលើបញ្ហានោះដូចជា ៖

- ការបោះចោលសំរាមឱ្យបានត្រឹមត្រូវទៅតាមការវេចខ្ចប់ និងទុកដាក់ក្នុងធុងទៅតាមប្រភេទឱ្យបានត្រឹមត្រូវ។
- ការកែច្នៃឡើងវិញនូវសារធាតុដែលអាចកែច្នៃបាន
- កែច្នៃនូវសំណល់ផ្ទះបាយ ឬសំណល់សរីរាង្គ ដោយបំលែងជាជីកំប៉ុស
- ចំពោះសំណល់វេជ្ជសាស្ត្រ ឬសំណល់ប្រកបគ្រោះថ្នាក់មួយចំនួន យកទៅដុតតាមបច្ចេកវិទ្យាដុតសំណល់។
- កាត់បន្ថយនូវការប្រើប្រាស់ថង់ប្លាស្ទិក ជំនួសវិញដោយការប្រើប្រាស់ស្លឹកឈើ ឬថង់ក្រដាសវិញ
- លើកទឹកចិត្តដល់ប្រជាជនក្នុងការប្រើប្រាស់នូវសម្ភារៈដែលបានកែច្នៃឡើងវិញ ជាពិសេសជម្រុញឱ្យមានការផលិតនូវសម្ភារៈដែលមិនប៉ះពាល់ដល់បរិស្ថាន។
- បង្រៀនប្រជាជនឱ្យយល់ដឹងអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូលដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន។
- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន។
- ចូលរួមដោះស្រាយបញ្ហានានាពាក់ពន្ធ័នឹងការងារសម្អាត ប្រមូល ដឹកជញ្ជូន សេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ពន្ធ័នឹងសំរាម សំណល់រឹងទីប្រជុំជន។[87]

### ២.២.៥. ហេតុបង្កនាំឱ្យមានការបំពុលដោយសំឡេង និងដំណោះស្រាយ

ការបំពុលដោយសំឡេង ឬសំឡេង រំខានខ្លាំងៗដែលជះឥទ្ធិពលដល់បទដ្ឋាន នៃទីកន្លែងជាក់លាក់មួយ។ បើទោះបីសំឡេង រំខានមិនសូវបង្កជាផលប៉ះពាល់ ដូចការបំពុលផ្សេងៗក៏ដោយ ប៉ុន្តែពិតទៅវាអាចបង្កអន្តរាយដល់អាយុជីវិត រស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា។ ការបំពុលដោយសំឡេងរួមមាន សំឡេងចរាចរណ៍ សំឡេងយន្តហោះ សំឡេងរថភ្លើង សំឡេងតន្ត្រី ឧបករណ៍បំពងសំឡេង និងម៉ាស៊ីននៅក្នុងរោងចក្រជាដើម។ ការបំពុលដោយសំឡេងត្រូវបានចែកចេញជា២គឺ ប្រភពចល័ត និងប្រភពអចល័ត។

[87] អនុក្រឹត្យ លេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន"

ការបំពុលដោយប្រភពចល័ត សំដៅលើប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ ពោលគឺមិនឈប់ស្ងៀមនៅមួយកន្លែង ឬជាការបំពុលនោះអាចចេញពី យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។ រីឯប្រភពអចល័តវិញគឺ ប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែង ជាក់លាក់ ដែលការបំពុលនោះអាចចេញពី រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម សិប្បកម្ម គ្រឿងបំពងសំឡេងចេញពីកន្លែងកំសាន្ត ឬក្លឹបកំសាន្ត និងកសិដ្ឋានគ្រប់ប្រភេទ។ ការបំពុលសំឡេងបានផ្តល់ផលប៉ះពាល់ទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់មនុស្សដូចជា អាចបណ្តាលឱ្យមានការថប់អារម្មណ៍ តានតឹង ដែលអាចបង្កឱ្យជាជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរ បង្កឱ្យមានបញ្ហាបេះដូង អាចគាំង ឬដាច់សរសៃឈាម លោតចង្វាក់បេះដូង លើសសម្ពាធឈាម បំផ្លាញការចងចាំជាពិសេស គឺបញ្ហាហ៊ឹងត្រចៀក ដែលអាចធ្វើឱ្យបាត់បង់នូវលទ្ធភាពនៃការស្តាប់។ ដូច្នេះហើយទើបយើងត្រូវមានចំណាត់ការ ទៅលើបញ្ហាបំពុលខ្យល់ឱ្យបានឆាប់រហ័សបំផុត។

❖ **វិធានការដោះស្រាយចំពោះបញ្ហាបំពុលដោយសំឡេង**

ចំពោះបញ្ហាបំពុលសំឡេងនេះដែរ យើងក៏មានវិធានការដើម្បីកាត់បន្ថយ ទប់ស្កាត់ និងដោះស្រាយផងដែរដូចជា ៖

➢ ជៀសវាងការប្រើប្រាស់សំឡេងដែលមិនចាំបាច់មិនថាទាំងនៅក្នុងផ្ទះ ឬនៅកន្លែងធ្វើការជាដើម អ្នកជិតខាងត្រូវគោរពម៉ោងសម្រាកឱ្យគ្នាទៅវិញទៅមកជាពិសេសប្រសិនបើពួកគេរស់នៅក្នុង អគារ ឬល្វែង។

➢ ជៀសវាងការស្តាប់តន្ត្រី និងទូរទស្សន៍ក្នុងកម្រិតសំឡេងខ្ពស់ ព្រោះវាអាចធ្វើឱ្យ ខូចត្រចៀករបស់សមាជិកគ្រួសារ។

➢ មិនបំពង់សំឡេងលឺៗដូចជា ប្រើប្រាស់កាំជ្រួច ផាវនិងឧបករណ៍ផ្សេងៗដែលខុសពី ច្បាប់កំណត់មិនឱ្យមានការប្រើប្រាស់ខុសពេលខុសវេលា។[88] កម្រិតកំណត់ស្តង់ដារនៃការបញ្ចេញ សំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំណត់សំឡេងអតិបរិមាសម្រាប់ ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។

➢ ហាមឃាត់ដាច់ខាតនូវការបង្កឱ្យមានសំឡេងដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដាក់វិធានការច្បាប់ចំពោះជនណាដែលប្រព្រឹត្តល្មើសទៅនឹងបញ្ញាត្តិច្បាប់ប្រទេសកម្ពុជា។[89]

---

[88] ដកស្រង់ចេញពីគេហទំព័រ https://km.warbletoncouncil.org/tipos-contamination-acustica-16274 ចូលមើលថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០២១

[89] មាត្រា៣ មាត្រា៧ និងមាត្រា៩ នៃអនុក្រឹត្យស្តីពី "ការត្រួតពិនិត្យការបំពុលខ្យល់-និងការរំខានដោយសំលេង" លេខ៤២ អនក្រ.បក ចុះថ្ងៃទី០៩ មិថុនា ២០០០

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើអត្ថបទនេះរួចមកហើយ យើងយល់ឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌ គឺជាផ្នែកមួយដែលមានចាំបាច់បំផុត ក្នុងការជម្រុញ និងសម្រេចបាននូវទិសដៅនៃភាពជោគជ័យដើម្បីផ្លាស់ប្តូរនូវទីក្រុងមួយឱ្យក្លាយជាទីក្រុងដែលមានលក្ខណៈស្តង់ដារ។ យ៉ាងណាមិញយើងបានសង្កេតឃើញថា សកម្មភាពរបស់ខណ្ឌច្បារអំពៅដំណើរការបានយ៉ាងល្អ ដោយសកម្មភាពមួយនោះមានការសហការជាមួយប្រជាពលរដ្ឋ និងមន្ត្រីគ្រប់ជាន់ថ្នាក់ ដើម្បីដំណើរការកសាងអភិវឌ្ឍនៅក្នុងខណ្ឌមួយនេះផងដែរ។ ទោះបីជាខណ្ឌបានរៀបចំ ធ្វើការអភិវឌ្ឍ បានយ៉ាងច្រើនស្ទើរគ្រប់វិស័យក៏ពិតមែន ក៏ប៉ុន្តែយើងឃើញថាការអភិវឌ្ឍរបស់ខណ្ឌនៅតែមិនទាល់ទទួលបានលទ្ធផល ដូចការរំពឹងទុករបស់ផែនការអភិវឌ្ឍន៍របស់ខណ្ឌនៅឡើយ។ ជាក់ស្តែងបញ្ហាសណ្តាប់ធ្នាប់ និងសោភ័ណភាព គឺជាបញ្ហាចម្បងមួយ ដែលខណ្ឌកំពុងតែយកចិត្តទុកដាក់នៅក្នុងកែប្រែរៀបចំកសាង ហេដ្ឋារចនាសម្ព័ន្ធបន្ថែម ព្រមទាំងយកចិត្តទុកដាក់ទៅលើការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពដើម្បីឱ្យខណ្ឌមានការអភិវឌ្ឍជឿនលឿនជាងនេះទៅទៀត។ លើសពីនេះ យើងក៏បានដឹងហើយថា នៅក្នុងខណ្ឌនៅតែមានការជួបប្រទះទៅលើបញ្ហា ការកកស្ទះចរាចរណ៍ ប្រព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធបង្ហូរលូទឹកស្អុយមិនទាន់មានភាពត្រឹមត្រូវ ដែលវាបង្កមកពីការកកស្ទះសំរាម ការកសាង ឬជួសជុលប្រព័ន្ធផ្លូវថ្នល់ មិនទាន់ត្រឹមត្រូវ ទៅតាមស្តង់ដារនៅឡើយ ដែលជាហេតុនាំឱ្យខូចខាត លិចលង់ជាពិសេសទៅទៀតនោះនៅមានភាពខ្វះខាត ទៅលើការៀបចំប្រព័ន្ធលូ នៅតាមភូមិ ឬសង្កាត់នីមួយៗ ជូនប្រជាពលរដ្ឋនៅ ឡើយដែលជាហេតុនាំឱ្យមាន ការលំបាកដល់ប្រជាពលរដ្ឋ នៅក្នុងការរស់នៅ និងប្រកបអាជីវកម្មផងដែរ។

ក្រៅពីការស្វែងយល់ទៅលើហេដ្ឋារចនាសម្ពន្ធ័ និងបញ្ហាបរិស្ថាន នៅក្នុងតំបន់ក៏ជាកត្តាសំខាន់ដែលសម្រាប់ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព ឱ្យកាន់តែមានប្រសិទ្ធិភាព គុណភាពសំរាប់ការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទាំងមូល។ ដូចនេះហើយទើបរដ្ឋបាលខណ្ឌបន្ថែមការយកចិត្តទុកដាក់ទៅលើបញ្ហាដែលអាច បណ្តាលឱ្យមានការបំពុលដល់បរិស្ថានដូចជា បញ្ហាបំពុលទឹក បញ្ហាបំពុលដី បញ្ហាបំពុលខ្យល់ បញ្ហាបំពុលដោយសំណល់រឹង-រាវ និងបញ្ហាបំពុលដោយសំឡេងផងដែរ។ បញ្ហាទាំងនោះសុទ្ធសឹងជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន សុខមាលភាព របស់ប្រជាជន ជាពិសេសសោភ័ណភាពនៅក្នុងខណ្ឌអាចមានការធ្លាក់ចុះ ប្រសិនបើមិនមាន ការដោះស្រាយឱ្យបានឆាប់រហ័សបំផុតទេនោះ។

យ៉ាងណាមិញ ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណា "**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌច្បារអំពៅ**" បានធ្វើឱ្យមានការយល់កាន់តែច្បាស់អំពីបុព្វហេតុដែលនាំឱ្យមានការ

រៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ខណ្ឌច្បារអំពៅ ព្រមទាំងយល់ដឹងពីសារៈសំខាន់នៃការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពផងដែរ។ ការរៀបចំនោះមិនត្រឹមតែធ្វើឱ្យខណ្ឌមានរបៀបរៀបរយ និងមានសោភ័ណភាពស្រស់ស្អាតប៉ុណ្ណោះទេ គឺថែមទាំងធ្វើឱ្យខណ្ឌកាន់តែមាន ភាពទាក់ទាញមួយកម្រិតទៀត។ លើសពីនេះទៅទៀត ការរៀបចំនូវសណ្តាប់ធ្នាប់បានធ្វើឱ្យ ខណ្ឌទាំងមូលមានការអភិវឌ្ឍស្មើរគ្រប់វិស័យទាំងអស់នៅក្នុងខណ្ឌ ព្រមទាំងផ្តល់នូវទំនុកចិត្ត ដល់ប្រជាពលរដ្ឋឱ្យរស់នៅប្រកបដោយ ភាពសុខដុមរមនា ទាំងផ្លូវកាយ និងផ្លូវចិត្ត ពោរពេញទៅដោយភាពស៊ីវិល័យ និងទាន់សម័យទៅតាមសម័យកាលនាពេលបច្ចុប្បន្ន។

# អនុសាសន៍

# អនុសាសន៍

ដោយយោងតាមការសិក្សាស្រាវជ្រាវ និងពិនិត្យមើលតាមស្ថានភាពជាក់ស្តែងនៅក្នុងខណ្ឌច្បារអំពៅ គឺសង្កេតឃើញថាមានការអភិវឌ្ឍ និងរីកចម្រើនគួរឱ្យកត់សម្គាល់រួមមាន៖ ការអភិវឌ្ឍលំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងវិស័យសំខាន់ៗជាច្រើនដែលមិនធ្លាប់មានពីមុនមក។ ទោះជាយ៉ាងណាក្តី ក៏នៅមានបញ្ហាមួយចំនួនទៀតដែលអាជ្ញាធរខណ្ឌបាននឹងកំពុងអនុវត្ត ប៉ុន្តែហាក់បីដូចជាពុំសូវទទួលបានប្រសិទ្ធភាព និងទទួលបានផលល្អប្រសើរនៅឡើយសម្រាប់ក្នុងការទប់ស្កាត់នៅបញ្ហាដែលកើតឡើងមានជាយូរហើយនោះ។

ដើម្បីចូលរួមដោះស្រាយបញ្ហាខាងក្រោម យើងខ្ញុំសូមសេចក្តីអនុញ្ញាតបញ្ចេញមតិដូចតទៅ៖

- បញ្ហាសន្តិសុខ អំពើចោរកម្ម ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធក្នុងខណ្ឌច្បារអំពៅ មេត្តាពង្រឹងច្បាប់ និងផ្សព្វផ្សាយ ព្រមទាំងអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពឱ្យបានតឹងរឹងជាទីបំផុត ដើម្បីធានាដល់សុខសុវត្ថិភាពជូនប្រជាពលរដ្ឋ។
- បញ្ហាកកស្ទះចរាចរណ៍ ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធក្នុងខណ្ឌ ចាត់វិធានការណ៍ ការចរាចរណ៍ខុសម៉ោងពេលរបស់ប្រភេទឡានដឹកទំនិញធំៗ ឡានដឹកខ្សាច់ ដែលមិនបានពិនិត្យឱ្យបានត្រឹមត្រូវតាមច្បាប់ និងបច្ចេកទេសឱ្យបានត្រឹមត្រូវ ដែលអាចបង្កការកកស្ទះ គ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ។ មេត្តាពង្រឹងច្បាប់ និងផ្សព្វផ្សាយ ណែនាំដោយភាពទន់ភ្លន់ជូនដល់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការគោរពច្បាប់ចរាចរណ៍គ្រប់ៗគ្នា។
- បញ្ហារៀបចំប្រព័ន្ធលូមិនទាន់តម្រូវការប្រជាពលរដ្ឋ ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធ មេត្តាត្រួតពិនិត្យនៅតាមសង្កាត់-ភូមិ ដែលបានជន់លិចដោយសារទឹកភ្លៀង មេត្តាក្នុងការដោះស្រាយរៀបចំប្រព័ន្ធលូដល់ប្រជាពលរដ្ឋរស់នៅក្នុងភូមិ-សង្កាត់ណាមួយដែលកំពុងជួបបញ្ហាទាំងអស់នេះ។
- ស្នើសុំអាជ្ញាធរពាក់ព័ន្ធមេត្តាចុះផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីការវេចខ្ចប់ទុកដាក់សំណង់រឹង និងរាវរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ ដើម្បីចៀសវាងការកាយក្លិនមិនល្អ និងកកស្ទះប្រព័ន្ធលូ។
- ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធរៀបចំចញ្ចើមផ្លូវឱ្យមានរបៀបរៀបរយ កុំឱ្យមានអាជីវករ ឬឡានរត់តាក់ស៊ីចតនៅចញ្ចើមផ្លូវដែលនាំឱ្យមានភាពអនាធិបតេយ្យនៅក្នុងខណ្ឌ។
- ស្នើសុំឱ្យអាជ្ញាធរដែលពាក់ព័ន្ធ បម្រើសេវាការងារ ជូនប្រជាពលរដ្ឋ ដោយភាពសប្បាយរីករាយ ស្មោះត្រង់ មិនគិតពីប្រយោជន៍ពីប្រជាពលរដ្ឋ។

- ស្នើសុំឱ្យអាជ្ញាធរធ្វើការកែសម្រួលទៅលើបញ្ហាការរំលោភលើចិញ្ចើមថ្នល់ ដីចំណីផ្លូវ ជាពិសេសការលក់ដូរគ្មានសណ្ដាប់ធ្នាប់តាមដងផ្លូវ អសន្តិសុខ និងភាពអនាធិបតេយ្យ ដែលអាចធ្វើឱ្យមានការប៉ះពាល់ទៅលើសោភ័ណភាពនៅក្នុងខណ្ឌបាន។
- ស្នើសុំឱ្យអាជ្ញាធរមានការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាននៅក្នុងខណ្ឌ ដូចជាបញ្ហាការគ្រប់គ្រងកាកសំណល់ ការប្រមូល ការដឹកជញ្ជូន និងការស្តុកសំរាមទុក ដែលបញ្ហាទាំងនេះសុទ្ធសឹងតែជាបញ្ហាដែលអាចបង្កជាការបំពុលដល់បរិស្ថានបាន។
- ស្នើទៅដល់ប្រជាពលរដ្ឋរស់នៅក្នុងខណ្ឌទាំងអស់ ចូលរួម ថែរក្សា ការពារ យកចិត្តទុកដាក់ និងបើកចិត្តទទួលយកការអប់រំពីថ្នាក់ដឹកនាំនៅក្នុងខណ្ឌ។
- ស្នើទៅដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ឱ្យចូលរួមសហការជាមួយថ្នាក់ដឹកនាំនៅក្នុង ខណ្ឌ និងគោរពទៅតាមសេចក្តីប្រកាស ការណែនាំ ព្រមទាំងអនុវត្តឱ្យបានខ្ជាប់ខ្ជួន។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- មាត្រា៥ និងមាត្រា៧ ច្បាប់ស្ដីពី "ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤
- មាត្រា ៥ ច្បាប់ចរាចរណ៍ផ្លូវគោក ដែលអនុម័ត ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ និងវិសោធនកម្ម ឆ្នាំ២០១៧
- មត្រា១ អនុក្រឹត្យ លេខ ៥៧៩ អនក្រ.បក ស្ដីពី ការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៣
- មាត្រា៤ មត្រា៦មាត្រា៨ និងមាត្រា៩អនុក្រឹត្យ លេខ២៧ អនក្រ.បក"ស្ដីពីការត្រួតពិនិត្យការបំពុលទឹក" ចុះថ្ងៃទី២៧ ឆ្នាំមេសា ឆ្នាំ១៩៩៩
- មាត្រា៨ ១០ ១១ និងមាត្រា១២អនុក្រឹត្យលេខ៤២ អនក្រ.បក ស្ដីពី "ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០
- មាត្រា៣ អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្ដីពី "ការគ្រប់គ្រងសំណល់រឹង" លេខ៣៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៦
- មាត្រា៤ អនុក្រឹត្យ លេខ២៣៥ អនក្រ.បក "ស្ដីពីការគ្រប់គ្រងប្រពន្ធ័លូ និងប្រពន្ធ័ប្រព្រឹត្តកម្មទឹកកខ្វក់" ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៧
- អនុក្រឹត្យ លេខ១១៣ អនក្រ.បក ស្ដីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- មាត្រា៣ មាត្រា៧ និងមាត្រា៩ អនុក្រឹត្យ លេខ៤២ អនក្រ.បក ស្ដីពី "ការត្រួតពិនិត្យការបំពុលខ្យល់និងការរំខានដោយសំលេង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

## ២.ប្រកាស និងសារាចរណ៍

- ប្រកាសលេខ៣៤៨ ស្ដីពី តួនាទីភារកិច្ច របៀបរបបការងារ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ។
- ប្រកាស លេខយោង ០០០០១៤/system ស្ដីពីការគ្រប់គ្រងសំណល់រាវដែលមានសារធាតុគីមីពុល កាលបរិច្ឆេទ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**៣. សេចក្តីជូនដំណឹង សេចក្តីណែនាំ និងរបាយការណ៍**

- របាយការណ៍ស្រាវជ្រាវ សាលាខណ្ឌមានជ័យ ការបង្កើតខណ្ឌថ្មី, ឆ្នាំ២០១៣ ។
- សេចក្តីណែនាំរដ្ឋបាលរាជធានីភ្នំពេញ លេខ ០១៣/១៨ សជណ ស្តីពី "ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨
- សេចក្តីណែនាំ លេខ០០៩/១៩ សណន.ស ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៩
- សេចក្តីជូនដំណឹង លេខ០៣៣/២១សជណ.ចអព.អណ៣ ស្តីពី "ការហាមលក់ដូរលើផ្លូវ៣៥៧ ផ្សារព្រែកឯង និងផ្លូវលេខ៣៦៩ ក្នុងខណ្ឌច្បារអំពៅ" ចុះថ្ងៃទី១០ ខែឧសភា ២០២១
- សេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ លេខៈ ០២៦/២១ សជណ ស្តីពី "ការពង្វាងចរាចរណ៍នៅលើស្ពានព្រះមុនីវង្សចាស់" ចុះថ្ងៃទី ០៧ មេសា ២០២១
- សារណាបញ្ចប់ការសិក្សា"ការរៀបចំសណ្តាប់ធ្នាប់និងសោភ័យភាពខណ្ឌចំការមន"របស់និស្សិតឈ្មោះ ក.ហុង ដានេ និងក.លី សុជាតា សាស្ត្រាចារ្យណែនាំ បណ្ឌិត ហាប់ ផល្លី ឆ្នាំ២០១៨ ទំព័រទី២៧ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

**៤. សៀវភៅ**

- កែវ ច័ន្ទរស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី២២
- សៀវភៅ នីតិនគរូបនីយវិទ្យា , សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា បោះពុម្ព ឆ្នាំ២០១៩-២០២០ ទំព័រ១ ទំព័រទី៥ ទំព័ទីរ៦ ទំព័រទី៧ និងទំព័រ១៤៤
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៣៦ ទំព័រទី៦០ ទំព័រទី៦៤, ទំព័រទី៦៥ និងទំព័រ៦៦
- សៀវភៅ "កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២០-២០២២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ "បានទទួលការអនុម័តពីក្រុមប្រឹក្សាខណ្ឌ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

**៥.រចនានុក្រម**

- សម្តេចព្រះសង្ឃរាជ ជួន ណាត

### ៥. គេហទំព័រ

- គេហទំព័រ http://nokorwatnews.com/archives/455772?fbclid=IwAR ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី បានចុះគ្រឿងចក្រជួសជុលផ្លូវលេខ១១០ ក្នុងខណ្ឌច្បារអំពៅ | សាលារាជធានីភ្នំពេញ (phnompenh.gov.kh) ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.cpp.org.kh/details/161552?fbclid=IwAR ដកស្រង់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nkdnews.com/archives/297182?fbclid=IwAR ដកស្រង់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://cambodiapropertyreport.com/article/4132?fbclid=IwAR ដកស្រង់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://news.ctv8.com.kh/2018/77052/?fbclid=IwAR ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/455772?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nkdnews.com/archives/297182?fbclid=IwAR3SMLNiFgCvcc9jnBk ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/341058?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://news.kohsantepheapdaily.com.kh/article/746796.html?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://mpwt.gov.kh/kh/press/16268?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/483731?fbclid=IwAR ដកស្រង់ថ្ងៃទី០៧ ខែកកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.mpwt.gov.kh/kh/press/16133 ដកស្រង់ថ្ងៃទី០៨ ខែកកក្កដា ឆ្នាំ២០២១

- គេហទំព័រ https://www.kampucheathmey.com/businesseconomic/54510/ ដកស្រង់ថ្ងៃទី០៨ ខែកកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.construction-property.com/km/preaek-pra-canal-land-encroachers ដកស្រង់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.postkhmer.com/ ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://crosscheckwmc.com/post/1/53?fbclid=IwAR0R ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/656638?fbclid=IwAR0K ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://rktnews.com/archives/150084?fbclid=IwAR36fOQuEGrf4_ ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://csndaily.com/index.php?a=article&id=13666&fbclid=IwAR3OOpog_f5m ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.cpc-news.com/archives/101067 ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.cycpp.news/2021/01/55309/?fbclid=IwAR3BbvHEP79I7-hs4-m ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/490278?fbclid=IwAR ដកស្រង់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.cpc-news.com/archives/52908 ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://csndaily.com/index.php?a=article&id=15733&fbclid=IwAR2BhnWNDG1U ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://kohreport.com/news/9507/?fbclid=IwAR2ZuCl4T-MBgnCDoN_4RcQzztU9GGdjw_ ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://cambodiapropertyreport.com/article/1557?fbclid=IwAR ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

- គេហទំព័រ https://news.sabay.com.kh/article/1240235?fbclid=Iw ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://cambodiapropertyreport.com/article/4132?fbclid=IwAR2s5qJKYyTxs0bGJs0yXy ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/341058?fbclid=IwAR ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.kampucheathmey.com/localnews/53160/?fbclid=IwAR2 ដកស្រង់ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://phnompenh.gov.kh/news-press-releases/post/news081020/ ដកស្រង់ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/341058 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://www.google.com ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://lorkremlaw.files.wordpress.com/2014/09/e19e9fe19e89e19f92e19e89e19eb6e19e85e19e9ae19eb6e19e85e19e9ae19e8ee19f8de19e95e19f92e19e9be19ebce19e9ce19e82e19f84e19e80.pdf ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://free.facebook.com/762625803936611/posts/1044884679044054/?_rdc=1&_rdr ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://facebook.com/សាលាខណ្ឌច្បារអំពៅ/posts/11-06-2021 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://facebook.com/សាលាខណ្ឌច្បារអំពៅ/posts/03-04-2021 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://nokorwatnews.com/archives/356964 ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://opendevelopmentcambodia.net/km/topic/pollution-and-waste/#ref-74643-2 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://healthcambodia.com/p6241/ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

- គេហទំព័រ https://km.warbletoncouncil.org/causas-consecuencias-contaminacion-agua-11450#menu-3 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រhttps://km.warbletoncouncil.org/contaminaction-del-suelo-3188 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://livelearn.org/assets/media/docs/resources/GoodPeople_GoodEnv_flipchart_khm.pdf ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health:ការបំពុលខ្យល់ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://km.eferrit.com/និយមន័យនៃការបំពុលខ្យល់/ ដកស្រង់ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/pollution-and-waste/ ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ http://mekonginfo.org/assets/midocs/0002192-environment-solid-waste-managementtraining-material.pdf ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១
- គេហទំព័រ https://www.cpp.org.kh/details/238080 ដកស្រង់ថ្ងៃទី១៦ខែ កក្កដា ឆ្នាំ២០២១
- គេហទំព័រ https://km.warbletoncouncil.org/tipos-contamination-acustica-16274 ដកស្រង់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

## មាតិកាឧបសម្ព័ន្ធ

**១.ឧបសម្ព័ន្ធរូបភាព**

**ឧបសម្ព័ន្ធទី១៖** ផែនទីខណ្ឌច្បារអំពៅ

**ឧបសម្ព័ន្ធទី២៖** រូបភាពកំពុងសាងសង់

**ឧបសម្ព័ន្ធទី៣៖** រូបភាពសាងសង់ជាស្ថាពរ

**២.ឧបសម្ព័ន្ធគតិយុត្តិ**

**ឧបសម្ព័ន្ធទី១៖** ច្បាប់ស្តីពី "ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ,លេខ ៥៧៩, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣, មាត្រា១

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ លេខ២៣៥ អនក្រ.បក "ស្តីពីការគ្រប់គ្រងប្រពន្ធ័លូ និងប្រពន្ធ័ប្រព្រឹត្តកម្មទឹកកខ្វក់" ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៧

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពី "ការត្រួតពិនិត្យការបំពុលខ្យល់-និងការរំខានដោយសំលេង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យស្តីពីលេខ៤២ អនក្រ.បក "ការត្រួតពិនិត្យការបំពុលខ្យល់-និងការរំខានដោយសំលេង" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

# ឧបសម្ព័ន្ធរូបភាព៖

# ឧបសម្ព័ន្ធទី១៖

# ខណ្ឌច្បារអំពៅ


ខណ្ឌចំការមន
ស្រុកល្វាឯម
ស្រុកកៀនស្វាយ
ខណ្ឌមានជ័យ
ក្រុងតាខ្មៅ
វាលស្បូវ
និរោធ
ព្រែកឯង
ក្បាលកោះ
ព្រែកប្រា
ព្រែកថ្មី
ជើង
លិច
កើត
ត្បូង

# ឧបសម្ព័ន្ធទី២៖






XCMG






XCMG

# ឧបសម្ព័ន្ធទី៣៖








# ឧបសម្ព័ន្ធគតិយុត្ត

# ឧបសម្ព័ន្ធទី១៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

# ច្បាប់

## ស្តីពី

# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់

## ស្តីពី

## ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

## ជំពូកទី ១

## កម្មវត្ថុ

មាត្រា ១.-

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំកែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

- គោរពប្រយោជន៍រួមនិងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផងនិងត្រួតពិនិត្យការសាងសង់ផង ។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រនិងលក្ខណៈពិសេសនៃជនបទនីមួយៗ ។
- ធានាលើកតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍និងរក្សាបាននូវគុណភាពបរិដ្ឋាន ។

មាត្រា ២.-

ច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែឬផ្លាស់ប្តូរ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នឹងត្រូវកែច្នៃអោយស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

មាត្រា ៣.-

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលមានសមាជិកនិងសំណើការតែងតាំងនឹងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់សំរាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំ-ពេញឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ សំរាប់ក្រុងភ្នំពេញត្រូវកំណត់ដោយអនុក្រឹត្យ ។

ចំពោះខេត្ត ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលដឹកនាំដោយអភិបាលខេត្ត ក្រុង និងអង្គភាពបច្ចេកទេសខេត្ត ក្រុង ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយសេចក្តីសំ-រេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ ។

 លលល

## ជំពូកទី ៣
## ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់

មាត្រា ៦.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

មាត្រា ៧.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់ សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខាសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

មាត្រា ៨.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៩.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់សំរាប់រាជធានីនិងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានី ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ទៀត ។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងដែរ ។

មាត្រា ១០.-

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេស ។ បញ្ជីអចលនវត្ថុឬ

# ជំពូកទី ២

## ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

មាត្រា ៤.-

ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ អោយសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិដ្ឋានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

មាត្រា ៥.-

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានីភ្នំពេញឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ខេត្ត ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំនិងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់និងកំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាននិងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានភារៈរៀបចំប្លង់គោលសំរាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

រមណីយដ្ឋានទាំងនោះនិងកំណត់ដោយអនុក្រឹត្យ ។ ការរុះរើ ការផ្លាស់ប្តូរទ្រង់ទ្រាយនិងការគ្រប់គ្រងអចលនវត្ថុនិងរមណីយដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

បទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្មនិងអភិវឌ្ឍន៍និងចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជីអចលនវត្ថុដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពនិងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនេះ តាមបញ្ញត្តិច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈនិងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្ដឹងទៅតុលាការទារជម្ងឺចិត្ត ។

មាត្រា ២២.-

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើវាយកំទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេសនិងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា។

មាត្រា ២៣.-

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ ច័ន្ទ ទី ២៣ ខែឧសភា ឆ្នាំ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភាលើកទី ២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី[២៤] ខែឧសភា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្ដីទី

# ឧបសម្ព័ន្ធទី២៖

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត**ខណ្ឌច្បារអំពៅ** នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន ០៨ ពីខណ្ឌមានជ័យ នៃរាជធានីភ្នំពេញគឺ សង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី ។

ព្រំប្រទល់រដ្ឋបាល**ខណ្ឌច្បារអំពៅ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌមានជ័យដែលស្ថិតនៅក្នុងសង្កាត់ច្បារអំពៅទី១ ទៅឱ្យសាលា**ខណ្ឌច្បារអំពៅ** ។

**មាត្រា ៣.-**

ទីតាំងសាលាខណ្ឌមានជ័យ ត្រូវស្ថិតនៅក្នុងសង្កាត់ចាក់អង្រែលើ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**ខណ្ឌច្បារអំពៅ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌមានជ័យ អភិបាលខណ្ឌមានជ័យ និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសុវត្ថិភាព សុខភាពសាធារណៈ និងការអភិរក្សជីវចម្រុះ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- រៀបចំ កែសម្រួល និងពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ប្រគល់មុខងារប្រតិបត្តិការ និងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ
- កំណត់នូវវិធានការចាំបាច់នានាដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ អំពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន ក្នុងការអភិវឌ្ឍន៍ ឬវិនិយោគសាងសង់ ប្រតិបត្តិការនិងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ ពុំមានវិសាលភាពអនុវត្តលើការគ្រប់គ្រងសំណល់រាវឧស្សាហកម្មឡើយ។

**មាត្រា៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់ រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅដ្ឋាន បុរីលំនៅដ្ឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និង តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
- **សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម
- **ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ(បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)
- **បណ្តាញលូរួម** សំដៅដល់បណ្តាញលូប្រមូល និងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងជាមួយគ្នា។



kz

- បណ្តាញលូដាច់ដោយឡែក សំដៅដល់បណ្តាញលូប្រមូលនិងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងញែកដាច់ផ្សេងពីគ្នា
- បណ្តាញលូមេ សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងអាងស្តុក ស្ថានីយ៍បូម ឬស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្តាញលូមេរង សំដៅដល់ប្រព័ន្ធលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ និងទទួលទឹកកខ្វក់ពីបណ្តាញលូខ្នែង
- បណ្តាញលូខ្នែង សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ ឬបណ្តាញលូ មេរង។
- បណ្តាញលូខ្នែងរង សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូខ្នែង និងទទួលទឹកកខ្វក់ពីទីតាំង ឬប្រភពបញ្ចេញ
- ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយ៍បូមទឹកលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ
- អាងស្តុកធម្មជាតិ សំដៅដល់អាងស្តុកទឹក បឹង ប្រឡាយ ឬស្រះសាធារណៈ ដែលបានប្រើប្រាស់សម្រាប់ស្តុក និងសម្អាតទឹកកខ្វក់តាមលក្ខណៈធម្មជាតិ
- ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ
- តំបន់ទឹកសាធារណៈ សំដៅដល់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជា ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ បឹង ស្រះ ត្រពាំង សមុទ្រ ដៃសមុទ្រ ពាម ប្រព័ន្ធប្រឡាយធារាសាស្ត្រ ទឹកក្រោមដី។ល។
- ទីប្រជុំជន សំដៅដល់ទីប្រជុំជនរាជធានី ទីប្រជុំជនខេត្ត ទីប្រជុំជនក្រុង ទីប្រជុំជនស្រុក និងទីប្រជុំជនខណ្ឌ
- ទីតាំង សំដៅដល់លំនៅដ្ឋាន លំនៅដ្ឋានប្រមូលផ្តុំ បុរីលំនៅដ្ឋាន អគារអាជីវកម្ម និងទីក្រុងរណប
- លំនៅដ្ឋាន សំដៅដល់ផ្ទះស្នាក់នៅជាលក្ខណៈឯកជនផ្ទាល់ខ្លួន
- លំនៅដ្ឋានប្រមូលផ្តុំ សំដៅដល់ផ្ទះស្នាក់នៅដែលទទួលសិទ្ធិកាន់កាប់បន្តពីអាជីវកម្មសាងសង់លំនៅដ្ឋានលក់ តែពុំមានអ្នកទទួលខុសត្រូវរួម
- បុរីលំនៅដ្ឋាន សំដៅដល់តំបន់អភិវឌ្ឍន៍លំនៅដ្ឋានប្រមូលផ្តុំដែលមានម្ចាស់បុរីនៅបន្តទទួលខុសត្រូវរួម
- អគារអាជីវកម្ម សំដៅដល់ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន ទីផ្សារ ផ្សារទំនើប អគារពាណិជ្ជកម្ម អគារសេវាកម្ម ទីសត្តឃាត អាផាតមែន និងអគារខុនដូ



ℓ

- **ទីក្រុងណេប** សំដៅដល់តំបន់អភិវឌ្ឍន៍ចម្រុះ រួមមាន៖ លំនៅដ្ឋានទំនើប អាផាតមែន អគារខុនដូ ផ្សារទំនើប សណ្ឋាគារ ភោជនីយដ្ឋាន អគារពាណិជ្ជកម្ម អគារសេវាកម្ម មណ្ឌលកំសាន្ត។ល។
- **អាងសិបទិច** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ
- **កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ** សំដៅដល់ការបង់ថ្លៃសម្រាប់ការថែទាំ ជួសជុល ស្តារ និងពង្រីកអណ្តូងលូ បណ្តាញលូ ប្រឡាយចំហ អាងស្តុក និងដំណើរការស្ថានីយ៍បូមទឹកកខ្វក់
- **កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ការបង់ថ្លៃសម្រាប់ការសម្អាតទឹកកខ្វក់
- **សំណល់កក់** សំដៅដល់កាកសំណល់ពីអាងសិបទិច ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- **រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត** សំដៅដល់ទីកន្លែងសម្រាប់អ្នកទេសចរទៅទស្សនា និងសម្រាកលំហែរកាយ ដែលមានផ្តល់នូវសេវាម្ហូបអាហារ ភេសជ្ជៈ កន្លែងស្នាក់ កីឡា កម្សាន្ត និងទិញទំនិញ។ល។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងការងារបច្ចេកទេសប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ និងផែនការអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច
- រៀបចំបទដ្ឋានបច្ចេកទេសស្តីពីការសាងសង់ គ្រប់គ្រង ប្រតិបត្តិការ និងការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនក្នុងការវិនិយោគសាងសង់ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គាំទ្រធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជន អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទដ្ឋានបច្ចេកទេស

ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល
- ការបង់ប្រាក់សំណងជួសជុលការបាក់បែកឬខូចខាតប្រព័ន្ធលូសាធារណៈ
- ការបង់ប្រាក់សំណងជួសជុលការខូចខាតបរិក្ខារគ្រឿងចក្រនៃស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ឬការធ្វើឱ្យមានប្រក្រតីភាពនៃដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា៥០.-**

បុគ្គលដែលយកសំរាម សំណល់រឹង សំណល់ប្រេងឥន្ធនៈ សារធាតុគីមី ឬសំណល់កក់ ចាក់ចូលប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល
- ការប្រមូលយកសំណល់ ឬសារធាតុដែលបានចាក់ចូលចេញពីប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៥១.-**

បទប្បញ្ញត្តិនៃមាត្រា២១ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍន៍នៃសំណង់បុរីលំនៅដ្ឋាន ឬទីក្រុងរណបថ្មី ដែលទទួលបានច្បាប់សាងសង់ក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

**មាត្រា៥២.-**

បទប្បញ្ញត្តិនៃជំពូកទី៦ ទោសប្បញ្ញត្តិ ត្រូវយកមកអនុវត្តចំពោះទីតាំងដែលមានការផ្តល់ជូននូវសេវាកម្មប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ។

ទីតាំងដែលមានការផ្តល់ជូននូវសេវាកម្មប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងក្រសួងសាធារណការ និងដឹកជញ្ជូន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៥៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងស្មារតីនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៨ កើត ខែ បុស្ស ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ គ.ស.២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

Chanthol Sun

**ស៊ុន ចាន់ថុល**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ
# ស្តីពី
# ការត្រួតពិនិត្យការបំពុលខ្យល់
# និងការរំខានដោយសំលេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាបួប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងឧសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្ដល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្ដឹង ឬសេចក្ដីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្ដែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្ដន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូក ទី ៩ នៃច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំង

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# ឧបសម្ព័ន្ធទី៥៖

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៤ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៧ អនក្រ.បក

### ស្តីពីការត្រួតពិនិត្យការបំពុលទឹក

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៩

**សំរេច**

**ជំពូកទី ១**

**បទបញ្ញត្តិទូទៅ**

មាត្រា ១ .- អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

មាត្រា ២ ._ អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្ក អោយមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

មាត្រា ៣ ._ និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ ៖

ក- " **តំបន់ទឹកសាធារណៈ** " ៖ គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា ៖ ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំង ប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹក ក្រោមដី ។

ខ- " **ប្រភពបំពុល** " គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគារ រដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូននិងតំបន់អាជីវកម្ម ឬសេវាកម្ម ដែល បញ្ចេញ សំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬ មិនផ្ទាល់ក្តីចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ។

គ-" **សំណល់រាវ** " ៖ គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្ត កម្មក្តី ។

ឃ- " **ទឹកលូ** " ៖ គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ។

ង- " **សំណល់រឹង** " ៖ គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវ បានបញ្ចេញចោលពីប្រភពបំពុល ។

ច- " **សំរាម** " ៖ គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបាន បញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ- " **សារធាតុបំពុល** " ៖ គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែល ធ្វើអោយមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើអោយប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូល ទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ- " **បរិមាណសារធាតុបំពុល** " ៖ គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅ ដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ- " **សារធាតុប្រកបដោយគ្រោះថ្នាក់** " ៖ គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមាន គ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាល អោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែង នៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

មាត្រា ៤ ._ កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។

មាត្រា ៥ ._ ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែកសំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៦ ._ ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

មាត្រា ៧ ._ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

កំរិតកំណត់ស្តង់ដារបរិមាណសាធារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៧ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៨ ._ ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសាធារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំអោយមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

មាត្រា ៩ ._ ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធស្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

មាត្រា ១០ ._ ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

ក-ធ្វើកំណត់....ហេតុប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-កំណត់....ប្រមូលនិងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ ទៅដល់សុខភាពមនុស្ស សត្វឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

មាត្រា ៣៤ ._ ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៤ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ៣៥ ._ កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តខុស ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តនូវវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

មាត្រា ៣៦ ._ មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល នឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

មាត្រា ៣៧ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣៩ ._ អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★